ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ៦៧ "ខ"
ចុះថ្ងៃទី ០៦-០១-២០២១
សំណុំរឿងព្រហ្មទណ្ឌលេខ ៤៥២០
ចុះថ្ងៃទី ១៧-៧-២០១៩
សំណុំរឿងស៊ើបសួរលេខ ៣៦២៨
ចុះថ្ងៃទី ១៣-៨-២០១៩
សំណុំរឿងជំនុំជម្រះលេខ ៨៨៩
ចុះថ្ងៃទី ២១-០២-២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង១៤ និង ៣០នាទី រសៀល និងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង០៨ និង៣០នាទី ព្រឹក នៅសាលសវនាការទី១ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-កញ្ញា [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៤៥២០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សាក់លី ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ អ្នកគ្រប់គ្រងក្រុមហ៊ុន HSC Beverages Co.,LTD មានទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្តាល សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៤២អា ផ្លូវលេខB សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] សៀកលីម មានកូន០២នាក់ ឪពុកឈ្មោះ [redacted] សុង "រស់" ម្តាយឈ្មោះ [redacted] លាងហេង "រស់" ទោសពីមុនគ្មាន ជាទីតិជន។

-លិខិតដោះលែងលេខ: ២៩៩៣ ល.ដ.ល ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ របស់មណ្ឌលអប់រំកែប្រែទី១ (ម១)។

-មានលោកមេធាវី [redacted] មានការិយាល័យនៅផ្ទះលេខ២៧ ផ្លូវ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២-ឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ ប្រធានគណនេយ្យក្រុមហ៊ុន HSC Beverages Co.,LTD មានទីកន្លែងកំណើតនៅ [redacted] ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ បរិញ្ញាប័ត្រ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៣៥៣ ផ្លូវលំ ភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] សោភ័ណ្ឌ មានកូន០២នាក់ ឪពុកឈ្មោះ [redacted] រិទ្ធី "រស់" ម្តាយឈ្មោះ [redacted] ខេង "ស្លាប់" ទោសពីមុនគ្មាន ជាទីតិជន។

-លិខិតដោះលែងលេខ: ១១១៨ ពក/២០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ពន្ធនាគាររាជធានីភ្នំពេញ។

100
34

-មានលោកមេធាវី [redacted] មានការិយាល័យនៅផ្ទះលេខ២៧ ផ្លូវ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-មានលោកមេធាវី [redacted] មានការិយាល័យនៅផ្ទះ លេខ៥២E0E1 ក្រុម០៩ ផ្លូវលេខ៨ សង្កាត់គីឡូលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ជាប់ចោទពីបទ **រំលោភលើទំនុកចិត្តពិសេសដោយអភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង ភេទប្រុស មានទីលំនៅផ្ទះលេខ១៨ ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-មានលោកមេធាវី [redacted] និងកញ្ញាមេធាវី [redacted] មានទីស្នាក់ការជាន់ទី១ អគារលេខ៨B ផ្លូវលេខ៨១ កែងផ្លូវលេខ១០៩ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលអំឡុងឆ្នាំ២០១៧ ឈ្មោះ [redacted] ហុង បានបង្កើតក្រុមហ៊ុនមួយឈ្មោះ HSC Bevera ges Co.,Ltd មានស្នាក់ការកណ្តាលនៅផ្ទះលេខ១៨ ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បានប្រគល់សិទ្ធិជូនឈ្មោះ [redacted]សាក់លី ធ្វើជានាយកគ្រប់គ្រងទូទៅ និងឈ្មោះ [redacted] រតនៈ ជាប្រធានគណនេយ្យ។ បន្ទាប់ពីក្រុមហ៊ុនដំណើការ និងក្រោមការកាន់កាប់គ្រប់គ្រងរបស់ឈ្មោះ [redacted] សាក់លី ដែលមានឈ្មោះ [redacted] រតនៈ ជាប្រធានគណនេយ្យ ពួកគេបានឃុបឃិតគ្នាជាមួយនឹងបក្ខពួកធ្វើរបាយការណ៍គណនេយ្យភូតកុហកផ្លាស់ប្តូរទិន្នន័យជាច្រើនលើកច្រើនសារក្នុងមួយឆ្នាំៗ បង្កើតឲ្យមានការលំអៀងប្រាក់ និងកិបកេងយកប្រាក់របស់ក្រុមហ៊ុនធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឲ្យក្រុមហ៊ុន HSC Bevera ges Co., Ltd មានការខាតបង់ប្រាក់សរុបអស់ចំនួន ២,០៩៣,១៦៦.២២$ (ពីរលានប្រាំបួនម៉ឺនបីពាន់មួយរយហុកសិបប្រាំមួយដុល្លាអាមេរិក និងម្ភៃពីរសេន)។ បន្ទាប់ពីបានរកឃើញថាក្រុមហ៊ុនមានការបាត់បង់ប្រាក់យ៉ាងច្រើន ឈ្មោះ [redacted]ហុង ដែលជាប្រធានក្រុមហ៊ុន HSC Beverages Co., Ltd បានឱ្យឈ្មោះ[redacted] សាក់លី ,ឈ្មោះ [redacted] រតនៈ និងបក្ខពួកផ្តល់កិច្ចសហការដើម្បីដោះស្រាយបញ្ហានេះ និងផ្តល់នូវឯកសារលំអិតពីការគ្រប់គ្រងរបស់ខ្លួន ប៉ុន្តែបក្ខពួកទាំងនេះ ពុំបានផ្តល់នូវឯកសារលំអិតពីការគ្រប់គ្រងរបស់ខ្លួនឡើយ បែរជាបិទទូរស័ព្ទហើយនាំគ្នាគេចខ្លួនបាត់តែម្តង។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted]ហុង។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៣៦៧៣ អ.យ.ក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ២៨៥ អ.យ.ក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៦៣០ "ហ" ដ.ង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ក្រឡាបញ្ជីរាយការណ៍អំពីវត្តមាន និងអវត្តមានភាគី:

+សាក្សីឈ្មោះ [redacted] លក្ខិណា ,ឈ្មោះ [redacted] សុភ័ក្រ្ត ,ឈ្មោះ [redacted] ទូច ,ឈ្មោះ [redacted] ធារ៉ា ,ឈ្មោះ [redacted] ដេវីត ,ឈ្មោះ [redacted] វ័ត្ថនៈ ,ឈ្មោះ [redacted] ដារិទ្ធ និងកញ្ញាមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី (វត្តមាន)។

+ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ,សាក្សីឈ្មោះ [redacted] គីមឡេង និងឈ្មោះ [redacted] ស្រីវើន ,លោកមេធាវី [redacted] ធុនណា និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (អវត្តមាន)។

-ក្រឡាបញ្ជីអានពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងដីកាសម្រេចច្រានចោលពាក្យបណ្តឹងជំទាស់លេខ ១១២ ដកឧ.២០២០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០២០ ,ពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] រតនៈ និងដីកាសម្រេចច្រានចោលពាក្យបណ្តឹងជំទាស់លេខ ១៤៣ ដកឧ.២០២០ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍។

-ក្រឡាបញ្ជីអានពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ។

-កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានមានមតិយោបល់ថា: ដោយសារសំណុំរឿងនេះជនជាប់ចោទបានប្តឹងជំទាស់ចៅក្រមជំនុំជម្រះចំនួន០២ដងហើយ ហើយក៏ត្រូវបានតុលាការជាន់ខ្ពស់សម្រេចច្រានចោលរួចទៅហើយដែរ ដូចនេះសុំឱ្យលោកចៅក្រមបន្តនីតិវិធីជំនុំជម្រះទៅតាមច្បាប់។

-តំណាងអយ្យការមានមតិយោបល់ថា: ក្នុងសំណុំរឿងនេះ ជនជាប់ចោទបានប្តឹងជំទាស់ចៅក្រមជំនុំចំនួន០២ដងទៅហើយ ហើយតុលាការជាន់ខ្ពស់ក៏បានសម្រេចច្រានចោលពាក្យបណ្តឹងចិត្តរបស់ជនជាប់ចោទរួចហើយដែរ ដូចនេះសុំឱ្យលោកចៅក្រមបន្តនីតិវិធីជំនុំជម្រះតាមនីតិវិធីច្បាប់។

-តុលាការយល់ឃើញថា ដោយសារជនជាប់ចោទបានប្តឹងជំទាស់ចៅក្រមជំនុំជម្រះចំនួន០២ដងរួចមកហើយ ហើយក៏ត្រូវបានសាលាឧទ្ធរណ៍សម្រេចច្រានចោលពាក្យបណ្តឹងជំទាស់របស់ជនជាប់ចោទរួចហើយដែរ ចំពោះពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ពុំមានមូលហេតុថ្មីក្នុងការប្តឹងជំទាស់ចៅក្រមជំនុំជម្រះនោះទេ ដូច្នេះ តុលាការសម្រេចបន្តសវនាការ។

-សាក្សីឈ្មោះ [redacted] លក្ខិណា បានឆ្លើយថា: កាលពីអំឡុងខែឧសភា ឆ្នាំ២០១៧ ខ្លួនបានចូលបម្រើការងារនៅក្រុមហ៊ុន HSC Beverages នៅផ្នែកតែអូរអិលឈិ ខាងរៀបចំបណ្ណចំណាយរបស់ក្រុមហ៊ុន ដែលផ្ទាល់លើ

របស់ខ្លួនមានឈ្មោះ [redacted] រតនៈ ជាប្រធានគណនេយ្យ ,ឈ្មោះ [redacted] សាក់លី ជាប្រធានគ្រប់គ្រង និងឈ្មោះ [redacted] ដេវីត ជាអភិបាលក្រុមហ៊ុន។ ពេលនោះខ្លួនទទួលបានប្រាក់ខែចំនួន ៣៥០$ (បីរយហាសិបដុល្លារអាមេរិក) ក្នុងមួយខែ ហើយបច្ចុប្បន្ននេះឡើងដល់ ៦២០$ (ប្រាំមួយរយម្ភៃដុល្លារអាមេរិក) ក្នុងមួយខែ។ ចំពោះការបញ្ជាទិញផលិតផលតែអូរិលឈិពីក្រុមហ៊ុននៅប្រទេសថៃ និងការប្តូរគម្រូបរង្វាន់តែអូរិលឈិ ខ្លួនមិនបានដឹងទេ ព្រោះមិនមែនជាការងាររបស់ខ្លួនទេ។ រាល់ការចំណាយរបស់ក្រុមហ៊ុនគ្រប់ផ្នែកទាំងអស់ត្រូវប្រគល់វិក័យប័ត្រចំណាយនោះមកផ្នែកចំណាយ ហើយខ្លួនរៀបចំឯកសារ ដើម្បីស្នើសុំទៅប្រធានក្រុមហ៊ុនតាមរយៈលោក [redacted] រតនៈ , លោក [redacted] សាក់លី និងលោក [redacted] ដេវីត រួចបញ្ជូនទៅលោកស្រី [redacted] គីមឡេង ដែលជាប្រធានគណនេយ្យរបស់ក្រុមហ៊ុន HSC Beverages Co.,Ltd ទើបដាក់ជូននាយកក្រុមហ៊ុនលោកឧកញ៉ា [redacted] ហុង ជាអ្នកសម្រេចចេញមូលប្បទានប័ត្រប្រគល់មកខាងខ្លួនវិញ ទើបខ្លួនបញ្ជូនមូលប្បទានប័ត្រនោះទៅឱ្យក្រុមហ៊ុនដែលជាម្ចាស់សម្ភារៈ។ ចំពោះការកោះប្រជុំថាក្រុមហ៊ុនមានបញ្ហានោះ ខ្លួនមិនបានដឹងទេ ព្រោះគេបានប្រជុំតែមេៗ តែកាលពីខែមិថុនា ឆ្នាំ២០១៩ នេះ មានការចុះសវនកម្មក្រុមហ៊ុនរយៈពេលមួយអាទិត្យ ហើយខ្លួនបានបញ្ជូនឯកសារដើម្បីឱ្យគេពិនិត្យដែរ ប៉ុន្តែមិនឃើញប្រធានគណនេយ្យចូលរួមទេ។ បច្ចុប្បន្ននេះខ្លួននៅធ្វើការធម្មតា ហើយខ្លួនមិនដឹងរឿងអ្វីទៀតទេ។

-សាក្សីឈ្មោះ [redacted] សុភ័ក្ត្រ បានឆ្លើយថាៈ កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ខ្លួនបានចូលធ្វើការនៅក្រុមហ៊ុន HSC Beverages មានតួនាទីជាអ្នកប្រមូលប្រាក់ពីអតិថិជន ដោយទទួលបានប្រាក់ខែចំនួន ២០០$ (ពីររយដុល្លារអាមេរិក) ក្នុងមួយខែ ហើយពេលនេះប្រាក់ខែខ្លួនឡើងដល់ ៣៣០$ (បីរយសាមសិបដុល្លារអាមេរិក)។ ចំពោះការងាររបស់ខ្លួនគឺទទួលបន្ទុកដើរប្រមូលប្រាក់ពីអតិថិជនតាមដេប៉ូ នៅពេលដែលឈ្មោះ [redacted] ស្រីរ៉េន ទម្លាក់បុងឱ្យមកខ្លួនថាត្រូវទៅដេប៉ូណា គឺខ្លួនកាន់បុងទៅដេប៉ូនោះ។ នៅខាងផ្នែកខ្លួនមានគ្នាពីរនាក់គឺខ្លួន និងឈ្មោះ [redacted] ទូច ពេលប្រមូលប្រាក់បានហើយ ខ្លួនយកប្រាក់នោះទៅដាក់ចូលក្នុងគណនីធនាគារអេស៊ីលីដា និងធនាគារអេប៊ីអេ របស់លោកឧកញ៉ា [redacted] ហុង រួចហើយខ្លួនយកប័ណ្ណដាក់ប្រាក់ចូលក្នុងធនាគារ មកធ្វើរបាយការណ៍ជូនទៅផ្នែកចំណាយដែលមានឈ្មោះ [redacted] លក្ខិណា ជាអ្នកពិនិត្យ រួចទើបបញ្ជូនទៅប្រធានគណនេយ្យឈ្មោះ [redacted] រតនៈ ពិនិត្យ រួចហើយទើបបញ្ជូនទៅអ្នកគ្រប់គ្រងទូទៅឈ្មោះ [redacted] សាក់លី។ ចំពោះតែបៃតងអូរិលឈិ របស់ក្រុមហ៊ុន HSC Beverages គឺនៅគម្របដបមានរង្វាន់ តែចំពោះការប្តូរគម្របរង្វាន់របស់អតិថិជនមកក្រុមហ៊ុននោះ ខ្លួនមិនបានដឹងទេ ព្រោះមានផ្នែកផ្សេងជាអ្នកធ្វើ រីឯការបញ្ជាទិញផលិតផលខ្លួនមិនបានដឹងទេ។ ចំពោះក្រុមហ៊ុន HSC Beverages មានបញ្ហាអ្វីនោះខ្លួនមិនបានដឹងទេ តែខ្លួនបានដឹងថាមានសវនកម្មចុះមកត្រួតពិនិត្យក្រុមហ៊ុន HSC Beverages បានរយៈពេលប្រហែលមួយអាទិត្យ តែខ្លួនមិនដឹងថាអ្នកខាងណាចុះមកទេ ហើយខ្លួនក៏បានបញ្ជូនឯកសារដើម្បីឱ្យគេពិនិត្យដែរ។ បច្ចុប្បន្នខ្លួនធ្វើការធម្មតា ហើយខ្លួនមិនដឹងរឿងអ្វីផ្សេងទៀតទេ។

-សាក្សីឈ្មោះ [redacted] ទូច បានឆ្លើយថាៈ ខ្លួនបានចូលធ្វើការនៅក្នុងក្រុមហ៊ុន HSC Beverages កាលពីអំឡុងឆ្នាំ២០១៧ មានតួនាទីជាអ្នកប្រមូលប្រាក់ពីអតិថិជន។ ចំពោះការងាររបស់ខ្លួនគឺទទួលបន្ទុកដើរប្រមូល

ប្រាក់ពីអតិថិជនតាមដេប៉ូ នៅពេលដែលឈ្មោះ [redacted] ស្រីរើន ទម្លាក់បុងឱ្យមកខ្លួនថាត្រូវទៅដេប៉ូណា គឺខ្លួនកាន់បុងទៅដេប៉ូនោះ។ ពេលប្រមូលប្រាក់បានហើយ ខ្លួនបានយកប្រាក់នោះទៅដាក់នៅធនាគារ និងវេរទៅប្រទេសថៃ រួចហើយខ្លួនយកវិក័យប័ត្រទៅឱ្យឈ្មោះ [redacted] លក្ខិណា។ ពេលដែលយកបុងចូលនោះ គឺមិនទាន់កាត់រង្វាន់ទេ។ ខ្លួនមិនបានធ្វើការផ្ទាល់ជាមួយឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ទេ ហើយចំពោះការប្តូររង្វាន់ខ្លួនមិនបានដឹងទេ ចំណែករឿងបាត់លុយក៏ខ្លួនមិនបានដឹងដែរ។ ឈ្មោះ [redacted] សាក់លី ជាអ្នកបញ្ជាទិញផលិតផល តែខ្លួនមិនដឹងច្បាស់ទេថាអ្នកណាជាអ្នកសម្រេចចុងក្រោយនោះ។ ឈ្មោះ [redacted] រតនៈ ជាប្រធានគណនេយ្យ ចំណែកឈ្មោះ [redacted] ដេវីត ជាប្រធានគ្រប់គ្រង ខ្លួនមិនមានពាក់ព័ន្ធអ្វីជាមួយឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] សាក់លី នោះទេ។

-សាក្សីឈ្មោះ [redacted] ផាវ៉ា បានឆ្លើយថា: កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC មានតួនាទីជាអ្នកគ្រប់គ្រងស្តុកទំនិញ និងចេញបុងឥវ៉ាន់ឱ្យទៅអតិថិជនរបស់ក្រុមហ៊ុន ក្រោយមកខ្លួនបានប្តូរមកកាន់ផ្នែកគ្រប់គ្រងរង្វាន់តែបៃតង អូអិឈិ វិញ រហូតមកដល់បច្ចុប្បន្ននេះ។ នៅពេលដែលខ្លួនមានតួនាទីជាអ្នកគ្រប់គ្រងស្តុកទំនិញនោះ គឺខ្លួនគ្រាន់តែជាអ្នកទទួលបុងពីឈ្មោះ [redacted] ណា និងឈ្មោះ ធីតា នៅផ្នែកដឹកជញ្ជូនទំនិញក្រុមហ៊ុន HSC Beverages តាមការបញ្ជាទិញពីអតិថិជន។ ពេលពួកគាត់ដឹកផលិតផលនោះឱ្យទៅអតិថិជនរួច ទើបពួកគាត់យកបុងមកឱ្យខ្លួន ហើយខ្លួនយកបុងនោះមកគិតចេញជាប្រាក់ ហើយបញ្ជូនទៅឱ្យផ្នែកអេចអា (ផ្នែកទារប្រាក់) ដើម្បីដើរប្រមូលប្រាក់ពីអតិថិជន ដែលជំពាក់មកចូលក្រុមហ៊ុនវិញ។ ចំពោះអ្នកដែលទទួលការកម្ម៉ង់បញ្ជាទិញពីអតិថិជនគឺឈ្មោះ [redacted] គីមអេង តែគាត់ឈប់ធ្វើការយូរហើយ តាំងពីមុនពេលឈ្មោះ [redacted] សាក់លី ចូលធ្វើការម្ល៉េះ ក្រោយមកទើបឈ្មោះ [redacted] សុវណ្ណារ៉ា បានចូលមកធ្វើជំនួស តែគាត់បានឈប់ធ្វើការហើយ។ ចំពោះបុងដែលខ្លួនចេញហើយ មុននឹងបញ្ជូនទៅឱ្យផ្នែកទារលុយ គឺខ្លួនត្រូវបញ្ជូនទៅលោក [redacted] រតនៈ និងលោក [redacted] សាក់លី ដើម្បីពិនិត្យ និងចុះហត្ថលេខារួចបញ្ជូនមកខ្លួនវិញ ទើបខ្លួនបញ្ជូនបន្តទៅឱ្យផ្នែកទារលុយរបស់ក្រុមហ៊ុន។ ចំពោះរឿងរង្វាន់ គឺខាងទីផ្សារជាអ្នកផ្តល់រង្វាន់ដល់អតិថិជន គឺមានឈ្មោះ [redacted] យុទិត្យា ជាអ្នករៀបចំ រួចហើយទើបបញ្ជូនរបាយការណ៍មកខាងខ្លួន ហើយខ្លួនបានកាត់កងជាមួយនឹងផលិតផលដែលត្រូវដឹកឱ្យអតិថិជនរួចរាល់ហើយ ទើបបញ្ជូនឯកសារនេះទៅឱ្យឈ្មោះ [redacted] ស្រីរើន នៅផ្នែកទារប្រាក់របស់ក្រុមហ៊ុន។ ឈ្មោះ [redacted] រតនៈ មានតួនាទីជាប្រធានគណនេយ្យ ចំណែកឈ្មោះ [redacted] សាក់លី ជាអ្នកគ្រប់គ្រងទូទៅ (GM)។ រយៈចុងក្រោយខ្លួនបានចុះទៅជួយរាប់គម្របរង្វាន់នៅចុងឆ្នាំ២០១៨ តាមការណែនាំរបស់ក្រុមហ៊ុន ដើម្បីឱ្យដឹងថាតើអតិថិជនបានផ្ញើមកពិតប្រាកដឬអត់ ក្រោយពេលរាប់រួចហើយគឺយកទៅទុកនៅក្នុងឃ្លាំង ដោយមានឈ្មោះ [redacted] ឆោម ជាប្រធានឃ្លាំង ពេលរាប់នោះគ្រាន់តែបានរាប់ចំនួនបេទេ ពុំបានរាប់ចំនួនគម្របទាំងអស់ទេ ក្នុងមួយបេមាន៥០០កេស ហើយនៅក្នុងបេនោះគឺគេច្រកជាថង់ ដោយក្នុងមួយថង់មាន២២០គម្រប ប៉ុន្តែឈ្មោះ [redacted] ភាន់ ជាអ្នករាប់ជាក់ស្តែង ហើយនៅពេលមានការបាត់បង់គឺឈ្មោះ [redacted] ភាន់ គាត់ជាអ្នកនិយាយជាមួយអតិថិជន។ ទាក់ទងនឹងTO យោងទៅតាមការដឹកជញ្ជូន ដោយសារពេលខ្លះឃ្លាំងអស់ស្តុក ហើយនៅពេលដែលអតិថិជនគាត់ទំនាក់ទំនងមក គឺយើងកាត់កងនឹងគម្របរង្វាន់ ពេលខ្លះកាត់កងជា

10/3

ទំនិញ ពេលខ្លះកាត់កងជាទឹកលុយជូនគាត់វិញ ហើយយើងធ្វើរបាយការណ៍ឲ្យទៅឈ្មោះ [redacted] វតេន: ចុះហត្ថលេខា។ ក្រោយមកមានឈ្មោះ [redacted] វ័ត្ថន: បានចូលមកធ្វើការនៅក្នុងក្រុមហ៊ុន តែខ្លួនមិនដឹងថាគាត់កាន់ផ្នែកអ្វីទេ គ្រាន់តែដឹងថាទាក់ទងទៅនឹងផ្នែកតែបៃតងអូរិលឈិរបស់ក្រុមហ៊ុន ហើយក៏បានកោះហៅប្រជុំ និងឲ្យគ្រប់ផ្នែកធ្វើរបាយការណ៍ត្រៀមសវនកម្ម ព្រោះបញ្ជីក្រុមហ៊ុនមិនត្រឹមត្រូវ។ ក្រោយមកនៅក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៩ ខាងសវនកម្មបានចុះមកត្រួតពិនិត្យបានរយៈពេលជាងមួយអាទិត្យ តែមិនបានចប់ទេ ដោយសារលោក សម វតេន: និងលោក សុង សាក់លី មិននៅ ហើយចាប់ពីពេលនោះមកខ្លួនមិនដឹងរឿងអ្វីទៀតទេ គឺខ្លួនធ្វើការជាធម្មតារហូតមកដល់សព្វថ្ងៃ។

-សាក្សី [redacted] ដេវីត បានឆ្លើយថា: កាលអំឡុងឆ្នាំ២០១៦-២០១៧ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC TOBACCO មានតួនាទីជានាយកក្រុមហ៊ុន ខ្លួនបានចូលរួមធ្វើការងារ តែមិនជាប្រចាំទេ ភាគច្រើនខ្លួនធ្វើការនៅពេលព្រឹក ដោយខ្លួនជាប់មើលការងារនៅក្រុមហ៊ុនផ្សេងទៀត ហេតុនេះខ្លួនមកធ្វើការងារមិនជាប់លាប់ទេ។ នៅក្នុងក្រុមហ៊ុនខ្លួនមានតួនាទីជានាយកក្រុមហ៊ុន ,ឈ្មោះ [redacted] សាក់លី ជាអ្នកគ្រប់គ្រងទូទៅ (GM) និងឈ្មោះ [redacted] វតេន: ជាគណនេយ្យ។ ខ្លួនមានតួនាទីជាអ្នកសម្របសម្រួល និងជួយគាត់តែងលិខិតដើម្បីទទួលបានការបញ្ជាទិញ រៀបចំគោលការណ៍លក់ គំរោងបង្កើនការលក់ ចំណែកអ្នកប្រតិបត្តិការផ្ទាល់គឺលោក សុង សាក់លី អ្នកធ្វើបញ្ជីចំណាយចំណូលគឺខាងគណនេយ្យឈ្មោះ [redacted] វតេន:។ នៅក្នុងឆ្នាំ២០១៨ របាយការណ៍គណនេយ្យខ្លួនធ្លាប់ឃើញ ហើយរបាយការណ៍ចំណាយត្រូវបញ្ជូនទៅលោក [redacted] សាក់លី ផ្ទាល់ តែរបាយការណ៍ប្រចាំខែមិនបានឃើញរាល់ខែទេ។ ឈ្មោះ [redacted]តេន: ធ្វើការនៅក្រោមលោក [redacted] សាក់លី។ ការបញ្ជាទិញ និងការរៀបចំប្រចាំខែ ខ្លួនជាអ្នកទាក់ទងផ្ទាល់ជាមួយក្រុមហ៊ុននៅប្រទេសថៃ សម្រាប់ការលក់ និងការរៀបចំចែកចាយតាមដេប៉ូនៅតាមខេត្ត គឺលោក [redacted] សាក់លី ជាអ្នកទាក់ទងផ្ទាល់ ខ្លួនបានត្រួតពិនិត្យប្រចាំខែដូចជាមួយខែលក់បានប៉ុន្មាន។ នៅពេលដែលខាងដេប៉ូដែលជាអតិថិជនចែកចាយបន្តរោសជ្ជៈរបស់ក្រុមហ៊ុន HSC Beverages ត្រូវការបញ្ជាទិញផលិតផល ពួកគាត់បានធ្វើសំណើរមកខាងផ្នែកលក់របស់ក្រុមហ៊ុន ហើយជួនកាលគាត់បានធ្វើសំណើរទៅលោក [redacted] សាក់លី ដោយផ្ទាល់តែម្តង។ នៅពេលទទួលការបញ្ជាទិញផលិតផលពីដេប៉ូ ខាងផ្នែកគណនេយ្យដែលមានលោក [redacted] វតេន: ជាអ្នកធ្វើរបាយការណ៍មកលោក [redacted] សាក់លី រួចហើយទើបបញ្ជូនមកខ្លួនពិនិត្យតម្លៃទិញដែលមានស្រាប់ ហើយការផែកចំនួនត្រឹមត្រូវ ឬអត់ គឺផ្នែកលោក [redacted] វតេន:។ ក្រោយពីខ្លួនចុះហត្ថលេខារួចហើយ លោក [redacted] វតេន: មកយកឯកសារពីខ្លួន រួចបញ្ជូនទៅផ្នែកគណនេយ្យរបស់ក្រុមហ៊ុនធំ HSC ដែលមានអ្នកស្រី [redacted] គីមឡេង ជាប្រធាន រួចហើយទើបបញ្ជូនទៅប្រធានក្រុមហ៊ុនធំ HSC គឺលោកឧកញ៉ា [redacted] ហុង។ ក្នុងករណីដែលខាងក្រុមហ៊ុនមានផលិតផលអាចផ្គត់ផ្គង់ដល់ដេប៉ូបាន គឺលោក [redacted] សាក់លី បានចាត់ចែងឲ្យផ្នែកឃ្លាំងបញ្ជូនឲ្យទៅដេប៉ូវិញតែម្តង គឺមិនបានឆ្លងមកដល់ខ្លួនទេ។ ប៉ុន្តែក្នុងករណីដែលផលិតផលនៅក្នុងក្រុមហ៊ុនមិនអាចផ្គត់ផ្គង់តាមតម្រូវការខាងដេប៉ូបានទេ ទើបខាងគណនេយ្យលោក [redacted] វតេន: ធ្វើសំណើរទៅលោក [redacted] សាក់លី រួចបញ្ជូនមកដល់ខ្លួន ហើយខ្លួនបញ្ជូនទៅលោកស្រី [redacted] គីមឡេង រួចបញ្ជូនបន្តទៅប្រធានក្រុមហ៊ុនលោកឧកញ៉ា [redacted] ហុង ក្រោយពីលោកឧកញ៉ា



Scanned with CamScanner

[redacted] ហុង ចុះហត្ថលេខារួចហើយ ទើបបញ្ជូនទៅលោកស្រី [redacted] គីមឡេង វិញ រួចលោកស្រី [redacted] គីមឡេង បញ្ជូនទៅលោក [redacted] រតនៈ ដើម្បីបញ្ជូនបន្តទៅក្រុមហ៊ុននៅប្រទេសថៃឲ្យផ្តល់ផលិតផលមកក្រុមហ៊ុន ចំពោះការទូទាត់ប្រាក់ឲ្យទៅក្រុមហ៊ុននៅថៃ គឺវេរតាមធនាគារ ដោយប្រធានគណនេយ្យ [redacted] គីមឡេង ជាអ្នកចុះហត្ថលេខា បន្ទាប់មកប្រធានក្រុមហ៊ុនចុះហត្ថលេខា ដោយឈ្មោះ [redacted] រតនៈ ជាអ្នកចូលរួមដឹងឮពីការកម្ម៉ង់ដែរ។ ចំពោះការទូទាត់ប្រាក់នៅតាមដេប៉ូចូលក្រុមហ៊ុន គឺខាងគណនេយ្យក្រុមហ៊ុនជាអ្នកធ្វើរបាយការណ៍ ហើយចំពោះរបាយការណ៍ចំណូល និងចំណាយប្រចាំខែ គឺតម្កល់នៅខាងគណនេយ្យក្រុមហ៊ុន។ ភេសជ្ជៈអូអិឈិ គឺមានរង្វាន់នៅគម្របដប ហើយនៅពេលដែលអតិថិជននៅតាមដេប៉ូប្តូរគម្របរង្វាន់ គឺគេបញ្ជូនចូលមកឃ្លាំង ហើយខាងលោក [redacted] រតនៈ ជាគណនេយ្យ បានធ្វើរបាយការណ៍ឡើងទៅលោក [redacted] សាក់លី រួចក៏ធ្វើការទូទាត់រង្វាន់ជាមួយដេប៉ូតែម្តង មិនបានឆ្លងកាត់មកខ្លួនទេ។ ចំពោះគម្របរង្វាន់ដែលដេប៉ូបញ្ជូនមក ត្រូវបានរក្សាទុកនៅក្នុងឃ្លាំង ដោយមានឈ្មោះ សូនី នៅផ្នែកទីផ្សាររៀបចំរបាយការណ៍ ដើម្បីបញ្ជូនទៅក្រុមហ៊ុននៅប្រទេសថៃ តែខ្លួនមិនដឹងថាអ្នកណាជាអ្នកបញ្ជូនទៅទេ ខ្លួនគ្រាន់តែដឹងថារបាយការណ៍នេះមិនបានឆ្លងកាត់មកខ្លួនទេ។ ចំពោះលោក [redacted] សាក់លី គាត់អាចបញ្ជាទិញផលិតផលភេសជ្ជៈពីប្រទេសថៃចូលមកក្រុមហ៊ុនផ្ទាល់បានឬអត់នោះខ្លួនមិនដឹងទេ តែមានពេលខ្លះពេលដែលក្រុមហ៊ុនត្រូវការផលិតផលដើម្បីផ្គត់ផ្គង់ឲ្យទៅដេប៉ូ គាត់បានឲ្យខ្លួនទូរស័ព្ទទៅក្រុមហ៊ុននៅថៃបញ្ជូនមកក្រុមហ៊ុន តែនៅពេលដែលខ្លួនមិនបាននៅក្នុងប្រទេសកម្ពុជា ខ្លួនជឿថាគាត់អាចបញ្ជាទិញដោយខ្លួនឯងបានព្រោះនៅប្រទេសថៃក៏គេស្គាល់គាត់ដែរ។ ក្រោយពីបញ្ជាទិញផលិតផលរួចហើយ ទើបលោក [redacted] សាក់លី ធ្វើសំណើរទៅប្រធានក្រុមហ៊ុន ដើម្បីធ្វើការទូទាត់ប្រាក់ឲ្យទៅក្រុមហ៊ុននៅប្រទេសថៃវិញ។ ពេលមានបញ្ហានៅឆ្នាំ២០១៩ ខ្លួនដឹង ព្រោះតួលេខនៅថៃ និងនៅខ្មែរមិនដូចគ្នា ទាំងភាគីថៃ និងភាគីខ្មែរមានការចាប់អារម្មណ៍នឹងគម្របដបប្តូររង្វាន់។ ក្រុមហ៊ុននៅខ្មែរប្រមូលគម្របដបទៅឃ្លាំង ក្រោយមកក៏មានគម្របខុសគ្នាជាមួយនឹងគម្របនៅថៃ ដោយសារគម្របនៅខ្មែរច្រើនជាង ហើយជួនកាលក៏មានបុគ្គលិកនៅថៃចុះមកចាប់ ដោយសារមានចំនួនច្រើនពេក ចំនួនមិនស្មើគ្នា មិនប្រហាក់ប្រហែលគ្នា ខ្លួនដឹងថាមានភាពមិនស្មើគ្នានៅអំឡុងឆ្នាំ២០១៨ តែខ្លួនមិនដឹងពីចំនួនដែលខុសគ្នានោះច្បាស់លាស់ទេ។ ដោយសារខាងគណនេយ្យក្រុមហ៊ុន គឺលោកស្រី [redacted] គីមឡេង មានការសង្ស័យថា ខាងគណនេយ្យក្រុមហ៊ុនធ្វើអ្វីមិនច្បាស់លាស់ មានបញ្ហា ដោយខ្លួនមិនមានជំនាញផ្នែកគណនេយ្យ ដូចនេះខ្លួនមិនបានដឹងទេ ខ្លួនមានតួនាទីពិនិត្យទៅលើផែនការផ្សេងៗ និងលក់ទៅតាមផែនការរបស់ក្រុមហ៊ុនប៉ុណ្ណោះ ហើយលោកស្រី [redacted] គីមឡេង បានរាយការណ៍ទៅប្រធានក្រុមហ៊ុន ហើយប្រធានក្រុមហ៊ុនបានឲ្យខ្លួនត្រួតពិនិត្យឡើងវិញ។ តែដោយសារខ្លួនគ្មានជំនាញនេះ ខ្លួនក៏ស្នើសុំទៅប្រធានក្រុមហ៊ុនឲ្យចាត់លោកស្រី [redacted] រ័ត្នៈ ដើម្បីឲ្យជួយមើលនៅផ្នែកគណនេយ្យ ហើយក្រុមហ៊ុនបានចាត់លោកស្រី [redacted] រ័ត្នៈ ចុះមកត្រួតពិនិត្យផ្នែកគណនេយ្យទៅវិញ។ ដោយពិនិត្យមើលរបាយការណ៍ផ្នែកគណនេយ្យឃើញថា មានបញ្ហាទៅលើការប្តូរគម្របរង្វាន់ និងការចំណូល-ការចំណាយខុសនឹងឯកសារជាក់ស្តែង ពេលនោះលោកស្រី [redacted] រ័ត្នៈ បានឲ្យលោក [redacted] សាក់លី និងលោក [redacted] រតនៈ ធ្វើរបាយការណ៍ឲ្យគាត់ ហើយលោកស្រី [redacted] រ័ត្នៈ បានឲ្យខ្លួនជួយត្រួតពិនិត្យឯកសារទាំងនោះ ខ្លួនឃើញមាន

បញ្ហាជាច្រើន ដូចជាការប្រមូលគម្រូបរង្វាន់ពីដេប៉ូបានតិច ហើយផ្តល់រង្វាន់ទៅឱ្យដេប៉ូវិញច្រើនលើសពីការពិត ដែលធ្វើឱ្យក្រុមហ៊ុនខាតប្រាក់ច្រើន និងមានការបញ្ហាទិញពីដេប៉ូ ហើយខាងគាត់បានបញ្ជូនផលិតផលទៅឱ្យដេប៉ូវិញ តែគាត់មិនបានបញ្ចូលវិក័យប័ត្រទូទាត់ប្រាក់ទៅឱ្យដេប៉ូទេ ព្រោះពុំមានឯកសារតម្កល់នៅក្រុមហ៊ុន។ ខ្លួនបានចុះហត្ថលេខាលើរបាយការណ៍នោះ ដោយសរសេរថាឯកសារនោះ ជាកម្មវត្ថុសម្រាប់ធ្វើសវនកម្ម។ ក្រោយមកក្រុមហ៊ុនបានប្រជុំដើម្បីត្រៀមធ្វើសវនកម្ម លុះដល់ថ្ងៃកំណត់ធ្វើសវនកម្ម ស្រាប់តែលោក [redacted] សាក់លី និងលោក [redacted] រតនៈ មិនបានចូលរួមទេ។ ចំពោះលទ្ធផលផ្លូវការរបស់សវនកម្ម ខ្លួនមិនបានដឹងទេ ដោយខ្លួនបានចូលនិវត្តន៍នៅឆ្នាំ២០១៩។

-សាក្សីឈ្មោះ [redacted] រ័ត្នឧ: បានឆ្លើយថា: កាលពីអំឡុងពីខែកញ្ញា ឆ្នាំ២០១៦ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC TOBACCO មានតួនាទីជាអ្នកគ្រប់គ្រងទូទៅ (GM)។ នៅថ្ងៃ១៨ ខែមេសា ឆ្នាំ២០១៩ ក្រុមហ៊ុនបានឱ្យខ្លួនមកកាន់ផ្នែកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន HSC ជំនួសលោក [redacted] សាក់លី បន្ថែមលើមុខងារចាស់របស់ខ្លួនទៀត ហើយក្រុមហ៊ុនត្រូវចាត់លោក [redacted] សាក់លី ទៅកាន់ផ្នែកគម្រោងរបស់ក្រុមហ៊ុន HSC វិញ។ នៅពេលដែលខ្លួនមកធ្វើការនៅទីនេះ ខ្លួនបានមើលរបាយការណ៍គណនេយ្យឃើញថា មានរបាយការណ៍ជាង ១,000,000$ (មួយលានដុល្លារអាមេរិក) តែពុំមានផលិតផលភេសជ្ជៈក្នុងឃ្លាំងទេ។ ខ្លួនបានសួរទៅខាងឃ្លាំងរបស់ក្រុមហ៊ុននៅអូរស្មាច់ និងឃ្លាំងនៅបាត់ដំបង ពួកគាត់ថាអត់មានឥវ៉ាន់នៅក្នុងឃ្លាំងទេ។ លុះពីរថ្ងៃក្រោយមកខាងឃ្លាំងនៅខាងបាត់ដំបងបានប្រាប់មកវិញថា ឃ្លាំងរបស់គាត់មានអីវ៉ាន់ប្រហែលជា ៨0,000 (ប្រាំបីម៉ឺន) កេស ហើយលក់អស់ប្រហែល ៦0,000 (ប្រាំមួយម៉ឺន) កេស នៅសល់ប្រហែល ២0,000 (ពីរម៉ឺន) កេស នៅក្នុងឃ្លាំង។ ខ្លួនបានជម្រាបទៅលោកអគ្គនាយក ហើយលោកអគ្គនាយកបានឱ្យលោក [redacted] រតនៈ ,លោក [redacted] សាក់លី និងលោក [redacted] ដេវីត បិទបញ្ជីឱ្យគាត់ តើប្រាក់នៅសល់ប៉ុន្មាន និងចំណេញបានប៉ុន្មាន ដោយគិតចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០១៩ ប៉ុន្តែរបាយការណ៍បិទបញ្ជីរបស់ពួកគាត់ធ្វើឬនដង ដោយតួលេខប្រែប្រួលរហូត ហើយពួកគាត់បែរជាបិទបញ្ជីឆ្នាំ២០១៧ ទៅវិញ។ នៅខែឧសភា គាត់បានភ្លេចចេញវិក័យប័ត្រទារលុយចំនួន៤0ម៉ឺនដុល្លារជាង ពេលយើងរកឃើញ គឺគាត់បានដូររបាយការណ៍ដេប៉ូជាច្រើនដែលជាក្រុមគ្រួសាររបស់លោក [redacted] សាក់លី មានឪពុកក្មេកគាត់ដេប៉ូធំនៅខេត្តកំពង់ចាម ប្រពន្ធគាត់ដេប៉ូធំនៅភ្នំពេញ និងបងថ្លៃគាត់ដេប៉ូធំនៅខេត្តកណ្តាល។ ខ្លួនបានមើលរបាយការណ៍បិទបញ្ជីរបស់ពួកគាត់ ឃើញថាមានបញ្ហាទៅលើផ្នែកគម្របរង្វាន់ដែលត្រូវបើកឱ្យអតិថិជនវិញ គឺការប្រមូលរង្វាន់ពីខាងដេប៉ូមកបានតិចប្រហែលជា ១,៥៤0,000 (មួយលានប្រាំសែនប្រាំបួនម៉ឺន) កេស ហើយរបាយការណ៍ផ្តល់រង្វាន់ទៅវិញច្រើនលើសរហូតទៅដល់ជាង ៨៦,000 (ប្រាំបីម៉ឺនប្រាំមួយពាន់) កេស។ ការខុសមួយទៀត គឺខុសទៅលើវិកយប័ត្រលក់ឥវ៉ាន់ ដោយពួកគាត់លុបចោលវិក័យប័ត្របញ្ជាទិញពីអតិថិជនតាមដេប៉ូ ដែលមានទឹកប្រាក់សរុប ៧៨៤,000$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់ដុល្លារអាមេរិក) គិតក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ចំណុចនេះ ពួកគាត់បានអះអាងថា សម្រាប់ធ្វើការទូទាត់ជាមួយគម្របរង្វាន់ឱ្យទៅអតិថិជន តែពួកគាត់មិនមានឯកសារណាមួយមកបញ្ជាក់ឡើយ។ ចំពោះរបាយការណ៍បិទបញ្ជី លោក [redacted] រតនៈ គាត់ជាអ្នកធ្វើ ហើយចុះហត្ថលេខាដោយលោក [redacted] រតនៈ ,លោក [redacted] សាក់លី

និងលោក [redacted] ដេវីត តែលោក [redacted] ដេវីត បានចារនៅខាងក្រោមថា សម្រាប់ធ្វើសវនកម្ម។ ដោយសារតែមានបញ្ហាបែបនេះ ទើបប្រធានក្រុមហ៊ុនបានឱ្យធ្វើសវនកម្មឡើងវិញ ដោយក្រុមហ៊ុនសម្រេចយកក្រុមហ៊ុនអង្គរចុះមកសវនកម្ម ហើយបានជូនដំណឹងទៅលោក [redacted] សាក់លី ,លោក [redacted] ដេវីត និងលោក [redacted] រតនៈ ឱ្យផ្ដល់ឯកសារសម្រាប់សវនកម្ម តែដល់ពេលកំណត់ពួកគាត់មិនបានផ្ដល់ឯកសារ ពេលនោះគឺគាត់មកធ្វើការធម្មតា ពេលអូឌីតមកបានរកឃើញមានបញ្ហាច្រើនជាងខ្លួន បញ្ហាខ្លាំងនោះគឺគាត់បិទបញ្ជីពីឆ្នាំ២០១៧-២០១៨ មុនពេលដែលខ្លួនចូល ដើម្បីទទួលបានប្រាក់អូធីពីក្រុមហ៊ុនចំនួន៥% តែគាត់ភ្លេចបុងទារលុយភ្ញៀវ៤០ម៉ឺនជាង ខ្លួនក៏បានប្រាប់គាត់ថា ខាងក្រុមអូឌីតទារឯកសារ ពេលនោះគាត់ក៏ឈប់មកធ្វើការ ពីរបីថ្ងៃក្រោយមកទើបមានឯកសារមកឱ្យក្រុមហ៊ុនតាមរយៈមេធាវី។ គាត់ភ្លេចទារលុយភ្ញៀវជាង៤០ម៉ឺននោះ គឺនៅដេប៉ូក្រុមគ្រួសាររបស់គាត់ ហើយក្រោយមកគាត់បានមកជួបខ្លួន ហើយគាត់បានសងរួចរាល់អស់ហើយ តែក្រោយមកស្រាប់តែរកឃើញប្រហែល២០ ទៅ៣០ម៉ឺនទៀត។ ទាក់ទងនឹងការចំណាយការបញ្ចុះទិញ ក្រុមហ៊ុនបានចេញវិក័យប័ត្រឱ្យភ្ញៀវរួចហើយ តែគាត់បានធ្វើវិក័យប័ត្រដល់ ៧៨៤,៣១៦$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់បីរយដប់ប្រាំមួយដុល្លារអាមេរិក) ក្នុងមួយខែ (ខែកុម្ភៈ) ខ្លួនក៏បានសួរទៅគាត់ គាត់ប្រាប់ថា នេះជាការកាត់គម្រូបសងអតិថិជន តែគាត់មិនមានឯកសារនោះទេ។ ចំពោះការបញ្ចុះទិញទំនិញនៅថៃ យើងតែងតែបង់លុយមុន១០០% តែពេលដែលមានបញ្ហាស្រាប់តែខាងថៃបានប្រាប់ថា យើងនៅជំពាក់គេជាង៧០ម៉ឺនដុល្លារអាមេរិក ពេលនោះទើបអគ្គនាយកសុំឱ្យធ្វើសវនកម្មបន្ទាន់ទៅលើស្តុកនៅអូរស្មាច់ និងខ្សែម។ ពេលដែលក្រុមហ៊ុនអង្គរចុះធ្វើសវនកម្មបានហៅគាត់ឱ្យមកចូលរួមតែគាត់មិនមក ខាងក្រុមហ៊ុនអង្គរមិនអាចធ្វើការបានទេបើគ្មានពួកគាត់មកចូលរួម ទើបយើងរកក្រុមហ៊ុនសវនករថ្មី គឺក្រុមហ៊ុន អេច អេស ស៊ី ហើយលទ្ធផលនៃសវនកម្មបានរកឃើញច្រើនជាងខ្លួនរកឃើញទៅទៀត សវនកម្មបានរកឃើញថា: ១-លំអៀងសាច់ប្រាក់ បាត-ដុល្លារ ២១៦,៥២៤.៧៧$ (ពីរសែនមួយម៉ឺនប្រាំមួយពាន់ប្រាំរយម្ភៃបួនដុល្លារអាមេរិក និងចិតសិបប្រាំពីរសេន) មិនបានកត់ត្រាចូលស៊ីស្ទឹម , ២-ឃើញមានការកត់ត្រាមួយ ដោយដាក់ថាការកត់ត្រាទទួលប្រាក់ដែលធ្វើការនិយ័តកម្ម តែមិនមានឯកសារទេ គឺមានចំនួន ៧៨,០០០$ (ប្រាំពីរម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ,៣-រកឃើញCredit Notes (ប័ណ្ណឥណទាន) ចំនួន២២ប័ណ្ណ ដែលមានទឹកប្រាក់ចំនួន ៨១៤,៦១៨$ (ប្រាំបីសែនមួយម៉ឺនបួនពាន់ប្រាំមួយរយដប់ប្រាំបីដុល្លារអាមេរិក) ដែលមិនមានឯកសារ ឬមូលដ្ឋានគាំទ្រគ្រប់គ្រាន់ សម្រាប់ឥណទានទាំងនេះទៅអតិថិជន ,៤-ការដូរគម្របរង្វាន់រកឃើញដល់ ២៨៣,២៤៣ (ពីរសែនប្រាំបីម៉ឺនបីពាន់ពីររយសែសិបបី) កេស គិតជាលុយមានចំនួន ២,៧១៩,១៣៧.១២$ (ពីរលានប្រាំពីរសែនមួយម៉ឺនប្រាំបួនពាន់មួយរយសាមសិបប្រាំពីរដុល្លារអាមេរិក និងដប់ពីរសេន) ចំណុចមួយទៀតនោះ គឺការធ្វើនិយ័តកម្មមានចំនួនច្រើន ហើយក្រុមហ៊ុនបានបាត់បង់លុយប្រហែល ៣.៨ លានដុល្លារ។ ការធ្វើសវនកម្មថ្មីនេះ គឺអត់មានការចូលរួមពីឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ទេ។ ចំពោះគម្របរង្វាន់ គឺមានកូនចៅគាត់ម្នាក់ជាអ្នកមើលការខុសត្រូវ ហើយរយៈពេល០១ខែ ទៅ០២ខែ គាត់បំផ្លាញចោលម្តង ដោយមានការចូលរួមពីភាគីថៃមកពិនិត្យគម្របដប។ ចំពោះការលំអៀងអត្រាប្តូរប្រាក់នៃការបញ្ចុះទិញទំនិញអតិថិជនឱ្យជាប្រាក់រៀល និងដុល្លារ តែក្រុមហ៊ុនកំណត់ជាប្រាក់ដុល្លារ ខាង

សវនករកឃើញមានភាពលំអៀង ដោយលុយភាគច្រើនអត់ដែលចូលក្រុមហ៊ុនទេ ពេលប្តូរប្រាក់ម្តងៗម្ចាស់អគ្រាប្តូរប្រាក់គេមានសរសេរនៅលើក្រដាសនឹងហើយ ជាធម្មតាប្រាក់ចំណេញ ឬខាតយើងមានគណនេយ្យរបស់ក្រុមហ៊ុនធ្វើការកត់ត្រា។ ពេលជួលក្រុមសវនករអង្គរមក ខ្លួនមិនដឹងថាអស់ប៉ុន្មានទេ ចំណែកសវនករលើកក្រោយនេះអស់ប្រហែល២ម៉ឺនដុល្លារអាមេរិក។

-សាក្សីឈ្មោះ [redacted] ដារិទ្ធ ជាសវនករ បានឆ្លើយថា: ក្រុមហ៊ុនខ្លួនបានបង្កើតឡើងនៅឆ្នាំ២០១១ ដោយបានទទួលអាជ្ញាប័ណ្ណគ្រប់គ្រាន់។ នៅពេលចុះសវនកម្មនៅក្រុមហ៊ុន HSC Beverages នោះមានគ្នា០៥នាក់ មានឈ្មោះ [redacted] ធីតា ជាអ្នកដឹកនាំ យើងបានធ្វើការត្រួតពិនិត្យទៅលើបញ្ជីស្នាមចំនួន០៤ធំមាន: ១-វិធីលក់ ឬវដ្តនៃការលក់ និងការប្រមូលសាច់ប្រាក់ ,២-ការទិញ និងការបង់លុយ ,៣-ការចងទំនិញ ការចេញទំនិញ និងទំនិញដែលនៅសល់ និង៤-ការចំណាយទៅលើការលក់ យើងបានត្រួតពិនិត្យចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ គឺមានរយៈពេល២៩ខែ។ ពេលដែលពួកខ្លួនចុះអូឌីត បុគ្គលិកមួយចំនួនបានឈប់អស់ ឯកសារដើមខ្វះខាតច្រើន។ ភស្តុតាងដែលរកឃើញគឺមាន វដ្តនៃការលក់ទទួលស្គាល់ការលក់ ក្រុមហ៊ុនគាត់រកស៊ីកត់ត្រាជាប្រាក់ដុល្លារ និងឃើញប្រមូលលុយជាពីរប្រភេទ ហើយឃើញមានលុយក្នុងធនាគារចំនួន ១១៣,០០០$ (មួយសែនមួយម៉ឺនបីពាន់ដុល្លារអាមេរិក) ខុសគ្នាពីចំនួនប្រាក់នៅក្នុងដៃ តែមិនឃើញមានចុះភាពលំអៀងទេ។ ចំពោះការលក់ ឃើញមានប្រតិបត្តិការមិនប្រក្រតី ការកត់ត្រាមានលុយថយចុះចំនួន ៧៨,០២៨$ (ប្រាំពីរម៉ឺនប្រាំបីពាន់ម្ភៃប្រាំបីដុល្លារអាមេរិក) តែអត់មានឯកសារភស្តុតាងទេ ចំពោះវដ្តនៃការលក់ ឃើញមានប័ណ្ណឥណទានច្រើន ឃើញមានការកាត់បន្ថយរបស់អតិថិជន ហើយការដូររង្វាន់គម្របដបគាត់មានឯកសារគាំទ្រ។ យើងបានផ្ទៀងផ្ទាត់ឃើញមានភាពលំអៀង គឺការដូររង្វាន់គម្របដបឱ្យអតិថិជនច្រើនជាងរង្វាន់ដែលមានឯកសារទទួលពីអតិថិជនគឺមាន ១.៥លាន តែបញ្ជីឃើញមាន ១.៨លាន ស្មើនឹង ២៨៣,២៤៣.២៥ (ពីរសែនប្រាំបីម៉ឺនបីពាន់ពីររយសែសិបបីក្បៀសម្ភៃប្រាំ) កេស និងឃើញមានឯកសារមួយទៀត គឺឯកសារផ្ទៃក្នុងឃើញមានគំលាត ២៦១,០០០ (ពីរសែនប្រាំមួយម៉ឺនមួយពាន់) កេស។ ខាងក្រុមហ៊ុនបានប្រាប់ថារង្វាន់ខាងរោងចក្រចេញ គឺមានផ្ទៀងផ្ទាត់ជាមួយក្រុមហ៊ុន ហើយយើងក៏បានផ្ទៀងផ្ទាត់ទៅឃើញមានភាពលំអៀងជាង២០ម៉ឺនកេស មិនដឹងដោយសារអ្វីទេ ចំណុចចុងក្រោយនោះគឺ របាយការណ៍លក់យើងឃើញមានការកត់ត្រាដោះដូរជាមួយថ្លៃដើម កត់ត្រាមិនត្រូវបច្ចេកទេស មិនមានការថយចុះ មិនមានការខាតបង់។ ពីរចំណុច យើងរកអត់ឃើញមានការបាត់បង់សាច់ប្រាក់ទេ ដោយសារខ្វះឯកសារច្បាប់ដើម ខ្វះការបកស្រាយ យើងអត់បានបញ្ជាក់ជាមួយអ្នកលក់ (គាត់អត់បានកែរបាយការណ៍ យើងអត់ដឹងបាត់បង់ប៉ុន្មាននោះទេ គ្រាន់តែរកឃើញលំអៀង)។ ក្រុមហ៊ុនខ្លួនធ្វើការអត់មានការចូលរួមពីអតិថិជនទេ ក្រុមហ៊ុនខ្លួនពុំមានជាប់សាច់ញាតិជាមួយប្រធានក្រុមហ៊ុន HSC Beverages ទេ ហើយក្រុមហ៊ុនខ្លួនក៏គ្មានទំនាស់ជាមួយឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ដែរ ក្រុមហ៊ុនខ្លួនមិនមានភាពលំអៀងទៅខាងណាទេ។ អ្នកដែលអនុវត្តសវនករមានរូបខ្លួន ដឹកនាំដោយឈ្មោះ [redacted] ធីតា ដែលមានបទពិសោធន៍០៥ឆ្នាំមកហើយ ,ឈ្មោះ វត្តី ,ឈ្មោះ [redacted] សែមេសា ,ឈ្មោះ [redacted] ស្រីនាង និងឈ្មោះ [redacted] កុលធីតា ពួកគាត់ធ្វើជាបុគ្គលិកយ៉ាងតិច២ឆ្នាំ មានក្រមសីលធម៌

បរិញ្ញាប័ត្រ ហើយលោក [redacted] ហុង ជាអ្នកបង់ថ្លៃសេវាសវនករឱ្យក្រុមហ៊ុនខ្លួន របាយការណ៍ដែលខ្លួនចេញនេះ គឺស្តង់ដារ អ្វីដែលបានរកឃើញបង្ហាញពីតម្លាភាព ខ្លួនមិនបានរកឃើញការបាត់បង់ណាមួយទេ គ្រាន់តែឃើញការលំអៀង។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: កាលពីចុងឆ្នាំ២០១៦ ខ្លួនបានបង្កើតក្រុមហ៊ុន ឈ្មោះ យ៉ូកុ បេវើរេច ខេមបូឌា តែម្នាក់ឯងទេ ដោយខ្លួនមានឡាយសិនត្រឹមត្រូវ សម្រាប់នាំចូលតែបៃតង អូរិឈិ ពីប្រទេសថៃ មកចែកចាយក្នុងស្រុក។ លុះមកដល់ខែមីនា ឆ្នាំ២០១៧ ដោយសារខ្លួនខ្វះដើមទុន ខ្លួនក៏បានប្រគល់ឡាយសិននេះឱ្យទៅលោកឧកញ៉ា [redacted] ហុង ជាប្រធានក្រុមហ៊ុន ហើយគាត់ឱ្យខ្លួនធ្វើការក្នុងក្រុមហ៊ុនរបស់គាត់ ដោយទទួលបានប្រាក់ខែ ៣,០០០$ (បីពាន់ដុល្លារអាមេរិក) ក្នុងមួយខែ និងបន្ថែមប្រាក់ចំណេញ៥% ក្នុងមួយឆ្នាំ។ ខ្លួនមានតួនាទីជាប្រធានទីផ្សារ ឈ្មោះ [redacted] ដេវីត ជាជនជាតិសាំងហ្គាពួរ ជានាយកក្រុមហ៊ុន ហើយមានលោកស្រី [redacted] គឹមឡេង ជាប្រធានគណនេយ្យក្រុមហ៊ុន។ លុះមកដល់ខែឧសភា ឆ្នាំ២០១៧ ដោយសារឯកសារក្នុងក្រុមហ៊ុនមានភាពច្របូកច្របល់ ក្រុមហ៊ុនរបស់លោកឧកញ៉ា [redacted] ហុង បានឱ្យខ្លួនធ្វើជាអ្នកគ្រប់គ្រងទូទៅ ឯឈ្មោះ [redacted] ដេវីត ជានាយកក្រុមហ៊ុន ហើយលោកស្រី [redacted] គឹមឡេង ជាអ្នកគ្រប់គ្រងគណនេយ្យរបស់ក្រុមហ៊ុន HSC Beverages ដដែល។ ខ្លួនមានតួនាទីមើលការខុសត្រូវក្រុមហ៊ុន ដូចជាការបញ្ជាទិញផលិតផលអូរិឈិ ពីក្រុមហ៊ុននៅប្រទេសថៃ ដើម្បីយកមកចែកចាយក្នុងស្រុក ហើយកូនចៅខ្លួនឈ្មោះ [redacted] លក្ខិណា ភេទស្រី (Account Payable) ជាអ្នកធ្វើរបាយការណ៍មកខ្លួន ហើយខ្លួនជាអ្នកត្រួតពិនិត្យឯកសារនេះ រួចទើបចុះហត្ថលេខាបញ្ជូនទៅលោក [redacted] ដេវីត ពិនិត្យបន្ត រួចហើយទើបចុះហត្ថលេខាបញ្ជូនទៅលោកស្រី [redacted] គឹមឡេង ពិនិត្យ រួចទើបបញ្ជូនទៅលោកឧកញ៉ា [redacted] ហុង ចុះហត្ថលេខា និងចេញមូលប្បទានប័ត្រ បន្ទាប់មកប្រគល់ទៅឱ្យលោកស្រី [redacted] គឹមឡេង ហើយបញ្ជូនទៅឈ្មោះ [redacted] លក្ខិណា ទើបចាត់ឱ្យឈ្មោះ [redacted] ទូច និងឈ្មោះ [redacted] សុភ័ក្រ្ត មានតួនាទីជាអ្នកប្រមូលប្រាក់ឱ្យក្រុមហ៊ុនយកទៅកន្លែងវេរប្រាក់នៅអូឡាំពិច ដើម្បីវេរទៅក្រុមហ៊ុននៅប្រទេសថៃ ហើយចាប់ពីខែកុម្ភៈ ឆ្នាំ២០១៨ មក រាល់ការវេរប្រាក់ទៅក្រៅប្រទេសគឺធ្វើតាមរយៈធនាគារវិញ។ នៅពេលដែលក្រុមហ៊ុននៅប្រទេសថៃបញ្ជូនឥវ៉ាន់មកវិញតាមផ្លូវគោករហើយ គឺបានយកទៅចែកចាយតាមដេប៉ូក្នុងស្រុកតែម្តង ទើបយកបុងមកទូទាត់ឱ្យក្រុមហ៊ុន។ ចំពោះភេសជ្ជៈអូរិឈិនេះ គឺមានរង្វាន់នៅគម្របដបមានរង្វាន់ជាច្រើនដែលធំជាងគេគឺរថយន្តម៉ាកហ្វតរ៉េនជ័រ ហើយរង្វាន់តូចៗដែលអតិថិជនត្រូវអាចបើកបាននៅដេប៉ូគ្រប់ខេត្តក្រុង រួចហើយទើបខាងទីផ្សារ និងឃ្លាំងធ្វើរបាយការណ៍ចូលមកគណនេយ្យ ដែលមានឈ្មោះ [redacted] ស្រីរ៉េន ជាអ្នកទារប្រាក់ពីដេប៉ូដែលជំពាក់ក្រុមហ៊ុន និងទូទាត់រង្វាន់ជាមួយដេប៉ូ ដើម្បីកាត់ប្រាក់ជំពាក់ជាមួយរង្វាន់នោះ ហើយចំពោះរង្វាន់ធំៗដូចជា ម៉ូតូ និងឡាន គឺក្រុមហ៊ុនចុះចែកដល់ផ្ទះ។ ចំពោះគម្របរង្វាន់ទាំងអស់ដែលចូលមកក្រុមហ៊ុនរួចហើយ រយៈពេលមួយខែទើបធ្វើការទូទាត់ទៅរោងចក្រប្រទេសថៃម្តង ហើយបើរង្វាន់ច្រើនពេកអាចមួយខែពីរដង។ ចំពោះសំណើរទៅរោងចក្រដើម្បីទូទាត់នោះ គឺកូនចៅខ្លួនជាអ្នកធ្វើបញ្ជីសរុបមកឱ្យខ្លួន ហើយខ្លួនក៏ចុះហត្ថលេខាបញ្ជូនទៅរោងចក្រ ទើបខ្លួនរាយការណ៍ទៅលោក [redacted] ដេវីត ឱ្យ

គាត់បានដឹង វង្វាន់ពេលនោះអាចមានពីមួយម៉ឺនទៅពីរម៉ឺនកេសតែប៉ុណ្ណោះ ក្នុងពេលផ្ញើទៅម្តងៗ។ កាលពីខែមីនា ឆ្នាំ២០១៧ រហូតដល់ខែឧសភា ឆ្នាំ២០១៧ ពេលដែលលោកស្រី [redacted] គឹមឡេង នៅជាប្រធានគណនេយ្យនោះ គាត់មិនបានធ្វើបញ្ជីចំណូលចំណាយប្រចាំខែ (បិទបញ្ជីប្រចាំខែ) ឱ្យបានត្រឹមត្រូវនោះទេ គឺរាល់បញ្ជីដែលផ្នែកផ្សេងៗប្រគល់ឱ្យទៅលោកស្រី [redacted] គឹមឡេង គាត់បានយកទៅរក្សាទុកតែម្តង។ ដោយសារពុំមានភាពច្បាស់លាស់ចាប់ពីខែឧសភា ឆ្នាំ២០១៧ មក លោក [redacted] ហុង ក៏បានប្រគល់ការងារបូកសរុបបញ្ជីចំណូលចំណាយផ្នែកតែបៃតង អូរិលឈិ ឱ្យមកលោក [redacted] ដេវីត និងខ្លួនជាអ្នកធ្វើវិញម្តង រីឯផ្នែកផ្សេងៗ គឺគាត់ជាអ្នកធ្វើដដែល។ ពេលនោះខ្លួនត្រូវរៀបចំបញ្ជីចំណូលចំណាយ ចាប់ពីខែមីនា ឆ្នាំ២០១៧ ឡើងវិញទាំងអស់ គឺធ្វើតែតាមឯកសារដែលលោកស្រី [redacted] គឹមឡេង ប្រគល់ឱ្យ រួចហើយតម្កល់ទុកក្នុងក្រុមហ៊ុនតែម្តង ពេលនោះខាងផ្នែកខ្លួន និងលោក [redacted] ដេវីត នេះ មិនទាន់មានប្រធានគណនេយ្យទេ។ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ ឈ្មោះ [redacted] រតន: បានចូលមកធ្វើជាប្រធានគណនេយ្យផ្នែកភេសជ្ជៈតែបៃតងអូរិលឈិ ឯប្រធានផ្នែកគណនេយ្យរួមរបស់ក្រុមហ៊ុន គឺលោកស្រី [redacted] គឹមឡេង ក្រោមការគ្រប់គ្រងពីឈ្មោះ [redacted] ដេវីត ដែរ ពេលឈ្មោះ [redacted] រតន: ចូលមកធ្វើការ ខ្លួនបានប្រគល់ការងារបញ្ជីក្នុងផ្នែកតែបៃតងនេះឱ្យទៅគាត់ធ្វើទាំងអស់ រួចហើយគាត់ត្រូវធ្វើបញ្ជីប្រចាំខែឱ្យមកខ្លួន។ លុះប្រហែលខែធ្នូ ឆ្នាំ២០១៧ ការប្តូរវង្វាន់គម្របដបតែអូរិលឈិទៅឱ្យអតិថិជន គឺប្រគល់ទៅឱ្យផ្នែកគណនេយ្យកាន់ស្តុកឈ្មោះ [redacted] ធារ៉ា វិញ។ នៅពេលដែលត្រូវបញ្ជូនគម្របវង្វាន់ទៅប្តូរនៅរោងចក្រប្រទេសថៃ គឺខាងផ្នែកទីផ្សារដែលមានឈ្មោះ [redacted] យុទិត្យា ជាអ្នករៀបចំធ្វើឯកសាររួចដាក់ឱ្យខ្លួនពិនិត្យ ក្រោយពីខ្លួនចុះហត្ថលេខារួចហើយ លោក [redacted] យុទិត្យា បានបញ្ជូនទៅរោងចក្រតែម្តង ហើយខាងរោងចក្របានធ្វើការទូទាត់វង្វាន់នោះជាមួយនឹងក្រុមហ៊ុនដោយប្រគល់ឱ្យវិញជាទំនិញ មិនបានទូទាត់ជាប្រាក់ទេ។ លុះមកដល់ខែមេសា ឆ្នាំ២០១៩ ខ្លួនបានសុំច្បាប់ឈប់ដើម្បីមើលប្អូនឈឺ តែមិនកំណត់ថ្ងៃទេ ពេលនោះក្រុមហ៊ុនបានយកលោកស្រី [redacted] រ័ត្នន: នៅផ្នែកគណនេយ្យផ្នែកតែបៃតង អូរិលឈិ ធ្វើបញ្ជីបិទចាប់ពីខែមីនា ឆ្នាំ២០១៧ រហូតមកដល់ថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៩ ហើយគាត់បានឱ្យពួកខ្លួនធ្វើបញ្ជីឱ្យទៅគាត់ក្នុងរយៈពេល០៣សប្តាហ៍ តែដោយសារពេលវេលាខ្លីពេក ពួកខ្លួនធ្វើបញ្ជីបិទទាំងបង្ខំ ដូច្នេះមិនបានពិនិត្យគ្រប់ជ្រុងជ្រោយទេ រួចហើយខ្លួនបានចុះហត្ថលេខាជាមួយលោក [redacted] រតន: និងលោក [redacted] ដេវីត ដោយសរសេរថាធ្វើសម្រាប់ធ្វើសវនកម្ម និងកែតម្រូវ ហើយលោក [redacted] ដេវីត ក៏យកទៅប្រគល់ឱ្យលោកស្រី [redacted] រ័ត្នន:។ ចំពោះការប្តូរគម្របវង្វាន់ឱ្យអតិថិជន ខាងដេប៉ូអាចប្តូរជាប្រាក់ ហើយជួនកាលអាចកាត់ជាផលិតផលជូនទៅអតិថិជនវិញ ដូច្នេះហើយ ទើបមានការលំបាកពេលធ្វើបញ្ជី។ ខ្លួនមិនបានធ្វើការកិបកេងប្រាក់របស់ក្រុមហ៊ុនតាមរយៈការប្តូរគម្របវង្វាន់តែអូរិលឈិនោះទេ ហើយការចោទប្រកាន់របស់ដើមបណ្តឹងថាមានការលំអៀងនោះដោយសារការបិទបញ្ជីលឿនពេក មិនបានពិនិត្យឯកសារឱ្យបានត្រឹមត្រូវ។ ចំពោះផ្នែកភេសជ្ជៈតែបៃតងអូរិលឈិរបស់ក្រុមហ៊ុន គឺខ្លួនបានធ្វើបញ្ជីប្រចាំឆ្នាំ មិនមានការខាតបង់ទេ គឺចំណេញបានប្រហែលជាង ១,៥០០,០០០$ (មួយលានប្រាំសែនដុល្លារអាមេរិក) គិតមកដល់ថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៩ នេះ ហើយចំពោះការចោទប្រកាន់ថា ខ្លួនបានរំសាយការបញ្ជាទិញផលិតផលក្រុមហ៊ុនរបស់អតិថិជននោះ ខ្លួនមិនបានដឹងទេ។ បន្ទាប់ពី

មានបញ្ហានេះមកក្រុមហ៊ុនបានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដោយឯកភាពគ្នាយកក្រុមហ៊ុនមួយដើម្បីត្រួតពិនិត្យបញ្ជីឡើងវិញ តែមិនបានកំណត់ថាជ្រើសរើសក្រុមហ៊ុនណាមួយក្នុងកិច្ចព្រមព្រៀងនោះទេ តែបាននិយាយគ្នាក្នុងពេលប្រជុំនោះថាយកក្រុមហ៊ុនឯករាជ្យ ហើយខ្លួន និងបុគ្គលិកផ្សេងទៀត បានធ្វើពាក្យទៅក្រុមហ៊ុន HSC Beverages ដោយស្នើសុំយកក្រុមហ៊ុនឈ្មោះ Price Water House Corp (PWC) ចុះធ្វើសវនកម្ម តែក្រុមហ៊ុនបដិសេធ ហើយដាក់ពាក្យបណ្ដឹងមកខ្លួនតែម្ដង។ ខ្លួនសុំឱ្យតុលាការបង្កើតសវនកម្មឯករាជ្យដោយសុំឱ្យក្រុមហ៊ុន Price Water House Corp (PWC) ធ្វើសវនកម្ម ដើម្បីត្រួតពិនិត្យឡើងវិញ ហើយបើឃើញថាខ្លួនមានកំហុស ខ្លួនសុខចិត្តទទួលខុសត្រូវចំពោះមុខច្បាប់ ហើយបើឃើញថាខ្លួនគ្មានកំហុសសុំលើកលែងចោទប្រកាន់។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វតន: បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: ខ្លួនមិនបានដឹងថាក្រុមហ៊ុន HSC Beverages បង្កើតឡើងនៅឆ្នាំណាទេ តែខ្លួនចូលធ្វើការក្នុងក្រុមហ៊ុននេះតាមរយៈការសម្ភាស នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ ដោយមានតួនាទីជាប្រធានគណនេយ្យរបស់ក្រុមហ៊ុន ដោយទទួលប្រាក់ខែដំបូងចំនួន ១,៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិក)។ ក្រុមហ៊ុននេះនាំចូលភេសជ្ជៈ **អូអិឈិ រេងជ័រ** និងភេសជ្ជៈផ្សេងៗទៀតពីប្រទេសថៃ និងសាំងហ្គាពួរមកលក់ក្នុងប្រទេសកម្ពុជា។ ប្រធានក្រុមហ៊ុន HSC Beverages មានឈ្មោះ [redacted] ហុង ហើយឈ្មោះ [redacted] សាក់លី គឺជាអ្នកគ្រប់គ្រងទូទៅ រីឯឈ្មោះ [redacted] ដេវីត ជាអភិបាលក្រុមហ៊ុន។ ចំពោះភេសជ្ជៈរបស់ក្រុមហ៊ុននេះ គឺមានរង្វាន់នៅគម្របដប និងគម្របកំប៉ុង មានរង្វាន់ចាប់ពីប្រាក់រហូតដល់រថយន្ត ហើយរង្វាន់ដែលអតិថិជនត្រូវអាចបើកបាននៅដេប៉ូគ្រប់ខេត្តក្រុង រួចហើយខាងដេប៉ូបញ្ជូនរង្វាន់ទាំងនោះមកឱ្យក្រុមហ៊ុន HSC Beverages ហើយក្រុមហ៊ុនបានធ្វើសំណើរទៅក្រុមហ៊ុននៅក្រៅប្រទេស ដើម្បីបើករង្វាន់ត្រឡប់មកវិញចំពោះគម្របរង្វាន់ដែលចូលមកក្រុមហ៊ុន HSC Beverages គឺមានក្រុមការងាររបស់ក្រុមហ៊ុន ដែលអ្នកគ្រប់គ្រងទូទៅចាត់ឱ្យធ្វើការងារនេះ ហើយគម្របរង្វាន់នេះ ក្រោយពីទទួលបានហើយដាក់បញ្ចូលទៅក្នុងឃ្លាំងដាក់គម្របចាក់សោរ ហើយក្រុមការងារនោះជាអ្នកមើល។ ក្នុងមួយខែ ក្រុមហ៊ុនត្រូវធ្វើរបាយការណ៍រង្វាន់នេះទៅបើកនៅក្រុមហ៊ុនឯបរទេសម្ដង ដោយខាងផ្នែកទីផ្សារជាអ្នកធ្វើរបាយការណ៍ ហើយដាក់ជូនទៅផ្នែកចាត់ការទូទៅរបស់ក្រុមហ៊ុនគឺលោក [redacted] សាក់លី ពិនិត្យ រួចទើបបញ្ជូនទៅក្រុមហ៊ុនក្រៅប្រទេស។ ម្យ៉ាងទៀតទំនិញដែលផ្ញើមកវិញ អាចជាការដូរគម្របរង្វាន់ អាចជាទំនិញឱ្យទទេ អាចជាទំនិញផ្នែកទីផ្សារ និងទំនិញគិតលុយ។ ចំពោះខ្លួនមានតួនាទីត្រឹមតែពិនិត្យលើឯកសារដែលខាងលោក [redacted] សាក់លី ជាអ្នកចាត់ការទូទៅក្រុមហ៊ុនបញ្ជាទិញទំនិញពីក្រៅប្រទេស ហើយគាត់បានដាក់មកខាងខ្លួនឱ្យពិនិត្យមើលថា អស់ជាទឹកប្រាក់ប៉ុន្មាន រួចដាក់ជូនទៅលោក [redacted] សាក់លី វិញ រួចគាត់បញ្ជូនទៅលោក [redacted] ដេវីត ជាអភិបាលក្រុមហ៊ុន រួចហើយគាត់បញ្ជូនទៅលោក [redacted] ហុង ជាប្រធានក្រុមហ៊ុន ដើម្បីត្រួតពិនិត្យ រួចហើយគាត់ចេញជាមូលប្បទានប័ត្រទូទាត់ជាមួយក្រុមហ៊ុននៅបរទេសតែម្ដង។ ក្រោយមកប្រហែលជាខែមេសា ឬខែឧសភា ឆ្នាំ២០១៨ នេះ ស្រាប់តែក្រុមហ៊ុនបានដូរអ្នកគ្រប់គ្រងក្រុមហ៊ុនទូទៅដោយដាក់ឈ្មោះ [redacted] រ័ត្ន: ជំនួសលោក [redacted] សាក់លី ហើយលោកស្រី [redacted] រ័ត្ន: គាត់

បានត្រួតពិនិត្យបញ្ជីក្រុមហ៊ុន ដោយឱ្យខ្លួនបិទបញ្ជីត្រឹមខែមេសាឱ្យគាត់ តែពេលវេលាខ្លីពេកធ្វើមិនទាន់ ទើបខ្លួនធ្វើទាំងបង្ខំ និងធ្វើជាបណ្តោះអាសន្នឱ្យគាត់សិន (បញ្ជីធ្វើចាប់ពីឆ្នាំ២០១៧ រហូតដល់ខែមេសា ឆ្នាំ២០១៨)។ ក្រោយពីខ្លួនធ្វើរបាយការណ៍រួចហើយ លោកស្រី [redacted] រ័ត្នន: ត្រួតពិនិត្យបញ្ជីឃើញថា បញ្ជីមានបញ្ហា ហើយខ្លួនក៏បានដឹងដែរថាបញ្ជីនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ព្រោះត្រូវការពេលវេលាវែងដើម្បីផ្ទៀងផ្ទាត់បញ្ជីនៅក្រុមហ៊ុនក្រៅប្រទេសទៀត និងរើឯកសារចាស់ៗមកធ្វើ។ ក្រោយពីលោកស្រី [redacted] រ័ត្នន: ពិនិត្យបញ្ជីរួចគាត់បានចាប់កំហុសខ្លួនថាបានផ្តល់រង្វាន់លើសទៅឱ្យដេប៉ូ តែការចេញប៊ុងប្រគល់ទៅឱ្យខាងដេប៉ូ ជាតួនាទីរបស់ឈ្មោះ [redacted] ធារ៉ា មានតួនាទីជាគណនេយ្យស្តុក គាត់វាយប៊ុងចេញជួនកាលគាត់បញ្ចេញទំនិញហើយទើបដាក់ឯកសារមកខាងខ្លួនពិនិត្យ រួចខ្លួនដាក់ជូនទៅលោក [redacted] សាក់លី ពិនិត្យ និងសម្រេច ហើយតម្កល់ឯកសារនៅក្រុមហ៊ុន។ បន្ទាប់មកក្រុមហ៊ុនបានប្រជុំពីបញ្ហានេះ ដោយខាងលោកស្រី [redacted] រ័ត្នន: ដែលជាអ្នកគ្រប់គ្រងទូទៅថាមានការបាត់ប្រាក់ក្រុមហ៊ុន ហើយគាត់ឱ្យឈ្មោះ [redacted] សាក់លី ជាអ្នកទទួលខុសត្រូវ តែលោក [redacted] សាក់លី ថាគាត់មិនបានដឹងពីបញ្ហានេះទេ តែសុំឱ្យក្រុមហ៊ុនបង្កើតសវនកម្មឯករាជ្យឱ្យត្រួតពិនិត្យឡើងវិញ ហើយក្រុមហ៊ុនបានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១៨ ថានឹងបង្កើតសវនកម្មឯករាជ្យ ដើម្បីត្រួតពិនិត្យឡើងវិញ តែមិនបានកំណត់ពេលវេលាដើម្បីបង្កើតសវនកម្មឯករាជ្យទេ។ ក្រោយពីចុះកិច្ចព្រមព្រៀងនោះរួចហើយ ខ្លួនក៏មិនបានចាកចេញពីក្រុមហ៊ុនដែរគឺនៅធ្វើការធម្មតា ហើយរំលងប្រហែល០២អាទិត្យ ខាងក្រុមហ៊ុនបានជូនដំណឹងថាសវនកម្មនឹងចុះមកក្នុងពេលឆាប់ៗនេះ ហើយខ្លួន និងលោក [redacted] សាក់លី បានដាក់ពាក្យស្នើសុំទៅក្រុមហ៊ុន HSC Beverages ដើម្បីយកក្រុមហ៊ុនឯករាជ្យនោះឈ្មោះ Pric Water House (PWM) ចុះធ្វើសវនកម្មវិញ ដោយក្រុមហ៊ុនមិនឱ្យការងារខ្លួនធ្វើ ខ្លួនក៏បានឈប់ទៅធ្វើការនៅពេលដែលដាក់សំណើរនេះតែម្តង តែក្រុមហ៊ុនមិនទទួល (សំណើសុំឱក្រុមហ៊ុន Pric Water House PWM ធ្វើសវនកម្ម)។ ខ្លួនបានធ្វើសំណើរ ០២-០៣ លើក ហើយក្រុមហ៊ុននៅតែមិនព្រមទទួល ខ្លួនបានដាក់ប្រៃយ៍ណីទើបគាត់ទទួល ហើយបានហៅខ្លួនឱ្យចូលដោះស្រាយ តែមានមេធាវីតំណាងឱ្យភាគីខ្លួនចូលដោះស្រាយជាមួយក្រុមហ៊ុន ទើបបានច្រានសំណើរខ្លួនចោលទើបស្ងាត់ ក្រោយមកស្រាប់តែមានការឃាត់ខ្លួនខ្លួនតែម្តង។ ចំពោះក្រុមហ៊ុនដែលថាមានការបាត់បង់ប្រាក់ចំនួន ២,០៩៣,១៦៦.២២$ (ពីរលានប្រាំបួនម៉ឺនបីពាន់មួយរយហុកសិបប្រាំមួយដុល្លារអាមេរិក និងម្ភៃពីសេន) នោះ ខ្លួនមិនបានដឹងទេ។ នៅពេលដែលខ្លួនមានតួនាទីនៅក្នុងក្រុមហ៊ុន ខ្លួនមិនដែលប៉ះពាល់ទឹកប្រាក់ចេញ និងចូលក្រុមហ៊ុនទេ រីឯការបញ្ជាទិញផលិតផល និងការចែកចាយផលិតផលក្នុងស្រុកក៏មិនមែនជាការងាររបស់ខ្លួនដែរ គឺមានផ្នែកផ្សេងៗគ្នា ចំណែកខ្លួនគ្រាន់តែទទួលឯកសាររួចសរុបបញ្ជីដាក់ជូនទៅលោក [redacted] សាក់លី ជាអ្នកគ្រប់គ្រងទូទៅ និងលោក [redacted] ដេវីត ជាអភិបាលក្រុមហ៊ុនរួចគឺចប់ការងាររបស់ខ្លួនហើយ។ ចំពោះការរំសាយការបញ្ជាទិញផលិតផលក្រុមហ៊ុនរបស់អតិថិជនចំនួន ៨២,៥៧៥ (ប្រាំបីម៉ឺនពីរពាន់ប្រាំរយចិតសិបប្រាំ) កេស ដែលមានទឹកប្រាក់ចំនួន ៧៨៤,៣១៦$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់បីរយដប់ប្រាំមួយដុល្លារអាមេរិក) នោះខ្លួនមិនដឹងទេ ហើយបើនិយាយពីតួនាទីខ្លួននៅក្នុងក្រុមហ៊ុននេះ គឺពុំមានសិទ្ធិ

107/21

បញ្ឈប់ការបញ្ជាទិញរបស់អតិថិជននេះទេ។ ខ្លួនសំណូមពរសុំឱ្យតុលាការបង្កើតសវនកម្មឯករាជ្យមួយ ដើម្បីត្រួតពិនិត្យឡើងវិញ និងសុំលើកលែងចោទប្រកាន់មកលើខ្លួន។

-តាមអំណានពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង បានបំភ្លឺថា: កាលពីអំឡុងឆ្នាំ ២០១៧ ខ្លួនបានបង្កើតក្រុមហ៊ុនឈ្មោះ HSC Beverages Co., Ltd នាំចូលផលិតផលភេសជ្ជៈតែអូអិឈិ និងភេសជ្ជៈរេងជ័រ ពីប្រទេសថៃមកចែកចាយក្នុងប្រទេសកម្ពុជា ដោយមានឈ្មោះ [redacted] រតន: ជាប្រធានគណនេយ្យ ,ឈ្មោះ [redacted] សាក់លី ជានាយកគ្រប់គ្រងទូទៅ រីឯឈ្មោះ [redacted] ដេវិត ជានាយកក្រុមហ៊ុន និងមានតួនាទីត្រួតពិនិត្យទៅលើការរៀបចំផែនការផ្សេងៗ និងការលក់ទៅតាមផែនការរបស់ក្រុមហ៊ុន។ នៅក្នុងដំណើរការក្រុមហ៊ុននេះ ឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: បានឃុបឃិតគ្នាជាមួយបក្ខពួកធ្វើរបាយការណ៍គណនេយ្យភូតកុហកផ្លាស់ប្តូរទិន្នន័យ និងកិបកេងយកប្រាក់របស់ក្រុមហ៊ុនធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ចាប់ពីក្រុមហ៊ុនបង្កើតរហូតមកដល់បច្ចុប្បន្ន ដែលធ្វើឱ្យក្រុមហ៊ុនខាតបង់ប្រាក់ចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន)។ ជាក់ស្តែងផលិតផលតែអូអិឈិ មានរង្វាន់នៅគម្របដប នៅពេលដែលអតិថិជនត្រូវរង្វាន់យកមកប្តូរនៅក្រុមហ៊ុន ក្រុមហ៊ុនត្រូវប្រើប្រាស់ផលិតផលដើម្បីសងទៅអតិថិជន ចំនួនសរុប ១,៥៩៥,៨៣០.៧០ (មួយលានប្រាំសែនប្រាំបួនម៉ឺនប្រាំពាន់ប្រាំបីរយសាមសិប ក្បៀសចិតសិប) កេស ប៉ុន្តែជាក់ស្តែងឈ្មោះ [redacted] សាក់លី ,ឈ្មោះ [redacted] រតន: និងគូកន បានប្រើប្រាស់ផលិតផលសងរង្វាន់ទៅអតិថិជនរហូតដល់ ១,៦៨២,៤៩៥.៤៧ (មួយលានប្រាំមួយសែនប្រាំបីម៉ឺនពីរពាន់បួនរយកៅសិបប្រាំ ក្បៀសសែសិបប្រាំពីរ) កេស លើសចំនួន ៨៦,៦៦៤.៧៧ (ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំមួយរយហុកសិបបួនក្បៀសចិតសិបប្រាំពីរ) កេស ដែលគិតជាប្រាក់សរុប ៧៦៦,៩៨៣.២០$ (ប្រាំពីរសែនប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំបួនរយប៉ែតសិបបីដុល្លារអាមេរិក និងម្ភៃសេន)។ ក្រុមហ៊ុនបានបញ្ជាទិញផលិតផលពីអតិថិជន ហើយក្រុមហ៊ុនបានបញ្ចេញផលិតផលប្រគល់ជូនអតិថិជនចំនួន ៨២,៥៧៥ (ប្រាំបីម៉ឺនពីរពាន់ប្រាំរយចិតសិបប្រាំ) កេស ដែលគិតជាសាច់ប្រាក់ចំនួនសរុប ៧៨៤,៣១៦$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់បីរយដប់ប្រាំមួយដុល្លារអាមេរិក) ប៉ុន្តែផលិតផលបានបញ្ចេញរួចហើយ ស្រាប់តែឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: បានប្រកាសរំលាយចោលការបញ្ជាទិញនេះទៅវិញ។ ក្រោយមកខ្លួនបានត្រួតពិនិត្យបញ្ជីគណនេយ្យក្រុមហ៊ុន ឃើញថាមានភាពមិនប្រក្រតីជាច្រើន ដែលខ្លួនបាត់បង់ប្រាក់សរុបចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន)។ ដើម្បីដោះស្រាយបញ្ហាបាត់បង់ប្រាក់ដ៏ច្រើននេះ និងដើម្បីជៀសវាងការចោទប្រកាន់គ្មានមូលដ្ឋាន ខ្លួនបានចុះកិច្ចព្រមព្រៀងជាមួយឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: និងបុគ្គលិកផ្សេងៗទៀត នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីជ្រើសរើសអ្នកធ្វើសវនកម្មឯករាជ្យត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនឡើងវិញ។ ក្រោយពីចុះកិច្ចព្រមព្រៀងរួច ឈ្មោះ [redacted] សាក់សី និងឈ្មោះ [redacted] រតន: បានបាត់ដំណឹងទូរស័ព្ទទាក់ទងមិនបាន និងគេចវេសមិនព្រមចូលខ្លួនមកដោះស្រាយរកការពិតចំពោះការបាត់បង់ប្រាក់នេះឡើយ។ ខ្លួនសំណូមពរ សុំឱ្យតុលាការផ្តន្ទាទោសឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: ទៅតាមផ្លូវច្បាប់សុំឱ្យអ្នកទាំងពីរទូទាត់ប្រាក់មកឱ្យខ្លួនចំនួន ៣,៨២៨,៣០៤.៤០$



Scanned with CamScanner

(បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន) វិញ និងទាមទារជួសជុលការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៥០០,០០០$ (ប្រាំសែនដុល្លារអាមេរិក) ព្រមទាំងសេវាមេធាវី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក)។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] គីមឡេង បានឆ្លើយបំភ្លឺនៅចៅក្រមស៊ើបសួរថា: កាលពីអំឡុងខែមករា ឆ្នាំ២០០៧ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC មានតួនាទីជាគណនេយ្យរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះឈ្មោះ [redacted] ដេវីត គឺជានាយក ,ឈ្មោះ [redacted] សាក់លី គាត់គឺជាអ្នកចាត់ចែងទូទៅ និងឈ្មោះ [redacted] រតនៈ ជាប្រធានគណនេយ្យ។ ចំពោះលោក [redacted] ដេវីត គាត់ជានាយកក្រុមហ៊ុន HSC Beverages មែន តែលោកឧកញ៉ា [redacted] ហុង ឱ្យគាត់ជួយមើលពីផែនការក្រុមហ៊ុននេះធ្វើបានតាមតម្រូវការដែរឬទេ ហើយលោក [redacted] ដេវីត គាត់មកធ្វើការក្នុងមួយអាទិត្យតែពីរថ្ងៃទេ ឯអ្នកធ្វើការផ្ទាល់ និងចាត់ចែងទូទៅក្រុមហ៊ុន គឺលោក [redacted] សាក់លី ជាអ្នកសម្រេច។ ចំពោះក្រុមហ៊ុន HSC Beverages បង្កើតឡើងនៅពាក់កណ្តាលខែមីនា ឆ្នាំ២០១៧ ដែលក្រុមហ៊ុននេះនាំចូលភេសជ្ជៈ អូរិឈិ រេងជ័រ និងភេសជ្ជៈផ្សេងៗទៀត ពីក្រុមហ៊ុននៅប្រទេសថៃមកលក់ក្នុងប្រទេសកម្ពុជា។ រាល់ការបញ្ជាទិញផលិតផលពីក្រុមហ៊ុននៅប្រទេសថៃរបស់ក្រុមហ៊ុន HSC Beverages បានប្រើមូលប្បទានប័ត្រសម្រាប់ចំណាយ ដែលមានតែលោកឧកញ៉ា [redacted] ហុង ទេដែលជាអ្នកសម្រេច តែបើសំណើរដែលមិនមានទាក់ទងនឹងមូលប្បទានប័ត្រ គឺពួកគាត់ដាក់ជូនទៅលោកឧកញ៉ា [redacted] ហុង ដោយផ្ទាល់តែម្តង។ នៅក្នុងឆ្នាំ២០១៨ លោកឧកញ៉ា [redacted] ហុង បានប្រជុំរួមបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន ដែលក្នុងនោះលោកឧកញ៉ាឱ្យខ្លួនធ្វើជាគណនេយ្យក្រុមហ៊ុន ដោយឱ្យជួយឆែកមើលបញ្ជីរបស់ក្រុមហ៊ុន តែដោយសារតែពេលនោះខ្លួនមិនមានពេលទំនេរ ទើបលោកឧកញ៉ាបានចាត់លោកស្រី [redacted] រ័ត្នន: ចុះធ្វើកិច្ចការនេះវិញ។ ក្រោយពីលោកស្រី [redacted] រ័ត្នន: ពិនិត្យលើឯកសារទាំងអស់ ឃើញថាក្រុមហ៊ុនមានបញ្ហា តែមានបញ្ហាទៅលើអ្វីខ្លះខ្លួនមិនបានដឹងទេ។ ក្រោយមកក្រុមហ៊ុនធ្វើការប្រជុំ ហើយលោកឧកញ៉ាសម្រេចឱ្យមានសវនកម្មឯករាជ្យមួយនៅក្នុងក្រុមហ៊ុន។ លុះដល់ថ្ងៃកំណត់ដែលសវនកម្មចុះមក ស្រាប់តែលោក [redacted] សាក់លី និងលោក [redacted] រតនៈ មិនបានចូលខ្លួនទេ ក្រុមហ៊ុនបានទូរស័ព្ទទៅពួកគាត់ដែរ តែមិនចូល ហើយចាប់ពីថ្ងៃនោះមក ពួកគាត់មិនបានចូលមកធ្វើការទៀតទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ស្រីរ៉េន បានឆ្លើយបំភ្លឺនៅចៅក្រមស៊ើបសួរថា: កាលអំឡុងខែមេសា ឆ្នាំ២០១៧ ខ្លួនចូលបំរើការងារក្នុងក្រុមហ៊ុន HSC Beverages ផ្នែកតែអូរិឈិ មានតួនាទីជាអ្នកទារប្រាក់ពីអតិថិជន ដែលទទួលបានប្រាក់ខែ ៤៥០$ (បួនរយហាសិបដុល្លារអាមេរិក) ក្នុងមួយខែ ហើយពេលនេះប្រាក់ខែខ្លួនបានឡើងដល់ ៥៤៥$ (ប្រាំរយសែសិបប្រាំដុល្លារអាមេរិក)។ ចំពោះការងាររបស់ខ្លួនគឺទទួលបុងរបស់អតិថិជនដែលជំពាក់ប្រាក់ ហើយប្រគល់ឱ្យឈ្មោះ [redacted] សុភ័ក្ត្រ និងឈ្មោះ [redacted] ទូច ជាអ្នកចុះទៅប្រមូលប្រាក់ពីអតិថិជន ហើយដាក់ចូលទៅក្នុងគណនេយ្យរបស់ក្រុមហ៊ុន នៃធនាគារអេស៊ីលីដា ឬធនាគារអេប៊ីអេ ហើយយកប័ណ្ណដាក់ប្រាក់ចូលក្នុងធនាគារមកឱ្យខ្លួនធ្វើរបាយការណ៍ប្រមូលប្រាក់ពីអតិថិជន រួចបញ្ជូនឯកសារទៅផ្នែកបង់ប្រាក់ ដែលមានឈ្មោះ [redacted] លក្ខិណា ជាអ្នកពិនិត្យរួច ហើយខ្លួនបញ្ជូនទៅលោក

[redacted] សាក់លី។ ចំពោះការបញ្ហាទិញផលិតផលតែអូរិឈិ ពីក្រុមហ៊ុននៅប្រទេសថៃចូលមកក្រុមហ៊ុន HSC Beverages ដើម្បីចែកចាយក្នុងស្រុកនោះខ្លួនមិនបានដឹងទេ គឺមានផ្នែកផ្សេងតែខ្លួនមិនច្បាស់លាស់ទេ។ រីឯការប្តូរគម្របង្វាន់តែអូរិឈិ គឺមានផ្នែករង្វាន់មួយទៀត ពុំមានពាក់ព័ន្ធនឹងការងាររបស់ខ្លួនទេ ហើយខ្លួនក៏មិនដឹងរឿងនេះដែរ។ ចំពោះក្រុមហ៊ុនមានបញ្ហាអ្វីនោះខ្លួនមិនបានដឹងទេ គឺគ្រាន់តែដឹងថាមានសវនកម្មចុះមកត្រួតពិនិត្យក្រុមហ៊ុន បានរយៈពេលប្រហែលមួយអាទិត្យ តែខ្លួនមិនដឹងខាងណាចុះមកទេ ហើយខ្លួនបានបញ្ជូនឯកសារដើម្បីឱ្យគេពិនិត្យដែរ។ បច្ចុប្បន្ននេះខ្លួននៅធ្វើការធម្មតា ហើយខ្លួនមិនដឹងរឿងអ្វីទៀតទេ។

-កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ការសួរដេញដោលរួចមក ខ្លួននៅតែរក្សាការប្តឹងទៅលើឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] សាក់លី ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល។ នៅក្នុងនេះ លោក [redacted] សាក់លី និងលោក [redacted] រតនៈ ត្រូវបានផ្តល់នូវការទុកចិត្តដោយកូនក្តីខ្លួនឱ្យគ្រប់គ្រងអាជីវកម្មក្រុមហ៊ុន តាំងពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ នៅក្នុងការគ្រប់គ្រងអាជីវកម្ម ទោះបីជាមានលោក [redacted] ដេវីត ជាអភិបាល តែលោកជាអ្នកគ្រប់គ្រងទៅលើផ្នែកទីផ្សារក្នុងការទាក់ទងជាមួយផ្នែកអាជីវកម្ម ក៏ដូចជាការផ្សព្វផ្សាយពាណិជ្ជកម្ម ដោយឡែកលោក [redacted] សាក់លី គឺជាអ្នកគ្រប់គ្រងទូទៅ ដែលត្រូវបានផ្តល់ឱ្យគ្រប់គ្រងទៅលើប្រតិបត្តិការអាជីវកម្មក្រុមហ៊ុនទាំងមូល ហើយមួយវិញទៀត នៅក្នុងចម្លើយរបស់ឈ្មោះ [redacted] សាក់លី នៅដំណាក់កាលចៅក្រមស៊ើបសួរ គេបានបញ្ជាក់អំពីបទពិសោធន៍នៃការគ្រប់គ្រងអាជីវកម្មទំនិញតែបៃតងនេះ ពោលគឺនៅឆ្នាំ២០១៦ គាត់បានបង្កើតក្រុមហ៊ុនមួយ តែដោយសារតែគាត់ខ្វះហិរញ្ញវត្ថុ ទើបគាត់ផ្ទេរអាជ្ញាប័ណ្ណនេះមកឱ្យកូនក្តីខ្លួន ដោយសារតែទំនុកចិត្តនេះហើយ ទើបកូនក្តីខ្លួនបានប្រគល់អាជីវកម្មនេះឱ្យទៅឈ្មោះ [redacted] សាក់លី គ្រប់គ្រង ដោយមានការទុកចិត្តតាំងពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ តែអ្វីដែលគួរឱ្យសោកស្តាយនៅពេលដែលកូនក្តីខ្លួនជឿទុកចិត្ត បែរជាចំណូលរបស់ក្រុមហ៊ុនមានការថយចុះ ហើយបែរជាមានបំណុលកើតឡើងទៅវិញ។ នៅពេលដែលក្រុមហ៊ុនមានការសង្ស័យ ក្រុមហ៊ុនបានឱ្យលោកស្រី [redacted] រ័ត្ននៈ ដែលជាគណនេយ្យករថ្មីឱ្យចូលទៅជំនួសលោក [redacted] សាក់លី ហើយអ្វីដែលបានរកឃើញដំបូង គឺការចេញដោយមានការបញ្ជាក់ថា នៅក្នុងបញ្ជីកភ័ណ្ឌរបស់ក្រុមហ៊ុនមានសមតុល្យចំនួន ១,០០០,០០០$ (មួយលានដុល្លារអាមេរិក) តែផ្ទុយទៅវិញនៅក្នុងឃ្លាំងស្តុកទំនិញបែរជាមិនមានទំនិញទៅវិញ។ នៅក្នុងនេះតាមរបាយការណ៍របស់សវនកម្ម ដែលផ្ទៀងផ្ទាត់ជាមួយរបាយការណ៍គណនេយ្យ ក៏ដូចជារបាយការណ៍គណនេយ្យដែលលោក [redacted] សាក់លី ធ្វើឡើងសម្រាប់ប្រគល់ជូនក្រុមហ៊ុន ឃើញថា មានភាពលំអៀង នៅក្នុងនោះភាពលំអៀងទី១ គឺពាក់ព័ន្ធនឹងអត្រាប្តូរប្រាក់អត្រាប្តូរប្រាក់ដែលមានភាពលំអៀងដែលបានចុះនៅក្នុងរបាយការណ៍ដែលធ្វើឡើងដោយលោក [redacted] រតនៈ និងលោក [redacted] សាក់លី គឺមានការខុសទៅនឹងរបាយការណ៍ជាក់ស្តែង ពាក់ព័ន្ធនឹងអត្រាប្តូរប្រាក់នៅក្នុងធនាគារ គឺខុសគ្នាចំនួន ១១៣,១៩៥.៣$ (មួយសែនមួយម៉ឺនបីពាន់មួយរយកៅសិបប្រាំដុល្លារអាមេរិក និងបីសេន) ប៉ុន្តែយើងបានធ្វើអញ្ញាតកម្មឡើងវិញ រីឯសាច់ប្រាក់នៅក្នុងដៃមានចំនួន ២១៦,៥២៤.៧៧$ (ពីរសែនមួយម៉ឺនប្រាំមួយពាន់ប្រាំរយម្ភៃបួនដុល្លារអាមេរិក និងចិតសិបប្រាំពីរសេន) គឺមិនបានធ្វើអញ្ញាតកម្មទេ ហើយក៏មិនមាន

ឯកសារណាមួយមកបញ្ជាក់ថាសាច់ប្រាក់នេះត្រូវបានបាត់ទៅណាដែរ តែផ្ទុយទៅវិញ យើងមានឯកសារដែលជាការកត់ត្រារបស់អ្នកទទួលប្រាក់ដូចបានបញ្ជាក់របស់លោកស្រី [redacted] រ័ត្ននៈ និងឯកសាររបស់ក្រុមសវនករ ដែលបញ្ជាក់ថា ពិតជាមានផលចំណេញពីអត្រាប្តូរប្រាក់ចំនួន ២១៦,៥២៤.៧៧$ (ពីរសែនមួយម៉ឺនប្រាំមួយពាន់ប្រាំរយម្ភៃបួនដុល្លារអាមេរិក និងចិតសិបប្រាំពីរសេន) ពិតប្រាកដមែន ប៉ុន្តែមិនត្រូវបានកត់បញ្ចូលទៅក្នុងបញ្ជីទេ។ ចំណុចទី២ ដែលរកឃើញថា មានការបាត់ប្រាក់ចំនួន ៧៨,០២៤.៥៥$ (ប្រាំពីរម៉ឺនប្រាំបីពាន់ម្ភៃបួនដុល្លារអាមេរិក និងហាសិបប្អូនសេន) ការកត់ត្រានៅក្នុងបញ្ជីគណនេយ្យដែលរៀបចំដោយលោក [redacted] សាក់លី និងលោក [redacted] រតនៈ បានបញ្ជាក់ថា ក្រុមហ៊ុនបានខាតទៅលើអត្រាប្តូរប្រាក់ចំនួន ៧៨,០២៤.៥៤$ (ប្រាំពីរម៉ឺនប្រាំបីពាន់ម្ភៃបួនដុល្លារអាមេរិក និងហាសិបប្អូនសេន) ក៏ប៉ុន្តែការខាតបង់នេះមិនបានបញ្ជាក់ពីភស្តុតាងដែលជាឯកសារទេ ដូច្នេះមានន័យថា គាត់បានដកលុយរបស់ក្រុមហ៊ុនចំនួន ៧៨,០២៤.៥៤$ (ប្រាំពីរម៉ឺនប្រាំបីពាន់ម្ភៃបួនដុល្លារអាមេរិក និងហាសិបប្អូនសេន) ហើយបានបានធ្វើនិយ័តកម្មថានេះគឺជាការខាតទៅលើអត្រាការប្រាក់ដែលចំណុចនេះបានធ្វើឱ្យក្រុមហ៊ុនខាតបង់ប្រាក់ដូចចំនួនខាងលើ។ ចំណុចទី៣ ដែលត្រូវបានរកឃើញដោយសវនករ អំពីភាពលំអៀងនៃប័ណ្ណឥណទាន ប័ណ្ណឥណទាននេះ គឺជាប័ណ្ណដែលកើតចេញពីការវិលត្រឡប់មកវិញនូវទំនិញរបស់អតិថិជនដែលអាចជាការស្នើសុំគម្រូបដបដូររង្វាន់ ដែលជាគោលការណ៍ ដូចជាការបញ្ជាក់របស់សាក្សី នៅពេលដែលយើងធ្វើប័ណ្ណឥណទានត្រូវមានភស្តុតាងគាំទ្រជាសំណើររបស់អតិថិជន ឬជាវិក័យប័ត្របង្វិលត្រឡប់មកវិញរបស់អតិថិជន តែផ្ទុយទៅវិញ នៅក្នុងការរកឃើញជាក់ស្តែងរបស់សវនករឃើញថាមានចំនួន២២ប័ណ្ណឥណទាន ដែលមិនមានឯកសារគាំទ្រ ហើយចំនួននេះគឺធ្វើឡើងត្រឹមតែខែធ្នូ ឆ្នាំ២០១៩ ពោលគឺនៅពេលដែលក្រុមហ៊ុនមានការសង្ស័យទៅលើឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ហើយគាត់ក៏បានធ្វើនិយ័តកម្មទៅលើវិក័យប័ត្រដែលត្រូវទូទាត់ជាមួយអតិថិជន តាមរយៈការបង្កើតនូវប័ណ្ណឥណទានដែលមិនមានឯកសារគាំទ្រ តាមរយៈប័ណ្ណឥណទាននេះធ្វើឱ្យកាត់បន្ថយនូវចំណូលដែលក្រុមហ៊ុនត្រូវបានទទួលពីអតិថិជនតាមរយៈវិក័យប័ត្រក្នុងការទាមទារប្រាក់រហូតដល់ ៨១៤,៦១៨$ (ប្រាំបីសែនមួយម៉ឺនបួនពាន់ប្រាំមួយរយដប់ប្រាំបីដុល្លារអាមេរិក) នេះគឺជាការបង្កើតនូវបញ្ជីគណនេយ្យមួយដើម្បីកាត់បន្ថយនូវប្រាក់ដែលត្រូវប្រមូលពីអតិថិជន។ ក្នុងនេះគឺមានតែមួយខែទេ ដោយឡែកខែផ្សេងៗគឺមិនមានចំនួនច្រើនដូចដែលពេលមិនទាន់រៀបបញ្ជីគណនេយ្យទេ ដែលដូចជាបង្ហាញអំពីចេតនានៅក្នុងការធ្វើនិយ័តកម្មនៃបញ្ជីគណនេយ្យដែលបានដកលុយពីក្រុមហ៊ុនទៅតាមរយៈការប្រមូលទឹកប្រាក់ពីអតិថិជន ប្តូរមកជាការបង្កើតនូវរូបភាពក្លែងបន្លំពីករណីដែលអតិថិជនធ្វើការប្តូររង្វាន់គម្រូបដប ក៏ដូចជាការបង្វិលទំនិញមកឱ្យក្រុមហ៊ុនវិញ។ ចំណុចទី៣ ពាក់ព័ន្ធនឹងការប្តូររង្វាន់គម្រូបដប ការរកឃើញនេះតាមរយៈបញ្ជីគណនេយ្យដែលរៀបចំដោយលោក [redacted] រតនៈ និងលោក [redacted] សាក់លី ភ្ជាប់ជាមួយនឹងបញ្ជីដែលមាននៅក្នុងក្រុមហ៊ុននៅប្រទេសថៃក៏ដូចជាចំនួនជាក់ស្តែងដែលមាននៅក្នុងស្តុកទំនិញ ឃើញថាមានភាពលំអៀងទៅលើទំនិញជាក់ស្តែងដែលបានបញ្ជូនទៅឱ្យអតិថិជន គឺមានការខុសគ្នារហូតដល់ទៅ ២៦១,៦៧៦.៩៥ (ពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំមួយរយចិតសិបប្រាំមួយក្បៀសកៅសិបប្រាំ) កេស ដែលគិតជាទឹកប្រាក់មានចំនួន ២,៧១៩,១៣៧.១២$ (ពីរលានប្រាំពីរសែនមួយម៉ឺន

ប្រាំបួនពាន់មួយរយសាមសិបប្រាំពីរដុល្លារអាមេរិក និងដប់ពីរសេន)។ អំពើរបស់ឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] វតន: នេះ គឺធ្វើឱ្យក្រុមហ៊ុនបាត់បង់ប្រាក់រហូតដល់ទៅ ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន) ដូចនេះខ្លួនសំណូមពរសុំឱ្យលោកចៅក្រមសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] វតន: ជាអតិបរមា និងសុំឱ្យលោកចៅក្រមចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] វតន: ដើម្បីមកអនុវត្តទោស និងទាមទារប្រាក់ដែលបានបាត់បង់ចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន) និងសំណងការខូចខាតផ្សេងៗ និងជំងឺចិត្តចំនួន ៥០០,០០០$ (ប្រាំសែនដុល្លារអាមេរិក) និងថ្លៃសេវកម្មច្បាប់ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក)។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា ពិតជាមានការរំលោភលើទំណុកចិត្តពិសេសដោយអភិបាល ប្រព្រឹត្តដោយឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] វតន: ពិតប្រាកដមែន ជាក់ស្តែងជនជាប់ចោទទាំងពីរធ្លាប់បានទទួលតួនាទីដែលត្រូវបានតែងតាំងដោយក្រុមហ៊ុន HSC Bevera ges Co.,Ltd ដែលមានលោក [redacted] ហុង ជាប្រធានក្រុមហ៊ុន ហើយជនជាប់ចោទទាំងពីរបានចូលមកគ្រប់គ្រងនូវប្រតិបត្តិការរបស់ក្រុមហ៊ុន។ ក្នុងអំឡុងពេលនៃការគ្រប់គ្រង ការប្រើប្រាស់សិទ្ធិអំណាចរបស់ជនជាប់ចោទទាំងពីររូប បានធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គល ដោយប្រើប្រាស់តួនាទីជាអ្នកគ្រប់គ្រងគ្រង យោងតាមភស្តុតាងលំអិតនៃរបាយការណ៍សវនកម្ម ដែលមានលក្ខខណ្ឌទម្រង់ស្តង់ដារ មានទម្ងន់គ្រប់គ្រាន់ដែលអាចឱ្យតុលាការជឿជាក់បាន និងភស្តុតាងផ្សេងទៀត ដែលអាចសន្និដ្ឋានបានថាមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វតន: និងឈ្មោះ [redacted] សាក់លី ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសព្រហ្ម ទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ មាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

-ក្រោយពីបានស្តាប់ចម្លើយសាក្សី
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់អំណានចម្លើយមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**
**យល់ឃើញថា**

១-នៅអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ ឈ្មោះ [redacted] ហុង ជាប្រធានក្រុមហ៊ុនមួយឈ្មោះ HSC Bevera ges Co.,Ltd មានស្នាក់ការកណ្តាលនៅផ្ទះលេខ១៨ ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការ

មន រាជធានីភ្នំពេញ បានប្រគល់សិទ្ធិជូនឈ្មោះ [redacted] សាក់លី ធ្វើជានាយកគ្រប់គ្រងទូទៅ និងឈ្មោះ [redacted]វតនៈ ជាប្រធានគណនេយ្យ។ ក្នុងតួនាទីជាអ្នកគ្រប់គ្រងទូទៅ និងជាប្រធានគណនេយ្យ ឈ្មោះ [redacted] សាក់លី និង ឈ្មោះ [redacted] វតនៈ បានឃុបឃិតគ្នាកិបកេងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតាមរូបភាព លំអៀងលើអត្រាប្តូរប្រាក់ ពីប្រាក់បាតមកប្រាក់ដុល្លារ ពីប្រាក់ដុល្លារមកប្រាក់បាត ,ការប្តូរវង្វាន់លើស និងការទូទាត់ប្រាក់ជាមួយអតិថិជន ធ្វើឱ្យក្រុមហ៊ុនខាតបង់ប្រាក់សរុប ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារ អាមេរិក និងសែសិបសេន) ហើយឈ្មោះ [redacted] វតនៈ ជាអ្នករៀបចំបញ្ជីគណនេយ្យ ដើម្បីបិទបាំងអំពើល្មើស របស់ពួកគេ។ បន្ទាប់ពីបានរកឃើញថា ក្រុមហ៊ុនមានការបាត់បង់ប្រាក់យ៉ាងច្រើន ឈ្មោះ [redacted] ហុង ដែលជា ប្រធានក្រុមហ៊ុន HSC បានឱ្យឈ្មោះ [redacted] សាកលី និងឈ្មោះ [redacted] វតនៈ ផ្តល់កិច្ចសហការដើម្បីដោះស្រាយ បញ្ហានេះ និងផ្តល់នូវឯកសារលំអិតពីការគ្រប់គ្រងរបស់ខ្លួន ប៉ុន្តែពួកគេពុំបានផ្តល់នូវឯកសារលំអិតពីការ គ្រប់គ្រងរបស់ខ្លួនឡើយ បែរជាបិទទូរស័ព្ទហើយនាំគ្នាគេចខ្លួនបាត់តែម្តង។

២-នាពេលសវនាការសាក្សីឈ្មោះ [redacted]លក្ខិណា បានឆ្លើយថា: នៅអំឡុងខែឧសភា ឆ្នាំ២០១៧ ខ្លួនបាន ចូលបំរើការងារនៅក្រុមហ៊ុន HSC Beverages នៅផ្នែកតែអូរិលឈិ ខាងរៀបចំប័ណ្ណចំណាយរបស់ក្រុមហ៊ុន ដែលថ្នាក់លើរបស់ខ្លួនមានឈ្មោះ [redacted] វតនៈ ជាប្រធានគណនេយ្យ ,ឈ្មោះ[redacted] សាក់លី ជាប្រធានគ្រប់គ្រង និងឈ្មោះ [redacted] ដេវីត ជាអភិបាលក្រុមហ៊ុន។ ពេលនោះខ្លួនទទួលបានប្រាក់ខែចំនួន ៣៥០$ (បីរយហាសិប ដុល្លារអាមេរិក) ក្នុងមួយខែ ហើយបច្ចុប្បន្ននេះឡើងដល់ ៦២០$ (ប្រាំមួយរយម្ភៃដុល្លារអាមេរិក) ក្នុងមួយខែ។ ចំពោះការបញ្ជាទិញផលិតផលតែអូរិលឈិពីក្រុមហ៊ុននៅប្រទេសថៃ និងការប្តូរគម្របវង្វាន់តែអូរិលឈិ ខ្លួនមិនបាន ដឹងទេ ព្រោះមិនមែនជាការងាររបស់ខ្លួនទេ។ រាល់ការចំណាយរបស់ក្រុមហ៊ុនគ្រប់ផ្នែកទាំងអស់ត្រូវប្រគល់ វិក័យប័ត្រចំណាយនោះមកផ្នែកចំណាយ ហើយខ្លួនរៀបចំឯកសារ ដើម្បីស្នើសុំទៅប្រធានក្រុមហ៊ុនតាមរយៈ លោក [redacted] វតនៈ ,លោក សុងសាក់លី និងលោក [redacted] ដេវីត រួចបញ្ជូនទៅលោកស្រី [redacted] គីមឡេង ដែលជា ប្រធានគណនេយ្យរបស់ក្រុមហ៊ុន HSC Beverages Co.,Ltd ទើបដាក់ជូននាយកក្រុមហ៊ុនលោកឧកញ៉ា [redacted] ហុង ជាអ្នកសម្រេចចេញមូលប្បទានប័ត្រប្រគល់មកខាងខ្លួនវិញ ទើបខ្លួនបញ្ជូនមូលប្បទានប័ត្រនោះទៅឱ្យក្រុម ហ៊ុនដែលជាម្ចាស់សម្ភារៈ។ ចំពោះការកោះប្រជុំថាក្រុមហ៊ុនមានបញ្ហានោះ ខ្លួនមិនបានដឹងទេ ព្រោះគេបានប្រជុំ តែមេៗ តែកាលពីខែមិថុនា ឆ្នាំ២០១៩ នេះ មានការចុះសវនកម្មក្រុមហ៊ុនរយៈពេលមួយអាទិត្យ ហើយខ្លួនបាន បញ្ជូនឯកសារដើម្បីឱ្យគេពិនិត្យដែរ ប៉ុន្តែមិនឃើញប្រធានគណនេយ្យចូលរួមទេ។ បច្ចុប្បន្ននេះខ្លួននៅធ្វើការ ធម្មតា ហើយខ្លួនមិនដឹងរឿងអ្វីទៀតទេ។

៣-នាពេលសវនាការសាក្សីឈ្មោះ [redacted] សុភ័ក្ត្រ បានឆ្លើយថា: នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ខ្លួន បានចូលធ្វើការនៅក្រុមហ៊ុន HSC Beverages មានតួនាទីជាអ្នកប្រមូលប្រាក់ពីអតិថិជន ដោយទទួលបាន ប្រាក់ខែចំនួន២០០$ (ពីររយដុល្លារអាមេរិក) ក្នុងមួយខែ ហើយពេលនេះប្រាក់ខែខ្លួនឡើងដល់ ៣៣០$ (បីរយ សាមសិបដុល្លារអាមេរិក)។ ចំពោះការងាររបស់ខ្លួនគឺទទួលបន្ទុកដើរប្រមូលប្រាក់ពីអតិថិជនតាមដេប៉ូ នៅ ពេលដែលឈ្មោះ [redacted] ស្រីរ៉េន ទម្លាក់បុងឱ្យមកខ្លួនថាត្រូវទៅដេប៉ូណា គឺខ្លួនកាន់បុងទៅដេប៉ូនោះ។ នៅខាង

ផ្នែកខ្លួនមានគ្នាពីរនាក់គឺខ្លួន និងឈ្មោះ [redacted]ទូច ពេលប្រមូលប្រាក់បានហើយ ខ្លួនយកប្រាក់នោះទៅដាក់ចូលក្នុងគណនីធនាគារអេស៊ីលីដា និងធនាគារអេប៊ីអេ របស់លោកឧកញ៉ា [redacted] ហុង រួចហើយខ្លួនយកប័ណ្ណដាក់ប្រាក់ចូលក្នុងធនាគារ មកធ្វើរបាយការណ៍ជូនទៅផ្នែកចំណាយដែលមានឈ្មោះ [redacted] លក្ខិណា ជាអ្នកពិនិត្យ រួចទើបបញ្ជូនទៅប្រធានគណនេយ្យឈ្មោះ [redacted] រតនៈ ពិនិត្យ រួចហើយទើបបញ្ជូនទៅអ្នកគ្រប់គ្រងទូទៅឈ្មោះ [redacted] សាក់លី។ ចំពោះតែបៃតងអូរិឈិ របស់ក្រុមហ៊ុន HSC Beverages គឺនៅគម្របដបមានរង្វាន់ តែចំពោះការប្តូរគម្របរង្វាន់របស់អតិថិជនមកក្រុមហ៊ុននោះ ខ្លួនមិនបានដឹងទេ ព្រោះមានផ្នែកផ្សេងជាអ្នកធ្វើរឺឯការបញ្ជាទិញផលិតផលខ្លួនមិនបានដឹងទេ។ ចំពោះក្រុមហ៊ុន HSC Beverages មានបញ្ហាអ្វីនោះខ្លួនមិនបានដឹងទេ តែខ្លួនបានដឹងថាមានសវនកម្មចុះមកត្រួតពិនិត្យក្រុមហ៊ុន HSC Beverages បានរយៈពេលប្រហែលមួយអាទិត្យ តែខ្លួនមិនដឹងថាអ្នកខាងណាចុះមកទេ ហើយខ្លួនក៏បានបញ្ជូនឯកសារដើម្បីឱ្យគេពិនិត្យដែរ។ បច្ចុប្បន្នខ្លួនធ្វើការធម្មតា ហើយខ្លួនមិនដឹងរឿងអ្វីផ្សេងទៀតទេ។

៤-នាពេលសវនាការសាក្សីឈ្មោះ [redacted] ទូច បានឆ្លើយថា: ខ្លួនបានចូលធ្វើការនៅក្នុងក្រុមហ៊ុន HSC Beverages កាលពីអំឡុងឆ្នាំ២០១៧ មានតួនាទីជាអ្នកប្រមូលប្រាក់ពីអតិថិជន។ ចំពោះការងាររបស់ខ្លួនគឺទទួលបន្ទុកដើរប្រមូលប្រាក់ពីអតិថិជនតាមដេប៉ូ នៅពេលដែលឈ្មោះ [redacted] ស្រីរើន ទម្លាក់បុងឱ្យមកខ្លួនថាត្រូវទៅដេប៉ូណា គឺខ្លួនកាន់បុងទៅដេប៉ូនោះ។ ពេលប្រមូលប្រាក់បានហើយ ខ្លួនបានយកប្រាក់នោះទៅដាក់នៅធនាគារ និងវេរទៅប្រទេសថៃ រួចហើយខ្លួនយកវិក័យប័ត្រទៅឱ្យឈ្មោះ [redacted] លក្ខិណា។ ពេលដែលយកបុងចូលនោះ គឺមិនទាន់កាត់រង្វាន់ទេ។ ខ្លួនមិនបានធ្វើការផ្ទាល់ជាមួយឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈទេ ហើយចំពោះការប្តូររង្វាន់ខ្លួនមិនបានដឹងទេ ចំណែករឿងបាត់លុយក៏ខ្លួនមិនបានដឹងដែរ។ ឈ្មោះ [redacted] សាក់លីជាអ្នកបញ្ជាទិញផលិតផល តែខ្លួនមិនដឹងច្បាស់ទេថាអ្នកណាជាអ្នកសម្រេចចុងក្រោយនោះ។ ឈ្មោះ [redacted] រតនៈជាប្រធានគណនេយ្យ ចំណែកឈ្មោះ [redacted] ដេវីត ជាប្រធានគ្រប់គ្រង ខ្លួនមិនមានពាក់ព័ន្ធអ្វីជាមួយឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] សាក់លី នោះទេ។

៥-នាពេលសវនាការសាក្សីឈ្មោះ [redacted] ធារ៉ា បានឆ្លើយថា: នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC មានតួនាទីជាអ្នកគ្រប់គ្រងស្តុកទំនិញ និងចេញបុងឥវ៉ាន់ឱ្យទៅអតិថិជនរបស់ក្រុមហ៊ុន ក្រោយមកខ្លួនបានប្តូរមកកាន់ផ្នែកគ្រប់គ្រងរង្វាន់តែបៃតង អូរិឈិ វិញ រហូតមកដល់បច្ចុប្បន្ននេះ។ នៅពេលដែលខ្លួនមានតួនាទីជាអ្នកគ្រប់គ្រងស្តុកទំនិញនោះ គឺខ្លួនគ្រាន់តែជាអ្នកទទួលបុងពីឈ្មោះ [redacted] ណា និងឈ្មោះ នីតា នៅផ្នែកដឹកជញ្ជូនទំនិញក្រុមហ៊ុន HSC Beverages តាមការបញ្ជាទិញពីអតិថិជន។ ពេលពួកគាត់ដឹកផលិតផលនោះឱ្យទៅអតិថិជនរួច ទើបពួកគាត់យកបុងមកឱ្យខ្លួន ហើយខ្លួនយកបុងនោះមកគិតចេញជាប្រាក់ ហើយបញ្ជូនទៅឱ្យផ្នែកអេចអា (ផ្នែកទារប្រាក់) ដើម្បីដើរប្រមូលប្រាក់ពីអតិថិជន ដែលជំពាក់មកចូលក្រុមហ៊ុនវិញ។ ចំពោះអ្នកដែលទទួលការកម្ម៉ង់បញ្ជាទិញពីអតិថិជនគឺឈ្មោះ [redacted] គឹមអេង តែគាត់ឈប់ធ្វើការយូរហើយ តាំងពីមុនពេលឈ្មោះ [redacted] សាក់លី ចូលធ្វើការម្ល៉េះ ក្រោយមកទើបឈ្មោះ [redacted] សុវណ្ណារ៉ា បានចូលមកធ្វើជំនួស តែគាត់បានឈប់ធ្វើការហើយ។ ចំពោះបុងដែលខ្លួនចេញហើយ មុននឹងបញ្ជូន

ទៅឱ្យផ្នែកទារលុយ គឺខ្លួនត្រូវបញ្ជូនទៅលោក [redacted] រតនៈ និងលោក [redacted] សាក់លី ដើម្បីពិនិត្យ និងចុះហត្ថលេខារួចបញ្ជូនមកខ្លួនវិញ ទើបខ្លួនបញ្ជូនបន្តទៅឱ្យផ្នែកទារលុយរបស់ក្រុមហ៊ុន។ ចំពោះរឿងរង្វាន់ គឺខាងទីផ្សារជាអ្នកផ្តល់រង្វាន់ដល់អតិថិជន គឺមានឈ្មោះ [redacted] យុទិត្យា ជាអ្នករៀបចំ រួចហើយទើបបញ្ជូនរបាយការណ៍មកខាងខ្លួន ហើយខ្លួនបានកាត់កងជាមួយនឹងផលិតផលដែលត្រូវដឹកឱ្យអតិថិជនរួចរាល់ហើយ ទើបបញ្ជូនឯកសារនេះទៅឱ្យឈ្មោះ [redacted] ស្រីរើន នៅផ្នែកទារប្រាក់របស់ក្រុមហ៊ុន។ ឈ្មោះ [redacted] រតនៈ មានតួនាទីជាប្រធានគណនេយ្យ ចំណែកឈ្មោះ [redacted] សាក់លី ជាអ្នកគ្រប់គ្រងទូទៅ (GM)។ រយៈចុងក្រោយខ្លួនបានចុះទៅជួយរាប់គម្របរង្វាន់នៅចុងឆ្នាំ២០១៨ តាមការណែនាំរបស់ក្រុមហ៊ុន ដើម្បីឱ្យដឹងថាតើអតិថិជនបានផ្ញើមកពិតប្រាកដឬអត់ ក្រោយពេលរាប់រួចហើយគឺយកទៅទុកនៅក្នុងឃ្លាំង ដោយមានឈ្មោះ [redacted] ឆោម ជាប្រធានឃ្លាំង ពេលរាប់នោះគ្រាន់តែបានរាប់ចំនួនបេទេ ពុំបានរាប់ចំនួនគម្របទាំងអស់ទេ ក្នុងមួយបេមាន៥០០កេស ហើយនៅក្នុងបេនោះគឺគេច្រកជាថង់ ដោយក្នុងមួយថង់មាន២២០គម្រប ប៉ុន្តែឈ្មោះ [redacted] ភាន់ ជាអ្នករាប់ជាក់ស្តែង ហើយនៅពេលមានការបាត់បង់គឺឈ្មោះ [redacted] ភាន់ គាត់ជាអ្នកនិយាយជាមួយអតិថិជន។ ទាក់ទងនឹងTO យោងទៅតាមការដឹកជញ្ជូន ដោយសារពេលខ្លះឃ្លាំងអស់ស្តុក ហើយនៅពេលដែលអតិថិជនគាត់ទំនាក់ទំនងមក គឺយើងកាត់កងនឹងគម្របរង្វាន់ ពេលខ្លះកាត់កងជាទំនិញ ពេលខ្លះកាត់កងជាទឹកលុយជូនគាត់វិញ ហើយយើងធ្វើរបាយការណ៍ឱ្យទៅឈ្មោះ [redacted] រតនៈ ចុះហត្ថលេខា។ ក្រោយមកមានឈ្មោះ [redacted] រ័ត្នៈ បានចូលមកធ្វើការនៅក្នុងក្រុមហ៊ុន តែខ្លួនមិនដឹងថាគាត់កាន់ផ្នែកអ្វីទេ គ្រាន់តែដឹងថាទាក់ទងទៅនឹងផ្នែកតែបៃតងអូរិលឈិរបស់ក្រុមហ៊ុន ហើយក៏បានកោះហៅប្រជុំ និងឱ្យគ្រប់ផ្នែកធ្វើរបាយការណ៍ត្រៀមសវនកម្ម ព្រោះបញ្ជីក្រុមហ៊ុនមិនត្រឹមត្រូវ។ ក្រោយមកនៅក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៩ ខាងសវនកម្មបានចុះមកត្រួតពិនិត្យបានរយៈពេលជាងមួយអាទិត្យ តែមិនបានចប់ទេ ដោយសារលោក [redacted] រតនៈ និងលោក [redacted] សាក់លី មិននៅ ហើយចាប់ពីពេលនោះមកខ្លួនមិនដឹងរឿងអ្វីទៀតទេ គឺខ្លួនធ្វើការជាធម្មតារហូតមកដល់សព្វថ្ងៃ។

៦-នាពេលសវនាការសាក្សី [redacted] ដេវីត បានឆ្លើយថា: នៅអំឡុងឆ្នាំ២០១៦-២០១៧ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC TOBACCO មានតួនាទីជានាយកក្រុមហ៊ុន ខ្លួនបានចូលរួមធ្វើការងារ តែមិនជាប្រចាំទេ ភាគច្រើនខ្លួនធ្វើការនៅពេលព្រឹក ដោយខ្លួនជាប់មើលការងារនៅក្រុមហ៊ុនផ្សេងទៀត ហេតុនេះខ្លួនមកធ្វើការងារមិនជាប់លាប់ទេ។ នៅក្នុងក្រុមហ៊ុនខ្លួនមានតួនាទីជានាយកក្រុមហ៊ុន ,ឈ្មោះ [redacted] សាក់លី ជាអ្នកគ្រប់គ្រងទូទៅ (GM) និងឈ្មោះ [redacted] រតនៈ ជាគណនេយ្យ។ ខ្លួនមានតួនាទីជាអ្នកសម្របសម្រួល និងជួយគាត់តែងលិខិតដើម្បីទទួលបានការបញ្ជាទិញ រៀបចំគោលការណ៍លក់ គំរោងបង្កើនការលក់ ចំណែកអ្នកប្រតិបត្តិការផ្ទាល់គឺលោក [redacted] សាក់លី អ្នកធ្វើបញ្ជីចំណាយចំណូលគឺខាងគណនេយ្យឈ្មោះ [redacted] រតនៈ។ នៅក្នុងឆ្នាំ២០១៨ របាយការណ៍គណនេយ្យខ្លួនធ្លាប់ឃើញ ហើយរបាយការណ៍ចំណាយត្រូវបញ្ជូនទៅលោក [redacted] សាក់លី ផ្ទាល់ តែរបាយការណ៍ប្រចាំខែមិនបានឃើញរាល់ខែទេ។ ឈ្មោះ [redacted] រតនៈ ធ្វើការនៅក្រោមលោក [redacted] សាក់លី។ ការបញ្ជាទិញ និងការរៀបចំប្រចាំខែ ខ្លួនជាអ្នកទាក់ទងផ្ទាល់ជាមួយក្រុមហ៊ុននៅប្រទេសថៃ សម្រាប់ការលក់ និងការរៀបចំចែកចាយតាមដេប៉ូនៅតាមខេត្ត គឺលោក [redacted] សាក់លី ជាអ្នកទាក់ទងផ្ទាល់



Scanned with CamScanner

ខ្លួនបានត្រួតពិនិត្យប្រចាំខែ ដូចជាមួយខែលក់បានប៉ុន្មាន។ នៅពេលដែលខាងដេប៉ូដែលជាអតិថិជនចែកចាយបន្តភេសជ្ជៈរបស់ក្រុមហ៊ុន HSC Beverages ត្រូវការបញ្ជាទិញផលិតផល ពួកគាត់បានធ្វើសំណើរមកខាងផ្នែកលក់របស់ក្រុមហ៊ុន ហើយជួនកាលគាត់បានធ្វើសំណើរទៅលោក [redacted] សាក់លី ដោយផ្ទាល់តែម្តង។ នៅពេលទទួលការបញ្ជាទិញផលិតផលពីដេប៉ូ ខាងផ្នែកគណនេយ្យដែលមានលោក [redacted] រតនៈ ជាអ្នកធ្វើរបាយការណ៍មកលោក [redacted] សាក់លី រួចហើយទើបបញ្ជូនមកខ្លួនពិនិត្យតម្លៃទិញដែលមានស្រាប់ ហើយការផែកចំនួនត្រឹមត្រូវ ឬអត់ គឺផ្នែកលោក [redacted] រតនៈ។ ក្រោយពីខ្លួនចុះហត្ថលេខារួចហើយ លោក [redacted] រតនៈ មកយកឯកសារពីខ្លួន រួចបញ្ជូនទៅផ្នែកគណនេយ្យរបស់ក្រុមហ៊ុនធំ HSC ដែលមានអ្នកស្រី [redacted] គីមឡេង ជាប្រធានរួចហើយទើបបញ្ជូនទៅប្រធានក្រុមហ៊ុនធំ HSC គឺលោកឧកញ៉ា [redacted] ហុង។ ក្នុងករណីដែលខាងក្រុមហ៊ុនមានផលិតផលអាចផ្គត់ផ្គង់ដល់ដេប៉ូបាន គឺលោក [redacted] សាក់លី បានចាត់ចែងឱ្យផ្នែកឃ្លាំងបញ្ជូនឱ្យទៅដេប៉ូវិញតែម្តង គឺមិនបានឆ្លងមកដល់ខ្លួនទេ។ ប៉ុន្តែក្នុងករណីដែលផលិតផលនៅក្នុងក្រុមហ៊ុនមិនអាចផ្គត់ផ្គង់តាមតម្រូវការខាងដេប៉ូបានទេ ទើបខាងគណនេយ្យលោក [redacted] រតនៈ ធ្វើសំណើរទៅលោក [redacted] សាក់លី រួចបញ្ជូនមកដល់ខ្លួនហើយខ្លួនបញ្ជូនទៅលោកស្រី [redacted] គីមឡេង រួចបញ្ជូនបន្តទៅប្រធានក្រុមហ៊ុនលោកឧកញ៉ា [redacted] ហុង ក្រោយពីលោកឧកញ៉ា [redacted] ហុង ចុះហត្ថលេខារួចហើយ ទើបបញ្ជូនទៅលោកស្រី [redacted] គីមឡេង វិញ រួចលោកស្រី [redacted] គីមឡេង បញ្ជូនទៅលោក [redacted] រតនៈ ដើម្បីបញ្ជូនបន្តទៅក្រុមហ៊ុននៅប្រទេសថៃឱ្យផ្តល់ផលិតផលមុកក្រុមហ៊ុន ចំពោះការទូទាត់ប្រាក់ឱ្យទៅក្រុមហ៊ុននៅថៃ គឺវេរតាមធនាគារ ដោយប្រធានគណនេយ្យ ប្រាក់ គីមឡេង ជាអ្នកចុះហត្ថលេខា បន្ទាប់មកប្រធានក្រុមហ៊ុនចុះហត្ថលេខា ដោយឈ្មោះ [redacted] រតនៈ ជាអ្នកចូលរួមដឹងឮពីការកម្ម៉ង់ដែរ។ ចំពោះការទូទាត់ប្រាក់នៅតាមដេប៉ូចូលក្រុមហ៊ុន គឺខាងគណនេយ្យក្រុមហ៊ុនជាអ្នកធ្វើរបាយការណ៍ ហើយចំពោះរបាយការណ៍ចំណូល និងចំណាយប្រចាំខែ គឺតម្កល់នៅខាងគណនេយ្យក្រុមហ៊ុន។ ភេសជ្ជៈអូរិឈិ គឺមានរង្វាន់នៅគម្របដប ហើយនៅពេលដែលអតិថិជននៅតាមដេប៉ូប្តូរគម្របរង្វាន់ គឺគេបញ្ជូនចូលមកឃ្លាំង ហើយខាងលោក [redacted] រតនៈ ជាគណនេយ្យ បានធ្វើរបាយការណ៍ឡើងទៅលោក [redacted] សាក់លី រួចក៏ធ្វើការទូទាត់រង្វាន់ជាមួយដេប៉ូតែម្តង មិនបានឆ្លងកាត់មកខ្លួនទេ។ ចំពោះគម្របរង្វាន់ដែលដេប៉ូបញ្ជូនមក ត្រូវបានរក្សាទុកនៅក្នុងឃ្លាំង ដោយមានឈ្មោះ សូធី នៅផ្នែកទីផ្សាររៀបចំរបាយការណ៍ ដើម្បីបញ្ជូនទៅក្រុមហ៊ុននៅប្រទេសថៃ តែខ្លួនមិនដឹងថាអ្នកណាជាអ្នកបញ្ជូនទៅទេ ខ្លួនគ្រាន់តែដឹងថារបាយការណ៍នេះមិនបានឆ្លងកាត់មកខ្លួនទេ។ ចំពោះលោក [redacted] សាក់លី គាត់អាចបញ្ជាទិញផលិតផលភេសជ្ជៈពីប្រទេសថៃចូលមកក្រុមហ៊ុនផ្ទាល់បាន ឬអត់នោះខ្លួនមិនដឹងទេ តែមានពេលខ្លះពេលដែលក្រុមហ៊ុនត្រូវការផលិតផលដើម្បីផ្គត់ផ្គង់ឱ្យទៅដេប៉ូ គាត់បានឱ្យខ្លួនទូរស័ព្ទទៅក្រុមហ៊ុននៅថៃបញ្ជូនមកក្រុមហ៊ុន តែនៅពេលដែលខ្លួនមិនបាននៅក្នុងប្រទេសកម្ពុជា ខ្លួនជឿថាគាត់អាចបញ្ជាទិញដោយខ្លួនឯងបានព្រោះនៅប្រទេសថៃក៏គេស្គាល់គាត់ដែរ។ ក្រោយពីបញ្ជាទិញផលិតផលរួចហើយ ទើបលោក [redacted] សាក់លី ធ្វើសំណើរទៅប្រធានក្រុមហ៊ុន ដើម្បីធ្វើការទូទាត់ប្រាក់ឱ្យទៅក្រុមហ៊ុននៅប្រទេសថៃវិញ។ ពេលមានបញ្ហានៅឆ្នាំ២០១៩ ខ្លួនដឹង ព្រោះតួលេខនៅថៃ និងនៅខ្មែរមិនដូចគ្នា ទាំងភាគីថៃ និងភាគីខ្មែរមានការចាប់អារម្មណ៍នឹងគម្របដបប្តូររង្វាន់។ ក្រុមហ៊ុននៅខ្មែរប្រមូលគម្របដបទៅ

ឃ្លាំង ក្រោយមកក៏មានគម្រូបខុសគ្នាជាមួយនឹងគម្រូបនៅថៃ ដោយសារគម្រូបនៅខ្មែរច្រើនជាង ហើយជួនកាលក៏មានបុគ្គលិកនៅថៃចុះមកចាប់ ដោយសារមានចំនួនច្រើនពេក ចំនួនមិនស្មើគ្នា មិនប្រហាក់ប្រហែលគ្នា ខ្លួនដឹងថាមានភាពមិនស្មើគ្នានៅអំឡុងឆ្នាំ២០១៨ តែខ្លួនមិនដឹងពីចំនួនដែលខុសគ្នានោះច្បាស់លាស់ទេ។ ដោយសារខាងគណនេយ្យក្រុមហ៊ុន គឺលោកស្រី [redacted] គីមឡេង មានការសង្ស័យថា ខាងគណនេយ្យក្រុមហ៊ុនធ្វើអ្វីមិនច្បាស់លាស់ មានបញ្ហា ដោយខ្លួនមិនមានជំនាញផ្នែកគណនេយ្យ ដូចនេះខ្លួនមិនបានដឹងទេ ខ្លួនមានតួនាទីពិនិត្យទៅលើផែនការផ្សេងៗ និងលក់ទៅតាមផែនការរបស់ក្រុមហ៊ុនប៉ុណ្ណោះ ហើយលោកស្រី [redacted] គីមឡេង បានរាយការណ៍ទៅប្រធានក្រុមហ៊ុន ហើយប្រធានក្រុមហ៊ុនបានឱ្យខ្លួនត្រួតពិនិត្យឡើងវិញ។ តែដោយសារខ្លួនគ្មានជំនាញនេះ ខ្លួនក៏ស្នើសុំទៅប្រធានក្រុមហ៊ុនឱ្យចាត់លោកស្រី [redacted] រ័ត្នន: ដើម្បីឱ្យជួយមើលនៅផ្នែកគណនេយ្យ ហើយក្រុមហ៊ុនបានចាត់លោកស្រី [redacted] រ័ត្នន: ចុះមកត្រួតពិនិត្យផ្នែកគណនេយ្យទៅវិញ។ ដោយពិនិត្យមើលរបាយការណ៍ផ្នែកគណនេយ្យឃើញថា មានបញ្ហាទៅលើការប្តូរគម្រូបរង្វាន់ និងការចំណូល-ការចំណាយ ខុសនឹងឯកសារជាក់ស្តែង ពេលនោះលោកស្រី [redacted] រ័ត្នន: បានឱ្យលោក [redacted] សាក់លី និងលោក [redacted] រតន: ធ្វើរបាយការណ៍ឱ្យគាត់ ហើយលោកស្រី [redacted] រ័ត្នន: បានឱ្យខ្លួនជួយត្រួតពិនិត្យឯកសារទាំងនោះ ខ្លួនឃើញមានបញ្ហាជាច្រើន ដូចជាការប្រមូលគម្រូបរង្វាន់ពីដេប៉ូបានតិច ហើយផ្តល់រង្វាន់ទៅឱ្យដេប៉ូវិញច្រើនលើសពីការពិត ដែលធ្វើឱ្យក្រុមហ៊ុនខាតប្រាក់ច្រើន និងមានការបញ្ជាទិញពីដេប៉ូ ហើយខាងគាត់បានបញ្ជូនផលិតផលទៅឱ្យដេប៉ូវិញ តែគាត់មិនបានបញ្ចូលវិក័យប័ត្រទូទាត់ប្រាក់ទៅឱ្យដេប៉ូទេ ព្រោះពុំមានឯកសារតម្កល់នៅក្រុមហ៊ុន។ ខ្លួនបានចុះហត្ថលេខាលើរបាយការណ៍នោះ ដោយសរសេរថាឯកសារនោះ ជាកម្មវត្ថុសម្រាប់ធ្វើសវនកម្ម។ ក្រោយមកក្រុមហ៊ុនបានប្រជុំដើម្បីត្រៀមធ្វើសវនកម្ម លុះដល់ថ្ងៃកំណត់ធ្វើសវនកម្ម ស្រាប់តែលោក [redacted] សាក់លី និងលោក [redacted] រតន: មិនបានចូលរួមទេ។ ចំពោះលទ្ធផលផ្លូវការរបស់សវនកម្ម ខ្លួនមិនបានដឹងទេ ដោយខ្លួនបានចូលនិវត្តន៍នៅឆ្នាំ២០១៩។

៧-នាពេលសវនាការសាក្សីឈ្មោះ [redacted] រ័ត្នន: បានឆ្លើយថា: នៅអំឡុងពីខែកញ្ញា ឆ្នាំ២០១៦ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC TOBACCO មានតួនាទីជាអ្នកគ្រប់គ្រងទូទៅ (GM)។ នៅថ្ងៃ១៨ ខែមេសា ឆ្នាំ២០១៩ ក្រុមហ៊ុនបានឱ្យខ្លួនមកកាន់ផ្នែកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន HSC ជំនួសលោក [redacted] សាក់លី បន្ថែមលើមុខងារចាស់របស់ខ្លួនទៀត ហើយក្រុមហ៊ុនត្រូវចាត់លោក [redacted] សាក់លី ទៅកាន់ផ្នែកគម្រោងរបស់ក្រុមហ៊ុន HSC វិញ។ នៅពេលដែលខ្លួនមកធ្វើការនៅទីនេះ ខ្លួនបានមើលរបាយការណ៍គណនេយ្យឃើញថា មានរបាយការណ៍ជាង ១,០០០,០០០$ (មួយលានដុល្លារអាមេរិក) តែពុំមានផលិតផលអោសថ្ឋ:ក្នុងឃ្លាំងទេ។ ខ្លួនបានសួរទៅខាងឃ្លាំងរបស់ក្រុមហ៊ុននៅអូរស្មាច់ និងឃ្លាំងនៅបាត់ដំបង ពួកគាត់ថាអត់មានឥវ៉ាន់នៅក្នុងឃ្លាំងទេ។ លុះពីរថ្ងៃក្រោយមកខាងឃ្លាំងនៅខាងបាត់ដំបងបានប្រាប់មកវិញថា ឃ្លាំងរបស់គាត់មានអីវ៉ាន់ប្រហែលជា ៨០,០០០ (ប្រាំបីម៉ឺន) កេស ហើយលក់អស់ប្រហែល ៦០,០០០ (ប្រាំមួយម៉ឺន) កេស នៅសល់ប្រហែល ២០,០០០ (ពីរម៉ឺន) កេស នៅក្នុងឃ្លាំង។ ខ្លួនបានជម្រាបទៅលោកអគ្គនាយក ហើយលោកអគ្គនាយកបានឱ្យលោក [redacted] រតន: ,លោក [redacted] សាក់លី និងលោក [redacted] ដេវីត បិទបញ្ជីឱ្យគាត់ តើប្រាក់នៅសល់ប៉ុន្មាន និង

ចំណេញបានប៉ុន្មាន ដោយគិតចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០១៩ ប៉ុន្តែរបាយការណ៍បិទបញ្ជីរបស់ពួកគាត់ធ្វើបួនដង ដោយតួលេខប្រែប្រួលរហូត ហើយពួកគាត់បែរជាបិទបញ្ជីឆ្នាំ២០១៧ ទៅវិញ។ នៅខែឧសភា គាត់បានភ្លេចចេញវិក័យប័ត្រទារលុយចំនួន៤០ម៉ឺនដុល្លារជាង ពេលយើងរកឃើញ គឺគាត់បានដូររបាយការណ៍ដេប៉ូជាច្រើនដែលជាក្រុមគ្រួសាររបស់លោក [redacted] សាក់លី មានឪពុកក្មេកគាត់ដេប៉ូធំនៅខេត្តកំពង់ចាម ប្រពន្ធគាត់ដេប៉ូធំនៅភ្នំពេញ និងបងថ្លៃគាត់ដេប៉ូធំនៅខេត្តកណ្ដាល។ ខ្លួនបានមើលរបាយការណ៍បិទបញ្ជីរបស់ពួកគាត់ឃើញថាមានបញ្ហាទៅលើផ្នែកគម្រោងរង្វាន់ដែលត្រូវបើកឱ្យអតិថិជនវិញ គឺការប្រមូលរង្វាន់ពីខាងដេប៉ូមកបានតិចប្រហែលជា ១,៥៩០,០០០ (មួយលានប្រាំសែនប្រាំបួនម៉ឺន) កេស ហើយរបាយការណ៍ផ្ដល់រង្វាន់ទៅវិញច្រើនលើសរហូតទៅដល់ជាង ៨៦,០០០ (ប្រាំបីម៉ឺនប្រាំមួយពាន់) កេស។ ការខុសមួយទៀត គឺខុសទៅលើវិក័យប័ត្រលក់ឥវ៉ាន់ ដោយពួកគាត់លុបចោលវិក័យប័ត្របញ្ចុះថ្លៃពីអតិថិជនតាមដេប៉ូ ដែលមានទឹកប្រាក់សរុប ៧៨៤,០០០$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់ដុល្លារអាមេរិក) គិតក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ចំណុចនេះ ពួកគាត់បានអះអាងថា សម្រាប់ធ្វើការទូទាត់ជាមួយគម្រោងរង្វាន់ឱ្យទៅអតិថិជន តែពួកគាត់មិនមានឯកសារណាមួយមកបញ្ជាក់ឡើយ។ ចំពោះរបាយការណ៍បិទបញ្ជី លោក [redacted] រតនៈ គាត់ជាអ្នកធ្វើ ហើយចុះហត្ថលេខាដោយលោក [redacted] រតនៈ ,លោក [redacted] សាក់លី និងលោក [redacted] ដេវីត តែលោក [redacted] ដេវីត បានថារនៅខាងក្រោមថាសម្រាប់ធ្វើសវនកម្ម។ ដោយសារតែមានបញ្ហាបែបនេះ ទើបប្រធានក្រុមហ៊ុនបានឱ្យធ្វើសវនកម្មឡើងវិញ ដោយក្រុមហ៊ុនសម្រេចយកក្រុមហ៊ុនអង្គរចុះមកសវនកម្ម ហើយបានជូនដំណឹងទៅលោក [redacted] សាក់លី ,លោក [redacted] ដេវីត និងលោក [redacted] រតនៈ ឱ្យផ្ដល់ឯកសារសម្រាប់សវនកម្ម តែដល់ពេលកំណត់ពួកគាត់មិនបានផ្ដល់ឯកសារពេលនោះគឺគាត់មកធ្វើការធម្មតា ពេលអូឌីតមកបានរកឃើញមានបញ្ហាច្រើនជាងខ្លួន បញ្ហាខ្លាំងនោះគឺគាត់បិទបញ្ជីពីឆ្នាំ២០១៧-២០១៨ មុនពេលដែលខ្លួនចូល ដើម្បីទទួលបានប្រាក់អូធីពីក្រុមហ៊ុនចំនួន៥% តែគាត់ភ្លេចប៉ុងទារលុយភ្ញៀវ៤០ម៉ឺនជាង ខ្លួនក៏បានប្រាប់គាត់ថា ខាងក្រុមអូឌីតទារឯកសារ ពេលនោះគាត់ក៏ឈប់មកធ្វើការ ពីរបីថ្ងៃក្រោយមកទើបមានឯកសារមកឱ្យក្រុមហ៊ុនតាមរយៈមេធាវី។ គាត់ភ្លេចទារលុយភ្ញៀវជាង៤០ម៉ឺននោះ គឺនៅដេប៉ូក្រុមគ្រួសាររបស់គាត់ ហើយក្រោយមកគាត់បានមកជួបខ្លួន ហើយគាត់បានសងរួចរាល់អស់ហើយ តែក្រោយមកស្រាប់តែរកឃើញប្រហែល២០ ទៅ៣០ម៉ឺនទៀត។ ទាក់ទងនឹងការចំណាយការបញ្ចុះថ្លៃ ក្រុមហ៊ុនបានចេញ វិក័យប័ត្រឱ្យភ្ញៀវរួចហើយ តែគាត់បានធ្វើវិក័យប័ត្រដល់ ៧៨៤,៣១៦$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់បីរយដប់ប្រាំមួយដុល្លារអាមេរិក) ក្នុងមួយខែ (ខែកុម្ភៈ) ខ្លួនក៏បានសួរទៅគាត់ គាត់ប្រាប់ថា នេះជាការកាត់គម្រោងសងអតិថិជន តែគាត់មិនមានឯកសារនោះទេ។ ចំពោះការបញ្ចុះថ្លៃទំនិញនៅថៃ យើងតែងតែបង់លុយមុន១០០% តែពេលដែលមានបញ្ហាស្រាប់តែខាងថៃបានប្រាប់ថា យើងនៅជំពាក់គេជាង៧០ម៉ឺនដុល្លារអាមេរិក ពេលនោះទើបអគ្គនាយកសុំឱ្យធ្វើសវនកម្មបន្ទាន់ទៅលើស្តុកនៅអូរស្មាច់ និងឡែម។ ពេលដែលក្រុមហ៊ុនអង្គរចុះធ្វើសវនកម្មបានហៅគាត់ឱ្យមកចូលរួមតែគាត់មិនមក ខាងក្រុមហ៊ុនអង្គរមិនអាចធ្វើការបានទេបើគ្មានពួកគាត់មកចូលរួម ទើបយើងរកក្រុមហ៊ុនសវនករថ្មី គឺក្រុមហ៊ុន អេច អេស ស៊ី ហើយលទ្ធផលនៃសវនកម្មបានរកឃើញច្រើនជាងខ្លួនរកឃើញទៅទៀត សវនកម្មបានរកឃើញថាៈ ១-លំអៀងសាច់ប្រាក់ បាត-ដុល្លារ

២១៦,៥២៤.៧៧$ (ពីរសែនមួយម៉ឺនប្រាំមួយពាន់ប្រាំរយម្ភៃបួនដុល្លារអាមេរិក និងចិតសិបប្រាំពីរសេន) មិនបានកត់ត្រាចូលស៊ីស្ទឹម ,២-ឃើញមានការកត់ត្រាមួយ ដោយដាក់ថាការកត់ត្រាទទួលប្រាក់ដែលធ្វើការនិយ័តកម្ម តែមិនមានឯកសារទេ គឺមានចំនួន ៧៨,០០០$ (ប្រាំពីរម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ,៣-រកឃើញCredit Notes (ប័ណ្ណឥណទាន) ចំនួន២២ប័ណ្ណ ដែលមានទឹកប្រាក់ចំនួន ៨១៤,៦១៨$ (ប្រាំបីសែនមួយម៉ឺនបួនពាន់ប្រាំមួយរយដប់ប្រាំបីដុល្លារអាមេរិក) ដែលមិនមានឯកសារ ឬមូលដ្ឋានគាំទ្រគ្រប់គ្រាន់ សម្រាប់ឥណទានទាំងនេះទៅអតិថិជន ,៤-ការដូរគម្របរង្វាន់រកឃើញដល់ ២៨៣,២៤៣ (ពីរសែនប្រាំបីម៉ឺនបីពាន់ពីររយសែសិបបី) កេស គិតជាលុយមានចំនួន ២,៧១៩,១៣៧.១២$ (ពីរលានប្រាំពីរសែនមួយម៉ឺនប្រាំបួនពាន់មួយរយសាមសិបប្រាំពីរដុល្លារអាមេរិក និងដប់ពីរសេន) ចំណុចមួយទៀតនោះ គឺការធ្វើនិយ័តកម្មមានចំនួនច្រើន ហើយក្រុមហ៊ុនបានបាត់បង់លុយប្រហែល ៣.៨ លានដុល្លារ។ ការធ្វើសវនកម្មថ្មីនេះ គឺអត់មានការចូលរួមពីឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ទេ។ ចំពោះគម្របរង្វាន់ គឺមានកូនចៅគាត់ម្នាក់ជាអ្នកមើលការខុសត្រូវ ហើយរយៈពេល០១ខែ ទៅ០២ខែ គាត់បំផ្លាញចោលម្តង ដោយមានការចូលរួមពីភាគីថៃមកពិនិត្យគម្របដប។ ចំពោះការលំអៀងអត្រាប្តូរប្រាក់នៃការបញ្ជាទិញទំនិញអតិថិជនឱ្យជាប្រាក់រៀល និងដុល្លារ តែក្រុមហ៊ុនកំណត់ជាប្រាក់ដុល្លារ ខាងសវនកររកឃើញមានភាពលំអៀង ដោយលុយភាគច្រើនអត់ដែលចូលក្រុមហ៊ុនទេ ពេលប្តូរប្រាក់ម្តងៗម្ចាស់អត្រាប្តូរប្រាក់គេមានសរសេរនៅលើក្រដាសនឹងហើយ ជាធម្មតាប្រាក់ចំណេញ ឬខាតយើងមានគណនេយ្យរបស់ក្រុមហ៊ុនធ្វើការកត់ត្រា។ ពេលជួលក្រុមសវនករអង្គរមក ខ្លួនមិនដឹងថាអស់ប៉ុន្មានទេ ចំណែកសវនករលើកក្រោយនេះអស់ប្រហែល២ម៉ឺនដុល្លារអាមេរិក។

៨-នាពេលសវនាការសាក្សីឈ្មោះ [redacted] ដារិទ្ធ ជាសវនករ បានឆ្លើយថា: ក្រុមហ៊ុនខ្លួនបានបង្កើតឡើងនៅឆ្នាំ២០១១ ដោយបានទទួលអាជ្ញាប័ណ្ណគ្រប់គ្រាន់។ នៅពេលចុះសវនកម្មនៅក្រុមហ៊ុន HSC Beverages នោះមានគ្នា០៥នាក់ មានឈ្មោះ [redacted] ធីតា ជាអ្នកដឹកនាំ យើងបានធ្វើការត្រួតពិនិត្យទៅលើបញ្ជីស្នាមចំនួន ០៤ធំមាន: ១-វិធីលក់ ឬវដ្តនៃការលក់ និងការប្រមូលសាច់ប្រាក់ ,២-ការទិញ និងការបង់លុយ ,៣-ការចងទំនិញ ការចេញទំនិញ និងទំនិញដែលនៅសល់ និង៤-ការចំណាយទៅលើការលក់ យើងបានត្រួតពិនិត្យចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ គឺមានរយៈពេល២៩ខែ។ ពេលដែលពួកខ្លួនចុះអូឌីត បុគ្គលិកមួយចំនួនបានឈប់អស់ ឯកសារដើមខ្វះខាតច្រើន។ ភស្តុតាងដែលរកឃើញគឺមានវដ្តនៃការលក់ ទទួលស្គាល់ការលក់ ក្រុមហ៊ុនគាត់រកស៊ីកត់ត្រាជាប្រាក់ដុល្លារ និងឃើញប្រមូលលុយជាពីរប្រភេទ ហើយឃើញមានលុយក្នុងធនាគារចំនួន ១១៣,០០០$ (មួយសែនមួយម៉ឺនបីពាន់ដុល្លារអាមេរិក) ខុសគ្នាពីចំនួនប្រាក់នៅក្នុងដៃ តែមិនឃើញមានចុះភាពលំអៀងទេ។ ចំពោះការលក់ ឃើញមានប្រតិបត្តិការមិនប្រក្រតី ការកត់ត្រាមានលុយថយចុះចំនួន ៧៨,០២៨$ (ប្រាំពីរម៉ឺនប្រាំបីពាន់ម្ភៃប្រាំបីដុល្លារអាមេរិក) តែអត់មានឯកសារភស្តុតាងទេ ចំពោះវដ្តនៃការលក់ ឃើញមានប័ណ្ណឥណទានច្រើន ឃើញមានការកាត់បន្ថយរបស់អតិថិជន ហើយការដូររង្វាន់គម្របដប គាត់មានឯកសារគាំទ្រ។ យើងបានផ្ទៀងផ្ទាត់ឃើញមានភាពលំអៀង គឺការដូររង្វាន់គម្របដបឱ្យអតិថិជនច្រើនជាងរង្វាន់ដែលមានឯកសារទទួលពីអតិថិជនគឺមាន ១.៥លាន តែបញ្ជីឃើញមាន ១.៨លាន

ស្មើនឹង ២៨៣,២៤៣.២៥ (ពីរសែនប្រាំបីម៉ឺនបីពាន់ពីររយសែសិបបីក្បៀសម្ភៃប្រាំ) កេស និងឃើញមានឯកសារមួយទៀត គឺឯកសារផ្ទៃក្នុងឃើញមានគំលាត ២៦១,០០០ (ពីរសែនប្រាំមួយម៉ឺនមួយពាន់) កេស។ ខាងក្រុមហ៊ុនបានប្រាប់ថារង្វាន់ខាងរោងចក្រចេញ គឺមានផ្ទៀងផ្ទាត់ជាមួយក្រុមហ៊ុន ហើយយើងក៏បានផ្ទៀងផ្ទាត់ទៅឃើញមានភាពលំអៀងជាង២០ម៉ឺនកេស មិនដឹងដោយសារអ្វីទេ ចំណុចចុងក្រោយនោះគឺ របាយការណ៍លក់យើងឃើញមានការកត់ត្រាដោះដូរជាមួយថ្លៃដើម កត់ត្រាមិនត្រូវបច្ចេកទេស មិនមានការថយចុះ មិនមានការខាតបង់។ ពីរចំណុច យើងរកអត់ឃើញមានការបាត់បង់សាច់ប្រាក់ទេ ដោយសារខ្វះឯកសារច្បាប់ដើម ខ្វះការបកស្រាយ យើងអត់បានបញ្ជាក់ជាមួយអ្នកលក់ (គាត់អត់បានកែរបាយការណ៍ យើងអត់ដឹងបាត់បង់ប៉ុន្មាននោះទេ គ្រាន់តែរកឃើញលំអៀង)។ ក្រុមហ៊ុនខ្លួនធ្វើការអត់មានការចូលរួមពីអតិថិជនទេ ក្រុមហ៊ុនខ្លួនពុំមានជាប់សាច់ញាតិជាមួយប្រធានក្រុមហ៊ុន HSC Beverages ទេ ហើយក្រុមហ៊ុនខ្លួនក៏គ្មានទំនាស់ជាមួយឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ដែរ ក្រុមហ៊ុនខ្លួនមិនមានភាពលំអៀងទៅខាងណាទេ។ អ្នកដែលអនុវត្តសវនករមានរូបខ្លួន ដឹកនាំដោយឈ្មោះ [redacted] ធីតា ដែលមានបទពិសោធន៍០៥ឆ្នាំមកហើយ ,ឈ្មោះ វត្តី ,ឈ្មោះ [redacted] សែមសា ,ឈ្មោះ [redacted] ស្រីនាង និងឈ្មោះ [redacted] កុលធីតា ពួកគាត់ធ្វើជាបុគ្គលិកយ៉ាងតិច២ឆ្នាំ មានកម្រិតវប្បធម៌ បរិញ្ញាប័ត្រ ហើយលោក [redacted] ហុង ជាអ្នកបង់ថ្លៃសេវា សវនករឱ្យក្រុមហ៊ុនខ្លួន របាយការណ៍ដែលខ្លួនចេញនេះគឺស្តង់ដារ អ្វីដែលបានរកឃើញបង្ហាញពីតម្លាភាព ខ្លួនមិនបានរកឃើញការបាត់បង់ណាមួយទេ គ្រាន់តែឃើញការលំអៀង។

៩-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: កាលពីចុងឆ្នាំ២០១៦ ខ្លួនបានបង្កើតក្រុមហ៊ុន ឈ្មោះ យ៉ូកុ បេវើរេច ខេមបូឌា តែម្នាក់ឯងទេ ដោយខ្លួនមានឡាយសិនត្រឹមត្រូវ សម្រាប់នាំចូលតែបែតង អូអិឈិ ពីប្រទេសថៃ មកចែកចាយក្នុងស្រុក។ លុះមកដល់ខែមីនា ឆ្នាំ២០១៧ ដោយសារខ្លួនខ្វះដើមទុន ខ្លួនក៏បានប្រគល់ឡាយសិននេះឱ្យទៅលោកឧកញ៉ា [redacted] ហុង ជាប្រធានក្រុមហ៊ុន ហើយគាត់ឱ្យខ្លួនធ្វើការក្នុងក្រុមហ៊ុនរបស់គាត់ ដោយទទួលបានប្រាក់ខែ ៣,០០០$ (បីពាន់ដុល្លារអាមេរិក) ក្នុងមួយខែ និងបន្ថែមប្រាក់ចំណេញ៥% ក្នុងមួយឆ្នាំ។ ខ្លួនមានតួនាទីជាប្រធានទីផ្សារ ឈ្មោះ [redacted] ដេវីត ជាជនជាតិសាំងហ្គាពួរ ជានាយកក្រុមហ៊ុន ហើយមានលោកស្រី [redacted] គីមឡេង ជាប្រធានគណនេយ្យក្រុមហ៊ុន។ លុះមកដល់ខែឧសភា ឆ្នាំ២០១៧ ដោយសារឯកសារក្នុងក្រុមហ៊ុនមានភាពច្របូកច្របល់ ក្រុមហ៊ុនរបស់លោកឧកញ៉ា [redacted] ហុង បានឱ្យខ្លួនធ្វើជាអ្នកគ្រប់គ្រងទូទៅ ឯឈ្មោះ [redacted] ដេវីត ជានាយកក្រុមហ៊ុន ហើយលោកស្រី [redacted] គីមឡេង ជាអ្នកគ្រប់គ្រងគណនេយ្យរបស់ក្រុមហ៊ុន HSC Beverages ដដែល។ ខ្លួនមានតួនាទីមើលការខុសត្រូវក្រុមហ៊ុន ដូចជាការបញ្ជាទិញផលិតផលអូអិឈិ ពីក្រុមហ៊ុននៅប្រទេសថៃ ដើម្បីយកមកចែកចាយក្នុងស្រុក ហើយកូនចៅខ្លួនឈ្មោះ [redacted] លក្ខិណា ភេទស្រី (Account Payable) ជាអ្នកធ្វើរបាយការណ៍មកខ្លួន ហើយខ្លួនជាអ្នកត្រួតពិនិត្យឯកសារនេះ រួចទើបចុះហត្ថលេខាបញ្ជូនទៅលោក [redacted] ដេវីត ពិនិត្យបន្ត រួចហើយទើបចុះហត្ថលេខាបញ្ជូនទៅលោកស្រី [redacted] គីមឡេង ពិនិត្យ រួចទើបបញ្ជូនទៅលោកឧកញ៉ា [redacted] ហុង ចុះហត្ថលេខា និងចេញមូលប្បទានប័ត្រ ឬផ្ញើប៉ុស្ដប្រគល់

ទៅឱ្យលោកស្រី [redacted] គីមឡេង ហើយបញ្ជូនទៅឈ្មោះ [redacted] លក្ខិណា ទើបចាត់ឱ្យឈ្មោះ [redacted] ទូច និងឈ្មោះ [redacted] សុភ័ក្ត្រ មានតួនាទីជាអ្នកប្រមូលប្រាក់ឱ្យក្រុមហ៊ុនយកទៅកន្លែងវេរប្រាក់នៅអូឡាំពិច ដើម្បីវេរទៅក្រុមហ៊ុននៅប្រទេសថៃ ហើយចាប់ពីខែកុម្ភៈ ឆ្នាំ២០១៨ មក រាល់ការវេរប្រាក់ទៅក្រៅប្រទេសគឺធ្វើតាមរយៈធនាគារវិញ។ នៅពេលដែលក្រុមហ៊ុននៅប្រទេសថៃបញ្ជូនឥវ៉ាន់មកវិញតាមផ្លូវគោកហើយ គឺបានយកទៅចែកចាយតាមដេប៉ូក្នុងស្រុកតែម្តង ទើបយកបុងមកទូទាត់ឱ្យក្រុមហ៊ុន។ ចំពោះភេសជ្ជៈអូអិឈិនេះ គឺមានរង្វាន់នៅគម្របដប មានរង្វាន់ជាច្រើនដែលធំជាងគេគឺរថយន្តម៉ាកហ្សូតរ៉េនជ័រ ហើយរង្វាន់តូចៗដែលអតិថិជនត្រូវអាចបើកបាននៅដេប៉ូគ្រប់ខេត្តក្រុង រួចហើយទើបខាងទីផ្សារ និងឃ្លាំងធ្វើរបាយការណ៍ចូលមកគណនេយ្យ ដែលមានឈ្មោះ [redacted] ស្រីរ៉េន ជាអ្នកទារប្រាក់ពីដេប៉ូដែលជំពាក់ក្រុមហ៊ុន និងទូទាត់រង្វាន់ជាមួយដេប៉ូ ដើម្បីកាត់ប្រាក់ជំពាក់ជាមួយរង្វាន់នោះ ហើយចំពោះរង្វាន់ធំៗដូចជា ម៉ូតូ និងឡាន គឺក្រុមហ៊ុនចុះចែកដល់ផ្ទះ។ ចំពោះគម្របរង្វាន់ទាំងអស់ដែលចូលមកក្រុមហ៊ុនរួចហើយ រយៈពេលមួយខែទើបធ្វើការទូទាត់ទៅរោងចក្រប្រទេសថៃម្តង ហើយបើរង្វាន់ច្រើនពេកអាចមួយខែពីរដង។ ចំពោះសំណើរទៅរោងចក្រដើម្បីទូទាត់នោះ គឺកូនចៅខ្លួនបានធ្វើបញ្ជីសរុបមកឱ្យខ្លួន ហើយខ្លួនក៏ចុះហត្ថលេខាបញ្ជូនទៅរោងចក្រ ទើបខ្លួនរាយការណ៍ទៅលោក [redacted] ដេវីត ឱ្យគាត់បានដឹង រង្វាន់ពេលនោះអាចមានពីមួយម៉ឺនទៅពីរម៉ឺនកេសតែប៉ុណ្ណោះ ក្នុងពេលផ្ញើទៅម្តងៗ។ កាលពីខែមីនា ឆ្នាំ២០១៧ រហូតដល់ខែឧសភា ឆ្នាំ២០១៧ ពេលដែលលោកស្រី [redacted] គីមឡេង នៅជាប្រធានគណនេយ្យនោះ គាត់មិនបានធ្វើបញ្ជីចំណូលចំណាយប្រចាំខែ (បិទបញ្ជីប្រចាំខែ) ឱ្យបានត្រឹមត្រូវនោះទេ គឺរាល់បញ្ជីដែលផ្នែកផ្សេងៗប្រគល់ឱ្យទៅលោកស្រី [redacted] គីមឡេង គាត់បានយកទៅរក្សាទុកតែម្តង។ ដោយសារពុំមានភាពច្បាស់លាស់ចាប់ពីខែឧសភា ឆ្នាំ២០១៧ មក លោក សុខ ហុង ក៏បានប្រគល់ការងារបូកសរុបបញ្ជីចំណូលចំណាយផ្នែកតែបៃតង អូអិឈិ ឱ្យមកលោក [redacted] ដេវីត និងខ្លួនជាអ្នកធ្វើវិញម្តង រីឯផ្នែកផ្សេងៗ គឺគាត់ជាអ្នកធ្វើដដែល។ ពេលនោះខ្លួនត្រូវរៀបចំបញ្ជីចំណូលចំណាយ ចាប់ពីខែមីនា ឆ្នាំ២០១៧ ឡើងវិញទាំងអស់ គឺធ្វើតែតាមឯកសារដែលលោកស្រី [redacted] គីមឡេង ប្រគល់ឱ្យ រួចហើយតម្កល់ទុកក្នុងក្រុមហ៊ុនតែម្តង ពេលនោះខាងផ្នែកខ្លួន និងលោក [redacted] ដេវីត នេះ មិនទាន់មានប្រធានគណនេយ្យទេ។ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ ឈ្មោះ [redacted] រតនៈ បានចូលមកធ្វើជាប្រធានគណនេយ្យផ្នែកភេសជ្ជៈតែបៃតងអូអិឈិ ឯប្រធានផ្នែកគណនេយ្យរួមរបស់ក្រុមហ៊ុន គឺលោកស្រី [redacted] គីមឡេង ក្រោមការគ្រប់គ្រងពីឈ្មោះ [redacted] ដេវីត ដែរ ពេលឈ្មោះ [redacted] រតនៈ ចូលមកធ្វើការ ខ្លួនបានប្រគល់ការងារបញ្ជីក្នុងផ្នែកតែបៃតងនេះឱ្យទៅគាត់ធ្វើទាំងអស់ រួចហើយគាត់ត្រូវធ្វើបញ្ជីប្រចាំខែឱ្យមកខ្លួន។ លុះប្រហែលខែធ្នូ ឆ្នាំ២០១៧ ការប្តូររង្វាន់គម្របដបតែអូអិឈិទៅឱ្យអតិថិជន គឺប្រគល់ទៅឱ្យផ្នែកគណនេយ្យកាន់ស្តុកឈ្មោះ [redacted] ធារ៉ា វិញ។ នៅពេលដែលត្រូវបញ្ជូនគម្របរង្វាន់ទៅប្តូរនៅរោងចក្រប្រទេសថៃ គឺខាងផ្នែកទីផ្សារដែលមានឈ្មោះ [redacted] យុទិត្យា ជាអ្នករៀបចំធ្វើឯកសាររួចដាក់ឱ្យខ្លួនពិនិត្យ ក្រោយពីខ្លួនចុះហត្ថលេខារួចហើយ លោក [redacted] យុទិត្យា បានបញ្ជូនទៅរោងចក្រតែម្តង ហើយខាងរោងចក្របានធ្វើការទូទាត់រង្វាន់នោះជាមួយនឹងក្រុមហ៊ុនដោយប្រគល់ឱ្យវិញជាទំនិញ មិនបានទូទាត់ជាប្រាក់ទេ។ លុះមកដល់ខែមេសា ឆ្នាំ២០១៩ ខ្លួនបានសុំច្បាប់ឈប់ដើម្បីមើលប្អូនឈឺ តែមិនកំណត់ថ្ងៃទេ

ពេលនោះក្រុមហ៊ុនបានយកលោកស្រី [redacted] រ័ត្នន: នៅផ្នែកគណនេយ្យផ្នែកតែបៃតង អូរិឈិ ធ្វើបញ្ជីបិទចាប់ពីខែមីនា ឆ្នាំ២០១៧ រហូតមកដល់ថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៩ ហើយគាត់បានឱ្យពួកខ្លួនធ្វើបញ្ជីឱ្យទៅគាត់ក្នុងរយៈពេល០៣សប្តាហ៍ តែដោយសារពេលវេលាខ្លីពេក ពួកខ្លួនធ្វើបញ្ជីបិទទាំងបង្ខំ ដូច្នេះមិនបានពិនិត្យគ្រប់ជ្រុងជ្រោយទេ រួចហើយខ្លួនបានចុះហត្ថលេខាជាមួយលោក [redacted] រតនៈ និងលោក [redacted] ដេវីត ដោយសរសេរថាធ្វើសម្រាប់ធ្វើសវនកម្ម និងកែតម្រូវ ហើយលោក [redacted] ដេវីត ក៏យកទៅប្រគល់ឱ្យលោកស្រី [redacted] រ័ត្នន:។ ចំពោះការប្តូរគម្របរង្វាន់ឱ្យអតិថិជន ខាងដេប៉ូអាចប្តូរជាប្រាក់ ហើយជួនកាលអាចកាត់ជាផលិតផលជូនទៅអតិថិជនវិញ ដូច្នេះហើយ ទើបមានការលំបាកពេលធ្វើបញ្ជី។ ខ្លួនមិនបានធ្វើការកិបកេងប្រាក់របស់ក្រុមហ៊ុនតាមរយៈការប្តូរគម្របរង្វាន់តែអូរិឈិនោះទេ ហើយការចោទប្រកាន់របស់ដើមបណ្តឹងថាមានការលំអៀងនោះដោយសារការបិទបញ្ជីលឿនពេក មិនបានពិនិត្យឯកសារឱ្យបានត្រឹមត្រូវ។ ចំពោះផ្នែកភេសជ្ជៈតែបៃតងអូរិឈិរបស់ក្រុមហ៊ុន គឺខ្លួនបានធ្វើបញ្ជីប្រចាំឆ្នាំ មិនមានការខាតបង់ទេ គឺចំណេញបានប្រហែលជាង ១,៥០០,០០០$ (មួយលានប្រាំសែនដុល្លារអាមេរិក) គិតមកដល់ថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៩ នេះ ហើយចំពោះការចោទប្រកាន់ថា ខ្លួនបានរំសាយការបញ្ជាទិញផលិតផលក្រុមហ៊ុនរបស់អតិថិជននោះ ខ្លួនមិនបានដឹងទេ។ បន្ទាប់ពីមានបញ្ហានេះមកក្រុមហ៊ុនបានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ដោយឯកភាពគ្នាយកក្រុមហ៊ុនមួយដើម្បីត្រួតពិនិត្យបញ្ជីឡើងវិញ តែមិនបានកំណត់ថាជ្រើសរើសក្រុមហ៊ុនណាមួយក្នុងកិច្ចព្រមព្រៀងនោះទេ តែបាននិយាយគ្នាក្នុងពេលប្រជុំនោះថាយកក្រុមហ៊ុនឯករាជ្យ ហើយខ្លួន និងបុគ្គលិកផ្សេងទៀត បានធ្វើពាក្យទៅក្រុមហ៊ុន HSC Beverages ដោយស្នើសុំយកក្រុមហ៊ុនឈ្មោះ Price Water House Corp (PWC) ចុះធ្វើសវនកម្ម តែក្រុមហ៊ុនបដិសេធ ហើយដាក់ពាក្យបណ្តឹងមកខ្លួនតែម្តង។ ខ្លួនសុំឱ្យតុលាការបង្កើតសវនកម្មឯករាជ្យដោយសុំឱ្យក្រុមហ៊ុន Price Water House Corp (PWC) ធ្វើសវនកម្ម ដើម្បីត្រួតពិនិត្យឡើងវិញ ហើយបើឃើញថាខ្លួនមានកំហុស ខ្លួនសុខចិត្តទទួលខុសត្រូវចំពោះមុខច្បាប់ ហើយបើឃើញថាខ្លួនគ្មានកំហុសសុំលើកលែងចោទប្រកាន់។

១០-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រតនៈ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: ខ្លួនមិនបានដឹងថាក្រុមហ៊ុន HSC Beverages បង្កើតឡើងនៅឆ្នាំណាទេ តែខ្លួនចូលធ្វើការក្នុងក្រុមហ៊ុននេះតាមរយៈការសម្ភាស នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ ដោយមានតួនាទីជាប្រធានគណនេយ្យរបស់ក្រុមហ៊ុន ដោយទទួលប្រាក់ខែដំបូងចំនួន ១,៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិក)។ ក្រុមហ៊ុននេះនាំចូលភេសជ្ជៈ អូរិឈិ វេងជ័រ និងភេសជ្ជៈផ្សេងៗទៀតពីប្រទេសថៃ និងសាំងហ្គាពួរមកលក់ក្នុងប្រទេសកម្ពុជា។ ប្រធានក្រុមហ៊ុន HSC Beverages មានឈ្មោះ [redacted] ហុង ហើយឈ្មោះ [redacted] សាក់លី គឺជាអ្នកគ្រប់គ្រងទូទៅ រីឯឈ្មោះ [redacted] ដេវីត ជាអភិបាលក្រុមហ៊ុន។ ចំពោះភេសជ្ជៈរបស់ក្រុមហ៊ុននេះ គឺមានរង្វាន់នៅគម្របដប និងគម្របកំប៉ុង មានរង្វាន់ចាប់ពីប្រាក់រហូតដល់រថយន្ត ហើយរង្វាន់ដែលអតិថិជនត្រូវអាចបើកបាននៅដេប៉ូគ្រប់ខេត្តក្រុង រួចហើយខាងដេប៉ូបញ្ជូនរង្វាន់ទាំងនោះមកឱ្យក្រុមហ៊ុន HSC Beverages ហើយក្រុមហ៊ុនបានធ្វើសំណើរទៅក្រុមហ៊ុននៅក្រៅប្រទេស ដើម្បីបើករង្វាន់ត្រឡប់មកវិញចំពោះគម្របរង្វាន់ដែលចូលមក

ក្រុមហ៊ុន HSC Beverages គឺមានក្រុមការងាររបស់ក្រុមហ៊ុន ដែលអ្នកគ្រប់គ្រងទូទៅចាត់ឱ្យធ្វើការងារនេះ ហើយគម្រូបរង្វាន់នេះ ក្រោយពីទទួលបានហើយដាក់បញ្ចូលទៅក្នុងឃ្លាំងដាក់គម្របចាក់សោរ ហើយក្រុមការងារនោះជាអ្នកមើល។ ក្នុងមួយខែ ក្រុមហ៊ុនត្រូវធ្វើរបាយការណ៍រង្វាន់នេះទៅបើកនៅក្រុមហ៊ុនឯបរទេសម្ដង ដោយខាងផ្នែកទីផ្សារជាអ្នកធ្វើរបាយការណ៍ ហើយដាក់ជូនទៅផ្នែកចាត់ការទូទៅរបស់ក្រុមហ៊ុនគឺលោក [redacted] សាក់លី ពិនិត្យ រួចទើបបញ្ជូនទៅក្រុមហ៊ុនក្រៅប្រទេស។ ម៉្យាងទៀតទំនិញដែលផ្ញើមកវិញ អាចជាការដូរគម្របរង្វាន់ អាចជាទំនិញឱ្យទទេ អាចជាទំនិញផ្នែកទីផ្សារ និងទំនិញគិតលុយ។ ចំពោះខ្លួនមានតួនាទីត្រឹមតែពិនិត្យលើឯកសារដែលខាងលោក [redacted] សាក់លី ជាអ្នកចាត់ការទូទៅក្រុមហ៊ុនបញ្ជាទិញទំនិញពីក្រៅប្រទេស ហើយគាត់បានដាក់មកខាងខ្លួនឱ្យពិនិត្យមើលថា អស់ជាទឹកប្រាក់ប៉ុន្មាន រួចដាក់ជូនទៅលោក [redacted] សាក់លី វិញ រួចគាត់បញ្ជូនទៅលោក [redacted] ដេវិត ជាអភិបាលក្រុមហ៊ុន រួចហើយគាត់បញ្ជូនទៅលោក [redacted] ហុង ជាប្រធានក្រុមហ៊ុន ដើម្បីត្រួតពិនិត្យ រួចហើយគាត់ចេញជាមូលប្បទានប័ត្រទូទាត់ជាមួយក្រុមហ៊ុននៅបរទេសតែម្ដង។ ក្រោយមកប្រហែលជាខែមេសា ឬខែឧសភា ឆ្នាំ២០១៩ នេះ ស្រាប់តែក្រុមហ៊ុនបានដូរអ្នកគ្រប់គ្រងក្រុមហ៊ុនទូទៅដោយដាក់ឈ្មោះ [redacted] រ័ត្ននៈ ជំនួសលោក [redacted] សាក់លី ហើយលោកស្រី [redacted] រ័ត្ននៈ គាត់បានត្រួតពិនិត្យបញ្ជីក្រុមហ៊ុន ដោយឱ្យខ្លួនបិទបញ្ជីត្រឹមខែមេសាឱ្យគាត់ តែពេលវេលាខ្លីពេកធ្វើមិនទាន់ ទើបខ្លួនធ្វើទាំងបង្ខំ និងធ្វើជាបណ្ដោះអាសន្នឱ្យគាត់សិន (បញ្ជីធ្វើចាប់ពីឆ្នាំ២០១៧ រហូតដល់ខែមេសា ឆ្នាំ២០១៩)។ ក្រោយពីខ្លួនធ្វើរបាយការណ៍រួចហើយ លោកស្រី [redacted] រ័ត្ននៈ ត្រួតពិនិត្យបញ្ជីឃើញថា បញ្ជីមានបញ្ហា ហើយខ្លួនក៏បានដឹងដែរថាបញ្ជីនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ព្រោះត្រូវការពេលវេលាវែងដើម្បីផ្ទៀងផ្ទាត់បញ្ជីនៅក្រុមហ៊ុនក្រៅប្រទេសទៀត និងរើឯកសារចាស់ៗមកធ្វើ។ ក្រោយពីលោកស្រី [redacted] រ័ត្ននៈ ពិនិត្យបញ្ជីរួចគាត់បានចាប់កំហុសខ្លួនថាបានផ្ដល់រង្វាន់លើសទៅឱ្យដេប៉ូ តែការចេញបុងប្រគល់ទៅឱ្យខាងដេប៉ូ ជាតួនាទីរបស់ឈ្មោះ [redacted] ធារ៉ា មានតួនាទីជាគណនេយ្យស្តុក គាត់វាយបុងចេញជូនកាលគាត់បញ្ចេញទំនិញហើយទើបដាក់ឯកសារមកខាងខ្លួនពិនិត្យ រួចខ្លួនដាក់ជូនទៅលោក [redacted] សាក់លី ពិនិត្យ និងសម្រេច ហើយតម្កល់ឯកសារនៅក្រុមហ៊ុន។ បន្ទាប់មកក្រុមហ៊ុនបានប្រជុំពីបញ្ហានេះ ដោយខាងលោកស្រី [redacted] រ័ត្ននៈ ដែលជាអ្នកគ្រប់គ្រងទូទៅថាមានការបាត់ប្រាក់ក្រុមហ៊ុន ហើយគាត់ឱ្យឈ្មោះ [redacted] សាក់លី ជាអ្នកទទួលខុសត្រូវ តែលោក [redacted] សាក់លី ថាគាត់មិនបានដឹងពីបញ្ហានេះទេ តែសុំឱ្យក្រុមហ៊ុនបង្កើតសវនកម្មឯករាជ្យឱ្យត្រួតពិនិត្យឡើងវិញ ហើយក្រុមហ៊ុនបានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១៩ ថានឹងបង្កើតសវនកម្មឯករាជ្យ ដើម្បីត្រួតពិនិត្យឡើងវិញ តែមិនបានកំណត់ពេលវេលាដើម្បីបង្កើតសវនកម្មឯករាជ្យទេ។ ក្រោយពីចុះកិច្ចព្រមព្រៀងនោះរួចហើយ ខ្លួនក៏មិនបានចាកចេញពីក្រុមហ៊ុនដែរគឺនៅធ្វើការធម្មតា ហើយរំលងប្រហែល០២អាទិត្យ ខាងក្រុមហ៊ុនបានជូនដំណឹងថាសវនកម្មនឹងចុះមកក្នុងពេលឆាប់ៗនេះ ហើយខ្លួន និងលោក [redacted] សាក់លី បានដាក់ពាក្យស្នើសុំទៅក្រុមហ៊ុន HSC Beverages ដើម្បីយកក្រុមហ៊ុនឯករាជ្យនោះឈ្មោះ Pric Water House (PWM) ចុះធ្វើសវនកម្មវិញ ដោយក្រុមហ៊ុនមិនឱ្យការងារខ្លួនធ្វើ ខ្លួនក៏បានឈប់ទៅធ្វើការនៅពេលដែលដាក់សំណើរនេះតែម្ដង តែក្រុមហ៊ុនមិនទទួល (សំណើសុំឱក្រុមហ៊ុន Pric Water House PWM ធ្វើសវនកម្ម)។ ខ្លួនបានធ្វើ

សំណើរ ០២-០៣ លើក ហើយក្រុមហ៊ុននៅតែមិនព្រមទទួល ខ្លួនបានដាក់ប្រៃសណីទើបគាត់ទទួល ហើយបានហៅខ្លួនឱ្យចូលដោះស្រាយ តែមានមេធាវីតំណាងឱ្យភាគីខ្លួនចូលដោះស្រាយជាមួយក្រុមហ៊ុន ទើបបានច្រានសំណើរខ្លួនចោលទើបស្ងាត់ ក្រោយមកស្រាប់តែមានការឃាត់រូបខ្លួនតែម្តង។ ចំពោះក្រុមហ៊ុនដែលថាមានការបាត់បង់ប្រាក់ចំនួន ២,០៩៣,១៦៦.២២$ (ពីរលានប្រាំបួនម៉ឺនបីពាន់មួយរយហុកសិបប្រាំមួយដុល្លារអាមេរិក និងម្ភៃពីសេន) នោះ ខ្លួនមិនបានដឹងទេ។ នៅពេលដែលខ្លួនមានតួនាទីនៅក្នុងក្រុមហ៊ុន ខ្លួនមិនដែលប៉ះពាល់ទឹកប្រាក់ចេញ និងចូលក្រុមហ៊ុនទេ រីឯការបញ្ជាទិញផលិតផល និងការចែកចាយផលិតផលក្នុងស្រុកក៏មិនមែនជាការងាររបស់ខ្លួនដែរ គឺមានផ្នែកផ្សេងៗគ្នា ចំណែកខ្លួនគ្រាន់តែទទួលឯកសាររួចសរុបបញ្ជីដាក់ជូនទៅលោក [redacted] សាក់លី ជាអ្នកគ្រប់គ្រងទូទៅ និងលោក [redacted] ដេវីត ជាអភិបាលក្រុមហ៊ុនរួចគឺចប់ការងាររបស់ខ្លួនហើយ។ ចំពោះការរំសាយការបញ្ជាទិញផលិតផលក្រុមហ៊ុនរបស់អតិថិជនចំនួន ៨២,៥៧៥ (ប្រាំបីម៉ឺនពីរពាន់ប្រាំរយចិតសិបប្រាំ) កេស ដែលមានទឹកប្រាក់ចំនួន ៧៨៤,៣១៦$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់បីរយដប់ប្រាំមួយដុល្លារអាមេរិក) នោះខ្លួនមិនដឹងទេ ហើយបើនិយាយពីតួនាទីខ្លួននៅក្នុងក្រុមហ៊ុននេះ គឺពុំមានសិទ្ធិអ្វីបញ្ឈប់ការបញ្ជាទិញរបស់អតិថិជននេះទេ។ ខ្លួនសំណូមពរសុំឱ្យតុលាការបង្កើតសវនកម្មឯករាជ្យមួយ ដើម្បីត្រួតពិនិត្យឡើងវិញ និងសុំលើកលែងចោទប្រកាន់មកលើខ្លួន។

១១-តាមអំណានពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង បានបំភ្លឺថា: នៅអំឡុងឆ្នាំ ២០១៧ ខ្លួនបានបង្កើតក្រុមហ៊ុនឈ្មោះ HSC Beverages Co., Ltd នាំចូលផលិតផលភេសជ្ជៈតែអូអិឈិ និងភេសជ្ជៈរេងជ័រ ពីប្រទេសថៃមកចែកចាយក្នុងប្រទេសកម្ពុជា ដោយមានឈ្មោះ [redacted] រតនៈ ជាប្រធានគណនេយ្យ ,ឈ្មោះ [redacted] សាក់លី ជានាយកគ្រប់គ្រងទូទៅ រីឯឈ្មោះ ស៊ឹម ដេវីត ជានាយកក្រុមហ៊ុន និងមានតួនាទីត្រួតពិនិត្យទៅលើការរៀបចំផែនការផ្សេងៗ និងការលក់ទៅតាមផែនការរបស់ក្រុមហ៊ុន។ នៅក្នុងដំណើរការក្រុមហ៊ុននេះ ឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ បានឃុបឃិតគ្នាជាមួយបក្ខពួកធ្វើរបាយការណ៍គណនេយ្យភូតកុហកផ្លាស់ប្តូរទិន្នន័យ និងកិបកេងយកប្រាក់របស់ក្រុមហ៊ុនធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ចាប់ពីក្រុមហ៊ុនបង្កើតរហូតមកដល់បច្ចុប្បន្ន ដែលធ្វើឱ្យក្រុមហ៊ុនខាតបង់ប្រាក់ចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន)។ ជាក់ស្តែងផលិតផលតែអូអិឈិ មានរង្វាន់នៅគម្របដប នៅពេលដែលអតិថិជនត្រូវរង្វាន់យកមកប្តូរនៅក្រុមហ៊ុន ក្រុមហ៊ុនត្រូវប្រើប្រាស់ផលិតផលដើម្បីសងទៅអតិថិជន ចំនួនសរុប ១,៥៩៥,៨៣០.៧០ (មួយលានប្រាំសែនប្រាំបួនម៉ឺនប្រាំពាន់ប្រាំបីរយសាមសិបក្បៀសចិតសិប) កេស ប៉ុន្តែជាក់ស្តែងឈ្មោះ [redacted] សាក់លី ,ឈ្មោះ [redacted] រតនៈ និងគូកន បានប្រើប្រាស់ផលិតផលសងរង្វាន់ទៅអតិថិជនរហូតដល់ ១,៦៨២,៤៩៥.៤៧ (មួយលានប្រាំមួយសែនប្រាំបីម៉ឺនពីរពាន់បួនរយកៅសិបប្រាំក្បៀសសែសិបប្រាំពីរ) កេស លើសចំនួន ៨៦,៦៦៤.៧៧ ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំមួយរយហុកសិបបួនក្បៀសចិតសិបប្រាំពីរ) កេស ដែលគិតជាប្រាក់សរុប ៧៦៦,៩៨៣.២០$ (ប្រាំពីរសែនប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំបួនរយប៉ែតសិបបីដុល្លារអាមេរិក និងម្ភៃសេន)។ ក្រុមហ៊ុនបានបញ្ជាទិញផលិតផលពីអតិថិជន ហើយក្រុមហ៊ុនបានបញ្ចេញផលិតផលប្រគល់ជូនអតិថិជនចំនួន ៨២,៥៧៥ (ប្រាំបីម៉ឺនពីរពាន់ប្រាំរយ

ចិតសិបប្រាំ) កេស ដែលគិតជាសាច់ប្រាក់ចំនួនសរុប ៧៨៤,៣១៦$ (ប្រាំពីរសែនប្រាំបីម៉ឺនបួនពាន់បីរយដប់ប្រាំមួយដុល្លារអាមេរិក) ប៉ុន្តែផលិតផលបានបញ្ចេញរួចហើយ ស្រាប់តែឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] វតន: បានប្រកាសរំលាយចោលការបញ្ជាទិញនេះទៅវិញ។ ក្រោយមកខ្លួនបានត្រួតពិនិត្យបញ្ជីគណនេយ្យក្រុមហ៊ុន ឃើញថាមានភាពមិនប្រក្រតីជាច្រើន ដែលខ្លួនបាត់បង់ប្រាក់សរុបចំនួន ៣,៨២៨,៣០៤.៥០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន)។ ដើម្បីដោះស្រាយបញ្ហាបាត់បង់ប្រាក់ដ៏ច្រើននេះ និងដើម្បីជៀសវាងការចោទប្រកាន់គ្មានមូលដ្ឋាន ខ្លួនបានចុះកិច្ចព្រមព្រៀងជាមួយឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] វតន: និងបុគ្គលិកផ្សេងៗទៀត នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីជ្រើសរើសអ្នកធ្វើសវនកម្មឯករាជ្យត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនឡើងវិញ។ ក្រោយពីចុះកិច្ចព្រមព្រៀងរួច ឈ្មោះ [redacted] សាក់សី និងឈ្មោះ [redacted] វតន: បានបាត់ដំណឹងទូរស័ព្ទទាក់ទងមិនបាន និងគេចវេសមិនព្រមចូលខ្លួនមកដោះស្រាយរកការពិតចំពោះការបាត់បង់ប្រាក់នេះឡើយ។ ខ្លួនសំណូមពរ សុំឱ្យតុលាការផ្តន្ទាទោសឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] វតន: ទៅតាមផ្លូវច្បាប់សុំឱ្យអ្នកទាំងពីររូទាត់ប្រាក់មកឱ្យខ្លួនចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីរម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន) វិញ និងទាមទារជួសជុលការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៥០០,០០០$ (ប្រាំសែនដុល្លារអាមេរិក) ព្រមទាំងសេវាមេធាវី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក)។

១២-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] គីមឡេង បានឆ្លើយបំភ្លឺនៅចៅក្រមស៊ើបសួរថា: នៅអំឡុងខែមករា ឆ្នាំ២០០៧ ខ្លួនបានចូលបំរើការងារនៅក្រុមហ៊ុន HSC មានតួនាទីជាគណនេយ្យរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះឈ្មោះ [redacted] ដេវីត គឺជានាយក ,ឈ្មោះ [redacted] សាក់លី គាត់គឺជាអ្នកចាត់ចែងទូទៅ និងឈ្មោះ [redacted] វតន: ជាប្រធានគណនេយ្យ។ ចំពោះលោក [redacted] ដេវីត គាត់ជានាយកក្រុមហ៊ុន HSC Beverages មែន តែលោកឧកញ៉ា [redacted] ហុង ឱ្យគាត់ជួយមើលពីផែនការក្រុមហ៊ុននេះធ្វើបានតាមតម្រូវការដែរឬទេ ហើយលោក [redacted] ដេវីត គាត់មកធ្វើការក្នុងមួយអាទិត្យតែពីរថ្ងៃទេ ឯអ្នកធ្វើការផ្ទាល់ និងចាត់ចែងទូទៅក្រុមហ៊ុន គឺលោក [redacted] សាក់លី ជាអ្នកសម្រេច។ ចំពោះក្រុមហ៊ុន HSC Beverages បង្កើតឡើងនៅពាក់កណ្តាលខែមីនា ឆ្នាំ២០១៧ ដែលក្រុមហ៊ុននេះនាំចូលភេសជ្ជ: អូអិឈិ រេងជ័រ និងភេសជ្ជ:ផ្សេងៗទៀត ពីក្រុមហ៊ុននៅប្រទេសថៃមកលក់ក្នុងប្រទេសកម្ពុជា។ រាល់ការបញ្ជាទិញផលិតផលពីក្រុមហ៊ុននៅប្រទេសថៃរបស់ក្រុមហ៊ុន HSC Beverages បានប្រើមូលប្បទានប័ត្រសម្រាប់ចំណាយ ដែលមានតែលោកឧកញ៉ា [redacted] ហុង ទេដែលជាអ្នកសម្រេច តែបើសំណើរដែលមិនមានទាក់ទងនឹងមូលប្បទានប័ត្រ គឺពួកគាត់ដាក់ជូនទៅលោកឧកញ៉ា [redacted] ហុង ដោយផ្ទាល់តែម្តង។ នៅក្នុងឆ្នាំ២០១៩ លោកឧកញ៉ា [redacted] ហុង បានប្រជុំរួមបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន ដែលក្នុងនោះលោកឧកញ៉ាឱ្យខ្លួនធ្វើជាគណនេយ្យក្រុមហ៊ុន ដោយឱ្យជួយឆែកមើលបញ្ជីរបស់ក្រុមហ៊ុន តែដោយសារតែពេលនោះខ្លួនមិនមានពេលទំនេរ ទើបលោកឧកញ៉ាបានចាត់លោកស្រី [redacted] រ័ត្នន: ចុះធ្វើកិច្ចការនេះវិញ។ ក្រោយពីលោកស្រី [redacted] រ័ត្នន: ពិនិត្យលើឯកសារទាំងអស់ ឃើញថាក្រុមហ៊ុនមានបញ្ហា តែមានបញ្ហាទៅលើអ្វីខ្លះខ្លួនមិនបានដឹងទេ។ ក្រោយមកក្រុមហ៊ុនធ្វើការប្រជុំ ហើយលោកឧកញ៉ា

សម្រេចឱ្យមានសវនកម្មឯករាជ្យមួយនៅក្នុងក្រុមហ៊ុន។ លុះដល់ថ្ងៃកំណត់ដែលសវនកម្មចុះមក ស្រាប់តែលោក [redacted] សាក់លី និងលោក[redacted]តេន: មិនបានចូលខ្លួនទេ ក្រុមហ៊ុនបានទូរស័ព្ទទៅពួកគាត់ដែរ តែមិនចូល ហើយចាប់ពីថ្ងៃនោះមក ពួកគាត់មិនបានចូលមកធ្វើការទៀតទេ។

១៣-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] ស្រីរើន បានឆ្លើយបំភ្លឺនៅចៅក្រមស៊ើបសួរថា: នៅអំឡុងខែមេសា ឆ្នាំ២០១៧ ខ្លួនចូលបំរើការងារក្នុងក្រុមហ៊ុន HSC Beverages ផ្នែកតែអូរិឈិ មានតួនាទីជាអ្នកទារប្រាក់ពីអតិថិជន ដែលទទួលបានប្រាក់ខែ ៤៥០$ (បួនរយហាសិបដុល្លាអាមេរិក) ក្នុងមួយខែ ហើយពេលនេះប្រាក់ខែខ្លួនបានឡើងដល់ ៥៤៥$ (ប្រាំរយសែសិបប្រាំដុល្លារអាមេរិក)។ ចំពោះការងាររបស់ខ្លួនគឺទទួល បុងរបស់អតិថិជនដែលជំពាក់ប្រាក់ ហើយប្រគល់ឱ្យឈ្មោះ [redacted]សុភ័ក្ត្រ និងឈ្មោះ [redacted] ទូច ជាអ្នកចុះទៅប្រមូលប្រាក់ពីអតិថិជន ហើយដាក់ចូលទៅក្នុងគណនេយ្យរបស់ក្រុមហ៊ុន នៃធនាគារអេស៊ីលីដា ឬធនាគារអេប៊ីអេ ហើយយកប័ណ្ណដាក់ប្រាក់ចូលក្នុងធនាគារមកឱ្យខ្លួនធ្វើរបាយការណ៍ប្រមូលប្រាក់ពីអតិថិជន រួចបញ្ជូនឯកសារទៅផ្នែកបង់ប្រាក់ ដែលមានឈ្មោះ [redacted]លក្ខិណា ជាអ្នកពិនិត្យរួច ហើយខ្លួនបញ្ជូនទៅលោក [redacted] សាក់លី។ ចំពោះការបញ្ជាទិញផលិតផលតែអូរិឈិ ពីក្រុមហ៊ុននៅប្រទេសថៃចូលមកក្រុមហ៊ុន HSC Beverages ដើម្បីចែកចាយក្នុងស្រុកនោះខ្លួនមិនបានដឹងទេ គឺមានផ្នែកផ្សេងតែខ្លួនមិនច្បាស់លាស់ទេ។ រីឯការប្តូរគម្របង្វាន់តែអូរិឈិ គឺមានផ្នែករង្វាន់មួយទៀត ពុំមានពាក់ព័ន្ធនឹងការងាររបស់ខ្លួនទេ ហើយខ្លួនក៏មិនដឹងរឿងនេះដែរ។ ចំពោះក្រុមហ៊ុនមានបញ្ហាអ្វីនោះខ្លួនមិនបានដឹងទេ គឺគ្រាន់តែដឹងថាមានសវនកម្មចុះមកត្រួតពិនិត្យក្រុមហ៊ុន បានរយៈពេលប្រហែលមួយអាទិត្យ តែខ្លួនមិនដឹងខាងណាចុះមកទេ ហើយខ្លួនបានបញ្ជូនឯកសារដើម្បីឱ្យគេពិនិត្យដែរ។ បច្ចុប្បន្ននេះខ្លួននៅធ្វើការធម្មតា ហើយខ្លួនមិនដឹងរឿងអ្វីទៀតទេ។

១៤-តាមរបាយការណ៍សវនកម្ម ការរកឃើញតថភាពពិត ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ របស់ក្រុមហ៊ុន **អេច អេស ស៊ី បេ វើរីច** ឯ.ក បានបញ្ជាក់ពីការរកឃើញភាពលំអៀង ដូចខាងក្រោម:

**ក-ទាក់ទងនឹងវដ្តនៃការលក់** (ចំណូល/ គណនីត្រូវទទួល/ ការប្រមូលសាច់ប្រាក់) ពួកយើងបានរកឃើញថា សាច់ប្រាក់ប្រមូលបានពិតប្រាកដ សម្រាប់ការិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ គឺមានចំនួនច្រើនជាងចំនួនដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ។ យើងរកឃើញមានភាពលំអៀងចំនួន ១១៣,១៩៥.០៣ ដុល្លារអាមេរិក សម្រាប់សាច់ប្រាក់នៅក្នុងធនាគារ និងចំនួន ២១៦,៥២៤.៧៧ ដុល្លារអាមេរិក សម្រាប់សាច់ប្រាក់នៅក្នុងដៃដែលបានមកពីការចំណេញ នៃអត្រាប្តូរប្រាក់ ពីការទូទាត់នៃគណនីត្រូវទទួលរបស់អតិថិជនជាច្រើន។ ភាពលំអិតនៃការប្រមូលសាច់ប្រាក់ និងភាពលំអៀងប្រចាំខែ ត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធ១៖ សង្ខេបការប្រមូលសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨។

ភាពលំអៀងរបស់សាច់ប្រាក់នៅក្នុងធនាគារ ត្រូវបានធ្វើនិយ័តកម្ម និងបានកត់ត្រាជាការចំណេញនៃអត្រាប្តូរប្រាក់បរទេស។ ប៉ុន្តែភាពលំអៀងរបស់សាច់ប្រាក់នៅក្នុងដៃចំនួន ២១៦,៥២៤.៧៧ ដុល្លារអាមេរិក គឺមិនត្រូវរកឃើញថាបានកត់ត្រា និងរាយការណ៍នៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុទេ។ សូម

យោងទៅឧបសម្ព័ន្ធ១៖ សង្ខេបការប្រមូលសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨។

ក្រុមហ៊ុនបានអនុវត្តការលក់ផលិតផល ទៅអតិថិជនដោយលក់ជាពាក់ជារូបិយបណ្ណ ប្រាក់បាតថៃ ហើយការប្រមូលសាច់ប្រាក់ត្រូវបានធ្វើឡើងជាសាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅក្នុងធនាគារ ប៉ុន្តែការកត់ត្រា និងរាយការណ៍ការលក់ នៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានធ្វើជារូបិយបណ្ណប្រាក់ដុល្លារអាមេរិក ដែលជារូបិយបណ្ណគោល ដោយធ្វើការបំលែង (ពីប្រាក់បាតថៃ ទៅប្រាក់ដុល្លារអាមេរិក) វិក័យប័ត្រនីមួយៗនូវអត្រាប្តូរប្រាក់ថេរមួយ។ ការអនុវត្តន៍បែបនេះ នាំឱ្យមានចំណេញ ឬខាតពីអត្រាប្តូរប្រាក់ស្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ដែលមានការចំណេញពីអត្រាប្តូរប្រាក់ដូចបានកំណត់សម្គាល់ខាងលើ។ ក្រុមហ៊ុនបានធ្វើការផ្លាស់ប្តូរការលក់ជារូបិយបណ្ណប្រាក់ដុល្លារអាមេរិកទៅអតិថិជនរបស់ខ្លួនចាប់ពីខែកុម្ភៈ ឆ្នាំ២០១៨។

ដោយសារតែការកត់ត្រា និងឯកសារគាំទ្រមានកម្រិត ហើយមិនមានបុគ្គលិកសម្រាប់សាកសួរដោយផ្ទាល់មាត់ ពួកយើងមិនអាចផ្ទៀងផ្ទាត់ភាពលំអៀងនៃសាច់ប្រាក់នៅក្នុងដៃចំនួន ២១៦,៥២៤.៧៧ ដុល្លារអាមេរិក (ចំនួនសាច់ប្រាក់ពិតប្រាកដដែលប្រមូលបានមានចំនួនច្រើនជាងសាច់ប្រាក់ដែលកត់ត្រានៅក្នុងបញ្ជីគណនេយ្យ) ដែលបានមកពីការចំណេញអត្រាប្តូរប្រាក់សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨។

**ខ-ទាក់ទងនឹងវដ្តនៃការលក់** (ចំណូល/ គណនីត្រូវទទួល/ ការប្រមូលសាច់ប្រាក់) ពួកយើងបានរកឃើញថាមានការធ្វើនិយ័តកម្មទៅលើសាច់ប្រាក់ក្នុងដៃចំនួន ៧៨,០២៤.៥១ ដុល្លារអាមេរិក។ ការធ្វើនិយ័តកម្មត្រូវបានធ្វើឡើងតាមរយៈប័ណ្ណឥណទាន (កាត់បន្ថយ) ពីសាច់ប្រាក់ក្នុងដៃ ទៅជាការខាតពីអត្រាប្តូរប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលមានលេខយោង Adj. ហើយបានពណ៌នាថា “ខាតពីអត្រាប្តូរប្រាក់សម្រាប់ខែធ្នូ ឆ្នាំ២០១៧” ដែលមិនមានឯកសារគាំទ្រ និងមូលដ្ឋានសម្រាប់ការខាតពីអត្រាប្តូរប្រាក់ដែលបានកើតឡើងនោះទេ។ ចំនួនសរុបនៃការខាតពីអត្រាប្តូរប្រាក់ (គណនី ៧៧០១០) រាយការណ៍នៅឆ្នាំ២០១៧ គឺចំនួន ១៣៥,៨៤៨.២៦ ដុល្លារអាមេរិក។ និន្នានុប្បវត្តន៍ដែលដកស្រង់ចេញពីបញ្ជីគណនេយ្យ

| ថ្ងៃខែឆ្នាំ | លេខយោង | កំណត់ចំណាំ | គណនីលេខ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|---|
| ១២/៣១/២០១៧ | Adj | ខាតពីអត្រាប្តូរប្រាក់សម្រាប់ខែធ្នូ ឆ្នាំ២០១៧ | ៧៧០១០ ខាតពីអត្រាប្តូរប្រាក់ | | ៧៨,០២៤.៥២ |

ដោយសារតែការកត់ត្រាមិនមានឯកសារគាំទ្រ ហើយមិនមានបុគ្គលិកសម្រាប់សាកសួរដោយផ្ទាល់មាត់ ពួកយើងមិនអាចបញ្ជាក់ពីសុពលភាពនៃការធ្វើនិយ័តកម្មរបស់សាច់ប្រាក់នៅក្នុងដៃចំនួន ៧៨,០២៤.៥១ ដុល្លារអាមេរិក ជាការខាតពីអត្រាប្តូរប្រាក់សម្រាប់ខែធ្នូ ឆ្នាំ២០១៧ នោះទេ។

**គ-ទាក់ទងនឹងវដ្តនៃការលក់** (ចំណូល/ គណនីត្រូវទទួល/ ការប្រមូលសាច់ប្រាក់) ពួកយើងបានរកឃើញថា មានប័ណ្ណឥណទាន (Credit Note) ចំនួន២២ប័ណ្ណ បានកត់ត្រានៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ មានចំនួន

ទឹកប្រាក់សរុប ៨១៤,៦១៨.០០ ដុល្លារអាមេរិក ដែលមិនមានឯកសារ ឬមូលដ្ឋានគាំទ្រគ្រប់គ្រាន់សម្រាប់ឥណទានទាំងនេះទៅអតិថិជន។ ដំបូងឥណទានត្រូវបានកត់ត្រាជាឥណទានការលក់ និងឥណទានពន្ធដែលមានតម្លៃសូន្យ។ ការកត់ត្រាតម្លៃលក់សូន្យ បាននាំឲ្យមានការថយចុះនូវបរិមាណរបស់សន្និធិចំនួន ៨៦,៩៧៨ កេស ហើយបង្កើនថ្លៃដើមទំនិញដែលបានលក់។

ហើយបណ្ណឥណទានដែលមានចំនួនទឹកប្រាក់ ៨១៤,៦១៨.០០ ដុល្លារអាមេរិក ត្រូវបានកត់ត្រាទៅបន្ថយគណនីត្រូវទទួល (ចំនួនប្រាក់ឥណទានបានយកទៅកាត់បន្ថយលើវិក័យប័ត្ររបស់អតិថិជនជាច្រើន) និងកាត់បន្ថយ (ឥណពន្ធ) ការលក់ ដែលបណ្តាលឲ្យមានការកើនឡើងសន្និធិចំនួន ៨៦,៩៧៨ កេស ហើយថយចុះថ្លៃដើមទំនិញដែលបានលក់។ ភាពលំអិតនៃបណ្ណឥណទានរបស់អតិថិជននីមួយៗបានយកទៅកាត់បន្ថយលើគណនីត្រូវទទួល ព្រមទាំងភាពលំអិតវិក័យប័ត្រត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធ២៖ បណ្ណឥណទានលំអិត ខែកុម្ភៈ ឆ្នាំ២០១៨។

ផលប៉ះពាល់ដែលបណ្តាលមកពីការកត់ត្រាស្មុគ្រស្មាញនេះ គឺបានកាត់បន្ថយគណនីត្រូវទទួល និងគណនីលក់ ចំនួន ៨១៤,៦១៨.០០ ដុល្លារអាមេរិក ដោយមិនមានឯកសារដូររង្វាន់ ឬឯកសារមានសុពលភាពពីអតិថិជន (សម្រាប់ការកត់ត្រាការលក់ដូររង្វាន់ធម្មតា គឺមានវិក័យប័ត្រ/សក្ខីប័ត្រ ដែលមានសុពលភាពពីអតិថិជនភ្ជាប់មកជាមួយនូវព័ត៌មានលំអិតបញ្ជាក់ពីការស្នើសុំទូទាត់គ្រឡប់ "claims" ព្រមទាំងហត្ថលេខារបស់អតិថិជន និងហត្ថលេខារបស់បុគ្គលិកក្រុមហ៊ុន)។ ពួកយើងបានកត់សម្គាល់ឃើញមានឯកសារផ្ទៃក្នុងនៃការដូររង្វាន់ "Redemption Prize Claim" បានភ្ជាប់មកជាមួយនឹងប័ណ្ណឥណទាន ប៉ុន្តែមិនមានវិក័យប័ត្រ/សក្ខីប័ត្រដែលមានសុពលភាពពីអតិថិជនភ្ជាប់មកជាមួយនូវព័ត៌មានលំអិតបញ្ជាក់ពីការស្នើសុំទូទាត់គ្រឡប់ "Claims" ព្រមទាំងហត្ថលេខារបស់អតិថិជន និងហត្ថលេខារបស់បុគ្គលិកក្រុមហ៊ុននោះទេ។

ដោយសារតែឯកសារគាំទ្រមានកម្រិត មិនមានបុគ្គលិកសម្រាប់សាកសួរដោយផ្ទាល់មាត់ ហើយមិនមានធ្វើការបញ្ជាក់ជាមួយអតិថិជន ពួកយើងមិនអាចបញ្ជាក់ពីសុពលភាពនៃប័ណ្ណឥណទានចំនួន ៨១៤,៨១៦.០០ ដុល្លារអាមេរិក សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៨ នោះទេ។ សូមយោងទៅឧបសម្ព័ន្ធ២៖ បណ្ណឥណទានលំអិតខែកុម្ភៈ ឆ្នាំ២០១៨។

ឃ-ទាក់ទងនឹងសន្និធិ ពួកយើងបានរកឃើញថា មានភាពលំអៀងនៃចំនួនការដូររង្វាន់ (Sale Redemptions) របស់អតិថិជនដែលស្នើសុំទូទាត់គ្រឡប់ (Claims) ជាមួយនឹងចំនួនសន្និធិដែលផ្តល់ដោយក្រុមហ៊ុនទៅអតិថិជន និងចំនួនសន្និធិដែលស្នើសុំទូទាត់គ្រឡប់ (Claims) ពីរោងចក្រវិញ សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨។

១) ពួកយើងបានរកឃើញថា បរិមាណនៃសន្និធិដែលផ្តល់ដោយក្រុមហ៊ុន (រាយការណ៍នៅក្នុងបញ្ជីគណនេយ្យ) ដែលជាការដូររង្វាន់ (Sale Redemptions) មានចំនួនច្រើនជាងបរិមាណដែលអតិថិជនស្នើសុំទូទាត់គ្រឡប់ (Claims) ចំនួន ២៨៣,២៤៣.៤៥ កេស សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

យោងតាមវិក័យប័ត្រ/សក្ខីប័ត្រ ដែលមានសុពលភាពពីអតិថិជនភ្ជាប់មកជាមួយនូវព័ត៌មានលំអិតបញ្ជាក់ពីការស្នើសុំទូទាត់ត្រឡប់ (Claims) ព្រមទាំងហត្ថលេខារបស់អតិថិជន និងហត្ថលេខារបស់បុគ្គលិកក្រុមហ៊ុន ត្រូវបានប្រើប្រាស់ជាឯកសារមានសុពលភាពសម្រាប់គាំទ្រការដូររង្វាន់ (Sale Redemptions) ពួកយើងបានរកឃើញចំនួនដែលអតិថិជនបានស្នើសុំទូទាត់ត្រឡប់ (Claims) សម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ គឺសរុប ១,៥៧១,០៣៥.២០ កេស ខណៈដែលបញ្ជីគណនីរបស់ក្រុមហ៊ុនបានកត់ត្រាចំនួនសរុប ១,៨៥៤,២៧៨.៦៥ កេស ជាបរិមាណដែលផ្តល់ទៅឲ្យអតិថិជនសម្រាប់ការដូររង្វាន់ (Sale Redemptions) សូមយោងទៅឧបសម្ព័ន្ធ៣៖ ការប្រៀបធៀបការដូររង្វាន់ (Sale Redemptions) សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។

២) ក្រុមហ៊ុនបានបង្កើតឯកសារផ្ទៃក្នុងសម្រាប់ការដូររង្វាន់ “Redemption Priz Claim” ដែលភ្ជាប់មកជាមួយព័ត៌មានលំអិត និងតារាងសរុបប្រចាំខែ “Redemption Oishi Caps Report month..” ផ្អែកលើឯកសារផ្ទៃក្នុងទាំងនេះ ការស្នើសុំទូទាត់ត្រឡប់ (Claims) ពីអតិថិជនសម្រាប់ការិយបរិច្ឆេទ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ គឺសរុប ១,៥៩២,៦០០.៧០ កេស។ ហេតុដូចនេះវាបានធ្វើឲ្យការផ្តល់ទៅឲ្យអតិថិជនសម្រាប់កាដូររង្វាន់ (Sale Redemptions) នៅក្នុងបញ្ជីគណនេយ្យមានបរិមាណច្រើនជាងឯកសារផ្ទៃក្នុងសម្រាប់ការដូររង្វាន់ “Redemption Prize Claim” ចំនួន ២៦១,៦៧៧.៩៥ កេស សម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។ សូមយោងទៅឧបសម្ព័ន្ធ៤៖ ការលក់ដូររង្វាន់ឯកសារផ្ទៃក្នុង (Sale Redemptions) សម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។

៣) ប៉ុន្តែផ្អែកលើរបាយការណ៍ពីខាងរោងចក្រ ចំនួនសរុបនៃការទិញដូររង្វាន់ (Purchase Redemptrions) គឺសរុបចំនួន ១,៦៧៤,៦៧៨.០០ កេស ជាចំនួននៃការដូររង្វាន់ និងការផ្សព្វផ្សាយសម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ដែលមានចំនួន ១,៥២០,៨១១.០០ កេស បានរាយការណ៍ជាការដូររង្វាន់ និងចំនួន ១៥៣,៨៦៧.០០ កេស ជាចំនួនសន្និធិសម្រាប់ផ្សព្វផ្សាយ។ សូមយោងទៅឧបសម្ព័ន្ធ៥៖ របាយការណ៍ទិញពីរោងចក្រសម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។

ដោយសារតែឯកសារគាំទ្រមានកម្រិត (វិក័យប័ត្រ/សក្ខីប័ត្រ ឯកសារដូររង្វាន់របស់អតិថិជន) មិនមានបុគ្គលិកសម្រាប់ការសាកសួរដោយផ្ទាល់មាត់ និងមិនមានការធ្វើការបញ្ជាក់ជាមួយអតិថិជន ពួកយើងមិនអាចផ្ទៀងផ្ទាត់ភាពលំអៀងរបស់សន្និធិចំនួន ២៨៣,២៤៣.៤៥ កេស សម្រាប់ការដូររង្វាន់ (ចំនួនផ្តល់ដោយក្រុមហ៊ុនច្រើនជាងចំនួនដូររង្វាន់ពីអតិថិជន) សម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។ សូមយោងទៅឧបសម្ព័ន្ធ៦៖ របាយការណ៍សន្និធិសម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ សម្រាប់ព័ត៌មានលំអិតអំពីសន្និធិដែលបានទិញ និងលក់ក្នុងគ្រា និងសន្និធិចុងគ្រា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។

ង) ទាក់ទងនឹងចំណាយការលក់ យើងបានរកឃើញថាចំណាយការលក់សរុបចំនួន ៣,២៩៤,៣០៤.៣០ ដុល្លារអាមេរិក សម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ត្រូវបានកត់ត្រាចូលទៅក្នុងបញ្ជីគណនេយ្យ និងកត់ត្រាជាឥណទានទៅថ្លៃដើមទំនិញដែលបានលក់ ហើយមិនត្រូវបានគាំទ្រ ដោយឯកសារគាំទ្រណាមួយឡើយ។ មានសំណួរទាក់ទងទៅនឹងចំណាយការលក់ទាំងនេះថា តើបានកើតឡើងដែរទេ ពីព្រោះចំណាយនេះត្រូវបានធ្វើចំណាត់ថ្នាក់គណនីឡើងវិញ (ការចុះបញ្ជីបិទទិនានុប្បវត្តិ) នៅក្នុងបញ្ជីគណនេយ្យជំនួសឱ្យការកើតឡើងពិតប្រាកដ ឬគាំទ្រដោយឯកសារណាមួយ។ ទោះជាយ៉ាងណាក៏ដោយ នេះគឺជាការចុះបញ្ជីដែលមិនមែនជាសាច់ប្រាក់ (មិនទាក់ទិនជាមួយសាច់ប្រាក់) ហើយជាលទ្ធផល មិនមានការថយចុះនៃទ្រព្យសម្បត្តិ ឬមិនមានការកើនឡើងបំណុលរបស់ក្រុមហ៊ុនឡើយ។

ដោយសារតែមិនមានឯកសារគាំទ្រ និងមិនមានបុគ្គលិកសម្រាប់សាកសួរដោយផ្ទាល់មាត់ យើងមិនអាចបញ្ជាក់ពីសុពលភាពនៃការចំណាយការលក់សរុបចំនួន ៣,២៩៤,៣០៤.៣០ ដុល្លារអាមេរិក សម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ នោះទេ។ សូមយោងទៅឧបសម្ព័ន្ធ៧៖ របាយការណ៍សង្ខេបចំណាយការលក់ សម្រាប់ការិយបរិច្ឆេទថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។

១៥-តាមចម្លើយរបស់សាក្សី ,អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ,អំណានចម្លើយរបស់ជនជាប់ចោទ ,អំណានចម្លើយរបស់សាក្សី និងរបាយការណ៍សវនកម្មការរកឃើញតថភាពពិត ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ឃើញថា ឈ្មោះ [redacted]ហាក់លី មានតួនាទីជានាយកគ្រប់គ្រងទូទៅ នៅក្នុងអាណត្តិដែលក្រុមហ៊ុនប្រគល់សិទ្ធិឱ្យ នៅក្រោមការគ្រប់គ្រងរបស់ខ្លួន ចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ ជននេះបានរៀបចំបណ្តាញឱ្យសាច់ញាតិរបស់ខ្លួនមាន ប្រពន្ធរបស់ខ្លួនធ្វើជាតំណាងចែកចាយដេប៉ូធំប្រចាំនៅក្រុងភ្នំពេញ បងថ្លៃរបស់ខ្លួនធ្វើជាតំណាងចែកចាយដេប៉ូធំនៅខេត្តកណ្តាល និងឪពុកក្មេករបស់ខ្លួនធ្វើជាតំណាងចែកចាយដេប៉ូធំប្រចាំខេត្តកំពង់ចាម និងរៀបចំបុគ្គលិកដែលជាមនុស្សរបស់ខ្លួនឱ្យកាន់កិច្ចការងារដូចជា ផ្នែកទូទាត់លុយ ប្រមូលលុយ ការប្តូរប្រាក់ ដើម្បីយកវេរតាមធនាគារ និងតាមកន្លែងប្តូរប្រាក់នៅអូឡាំពិក ទូទាត់ទំនិញជាមួយក្រុមហ៊ុនថៃ លើសពីនេះទៅទៀត ឈ្មោះ [redacted] រតន: ជាប្រធានគណនេយ្យ ជាអ្នករៀបចំបញ្ជីដើម្បីបិទបាំងនូវសកម្មភាពកិបកេងទ្រព្យរបស់ក្រុមហ៊ុន។

១៦-តាមចម្លើយសាក្សីឈ្មោះ [redacted] រ័ត្ន: ដែលមានជំនាញផ្នែកគណនេយ្យ ហើយត្រូវបានក្រុមហ៊ុនឱ្យមកកជំនួសតំណែងលោក [redacted] សាក់លី ឃើញថា ក្រុមហ៊ុនក៏បានធ្វើសវនកម្មផ្ទៃក្នុងរបស់ខ្លួន ដែលសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុនមានភាពស៊ីសង្វាក់ជាមួយសវនកម្មឯករាជ្យរបស់ក្រុមហ៊ុន អេច អេស ស៊ី ដែលបានរកឃើញថា ពិតជាមានការបាត់បង់ទ្រព្យរបស់ក្រុមហ៊ុនតាមរយៈអត្រាប្តូរប្រាក់ខុសហេហាងឆេង តាមរយៈការផ្តល់គម្របរង្វាន់លើសទៅឱ្យដេប៉ូ និងការទូទាត់ប្រាក់ជាមួយអតិថិជន សរុបចំនួន ៣,៨២៨,៣០៤.៩០$ (បីលានប្រាំបីសែនពីម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន) ដែលសកម្មភាពទាំងនេះ កើតឡើងក្រោមការចាត់ចែងរបស់បុគ្គលឈ្មោះ [redacted] សាក់លី និងមានការសម្រួលឯកសារបញ្ជីឈ្មោះ [redacted] រតន:។

១៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី មានតួនាទីជានាយកគ្រប់គ្រងទូទៅ និងឈ្មោះ [redacted] រតនៈ ជាបុគ្គលិកក្រុមហ៊ុន មានតួនាទីជាប្រធានគណនេយ្យ ក្នុងមុខងាររបស់ខ្លួនជនជាប់ចោទទាំងពីររូបនេះ បានឃុបឃិតគ្នាបានធ្វើរបាយការណ៍គណនេយ្យភូតកុហក ផ្លាស់ប្តូរទិន្នន័យ បង្កើតឱ្យមានការលំអៀងប្រាក់ កិបកេងប្រាក់របស់ក្រុមហ៊ុនយកធ្វើជាផលប្រយោជន៍ផ្ទាល់ខ្លួន ដូច្នេះទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ មានធាតុផ្សំជាបទល្មើស រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ហើយក្នុងទង្វើរបស់ជនជាប់ចោទរូបនេះ បានធ្វើឱ្យជនរងគ្រោះឈ្មោះ [redacted] ហុង ខូចខាតផលប្រយោជន៍ចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន)។

១៨-ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្ត ជននេះមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

១៩-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ បានបង្ហាញឱ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទរូបនេះមានចេតនាទុច្ចរិត ដែលការប្រព្រឹត្តទាំងនេះធ្វើអោយខូចរបៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋពល និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា ៣៩១ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២០-មានភស្តុតាង និងមានពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ សុង សាក់លី ភេទប្រុស អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ៣៥ឆ្នាំ ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ មាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២១-ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតនៈ ត្រូវបានតុលាការសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន តែមានកាតព្វកិច្ចត្រូវគោរពនូវវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ ប៉ុន្តែជនជាប់ចោទទាំង២នាក់នេះ មិនគោរពនូវការកោះហៅរបស់តុលាការឱ្យចូលមកសវនការនោះទេ ថែមទាំងមានចេតនារឹងរូសចង់រួសបន្លាយនីតិវិធីតុលាការ ដោយប្តឹងដកចិត្តចៅក្រមរាល់ពេលសវនាការដោយគ្មានមូលហេតុ ទោះបីធ្លាប់ត្រូវបានសាលាឧទ្ធរណ៍សម្រេចច្រានចោលបណ្តឹងរបស់ខ្លួនយ៉ាងណាក្តី ទាំងនេះសរបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទទាំង២នាក់គ្មានបំណងកែប្រែខ្លួន ដើម្បីចូលមករួមរស់ក្នុងសង្គមវិញនោះទេ ដូច្នេះគប្បីសម្រេចផ្តន្ទាទោស និងបង្គាប់ឱ្យចាប់ខ្លួនដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

២២-ក្នុងរឿងនេះ ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង បានទាមទារប្រាក់ចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន) និងទាមទារជួសជុលការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៥០០,០០០$ (ប្រាំសែនដុល្លារអាមេរិក) ព្រមទាំងសេវាមេធាវី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) គប្បីតុលាការលើកមកពិចារណាក្នុងការសម្រេចសេចក្តី។

២៣-ព្យសនកម្មដែលកើតឡើងលើជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង ដែលខាតបង់ទ្រព្យសម្បត្តិដោយសារអំពើទុច្ចរិតរបស់ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: ដូច្នេះជនជាប់ចោទទាំងពីររូបនេះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការជួសជុលសំណងដល់ជនរងគ្រោះ និងជំងឺចិត្តតាមកំរិត និងព្យសនកម្មដែលកើតឡើងចំពោះជនរងគ្រោះ។

២៤-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី មានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្ដី។

២៥-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ មានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្ដី។

២៦-ជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: មិនបានចូលមកបង្ហាញខ្លួននៅពេលសវនាការ ប៉ុន្តែសាមីខ្លួនបានដឹងអំពីការកោះហៅនេះហើយ ថែមទាំងបានប្ដឹងជំទាស់ទៅក្រុមចំនួន០៣លើកជាប់ៗគ្នា ទោះបីសាលាឧទ្ធរណ៍សម្រេចច្រានចោលបណ្ដឹងជំទាស់នេះរួចមកហើយក្ដី ដូចនេះបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: ពិតជាបានដឹងអំពីការកោះហៅឱ្យចូលសវនាការ តែបែរជាមិនចូលមកបង្ហាញខ្លួននាពេលសវនាការទេ គប្បីតុលាការសម្រេចសេចក្ដីកំបាំងមុខតែចាត់ទុកជាចំពោះមុខ តាមបញ្ញត្តិមាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

១-ផ្ដន្ទាទោស:

១.១-ឈ្មោះ [redacted] សាក់លី ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦,០០០,០០០៛ (ប្រាំមួយលានរៀល)។

១.២-ឈ្មោះ [redacted] រតន: ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦,០០០,០០០៛ (ប្រាំមួយលានរៀល)។

ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យធ្វើការចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] សាក់លី ភេទប្រុស អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] រតន: ភេទប្រុស អាយុ៣៥ឆ្នាំ ដើម្បីអនុវត្តទោសតាមអំណាចសាលក្រមនេះ។

៣-បង្គាប់ឱ្យឈ្មោះ [redacted] សាក់លី និងឈ្មោះ [redacted] រតន: រួមគ្នាសងសំណងចំនួន ៣,៨២៨,៣០៤.៤០$ (បីលានប្រាំបីសែនពីម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក និងសែសិបសេន) និងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា ចំនួន ៦០,០០០,០០០៛ (ហុកសិបលានរៀល) ឱ្យទៅជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង ។ ការទាមទារលើសពីនេះច្រានចោល។

-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ និងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ សុង សាក់លី និងឈ្មោះ

[redacted]រតន: និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១។ ភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា:** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា:** [redacted]

................................................................................................................................

"បានចំលងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃចន្ទ ១៣ រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]